លេខ ១២
ឆ្នាំ២០២២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



# បុព្វកថា

នៅក្នុងបរិការណ៍ឆ្នាំ២០២១, ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវបាននិងកំពុងបន្តនាំមកនូវផលប៉ះពាល់អវិជ្ជមាន បញ្ហា-ប្រឈម និងហានិភ័យជាច្រើន ដែលមិនធ្លាប់មានពីមុនមក ចំពោះតំបន់ និងពិភពលោកទាំងមូល ដោយគ្មានការលើកលែងចំពោះប្រទេសណាមួយឡើយ ជាពិសេសគឺបានធ្វើឱ្យមនុស្សរាប់លាននាក់បាត់បង់ការងារ ធ្លាក់ចុះនូវប្រាក់ចំណូល ហើយប្រជាជនមួយចំនួនធំនៅលើពិភពលោក ត្រូវធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ ហើយកម្ពុជាក៏មិនអាចគេចរួចពីវិបាកអាក្រក់ទាំងនេះផងដែរ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ តែថែមទាំងអាចទាញបង្អន់ល្បឿននៃកិច្ចដំណើរការអភិវឌ្ឍន៍ឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ ផងដែរ។

ឆ្លងកាត់ដំណាក់កាលដ៏លំបាកនេះ ទោះបីកម្ពុជាជាប្រទេសតូច ហើយធនធានក៏នៅមានកម្រិតក្តី ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានៅរក្សាបានស្ថានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាព នៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងការវិភាជឡើងវិញនូវចំណាយក្នុងឆ្នាំ, រាជរដ្ឋាភិបាលមានសមត្ថភាព និងលទ្ធភាពអាចគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ បានល្អប្រសើរ ឆ្លើយតបបានទៅនឹងកិច្ចការអាទិភាព ដែលកើតមានថ្មីៗ ដោយផ្អែកលើមូលដ្ឋានគ្រឹះ រឹងមាំនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលយើងខិតខំកសាងបាននៅក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមក ជាពិសេសក្នុងរយៈពេល ៧ឆ្នាំចុងក្រោយ ព្រមជាមួយនឹងការចូលរួម យ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ផ្លូវការ វិស័យឯកជន ព្រមទាំងអង្គការ និងសង្គមស៊ីវិលផងដែរ។ លើសពីនេះ ជាមួយនឹងកិច្ចប្រឹងប្រែងតស៊ូជម្នះនឹងវិបត្តិនៃជំងឺកូវីដ-១៩, សំដៅកាត់បន្ថយផលប៉ះពាល់ នៃវិបត្តិនេះមកលើសុខភាព ជីវភាពរស់នៅរបស់ប្រជាជន និងសង្គម-សេដ្ឋកិច្ចទាំងមូល។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏បានគិតគូររៀបចំនូវ "ផែនការស្តារសេដ្ឋកិច្ចឡើងវិញ" សម្រាប់ឆ្នាំ២០២១-២០២៣ ដែលជាការត្រៀមខ្លួន សម្រាប់ដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ (Post Covid-19) ដើម្បីឈានទៅបង្កើតបាននូវភាពធន់ (Resiliency) របស់កម្ពុជា ទៅនឹងវិបត្តិសម្រាប់រយៈពេលវែងខាងមុខ រួមបញ្ចូលនូវវិបត្តិសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ និងការរាតត្បាតនៃជំងឺឆ្លងនានាផងដែរ។

សមិទ្ធផលដែលសម្រេចបានមកដល់ពេលនេះ គឺដោយសារការចូលរួមយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវក្នុងភាពជាម្ចាស់របស់ក្រសួង-ស្ថាប័ន ព្រមទាំងមានការគាំទ្រជាប្រចាំ និងការប្តេជ្ញាចិត្តឥតងាករេពីថ្នាក់ដឹកនាំ និងស្ថាបនិកគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់សូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាសេនាធិការ ជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងការងារដឹកនាំ សម្របសម្រួល គាំទ្រ ផ្សព្វផ្សាយ ត្រួតពិនិត្យ ព្រមទាំងវាយតម្លៃ ប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម៕៚

ថ្ងៃ *អង្គារ ៣ កើត* ខែ *មិគសិរ* ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី *០៧* ខែ *ធ្នូ* ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ក្នុងស្ថានភាពដែលកម្ពុជា កំពុងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងរយៈកាលជាង ១ឆ្នាំកន្លងមកនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកទ្រទ្រង់ស្ថានភាពសេដ្ឋកិច្ចមិនឱ្យធ្លាក់ចុះខ្លាំង និងអាចគ្រប់គ្រងបាន ព្រមទាំងនៅបន្តដំណើរទៅមុខក្នុងការពុះពារឧបសគ្គដើម្បីធានាបាននូវការសម្រេចគោលដៅ និងចក្ខុវិស័យចុងក្រោយរបស់កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។ ជាការពិត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងស្ថិតនៅលើមាគ៌ា និងទិសដៅត្រឹមត្រូវដែលយើងអាចរក្សាបាននូវភាពជាម្ចាស់ទាំងស្រុង ហើយរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានជ្រើសរើសអភិក្រមប្រតិបត្តិ ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន ជាពិសេសដែលផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់នៅតាមដំណាក់កាលនីមួយៗ។ បន្ថែមពីនេះ ប្រព័ន្ធថវិកាយើងកាន់តែមានភាពជឿទុកចិត្ត និងជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

រហូតមកដល់ពេលនេះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដំណើរការបានរយៈពេលជិត ១៧ឆ្នាំហើយគឺចាប់ពីឆ្នាំ២០០៤ មក ព្រមទាំងទទួលបានការគាំទ្រ និងចូលរួមអនុវត្តយ៉ាងផុសផុលពីគ្រប់ស្ថាប័ន ព្រមទាំងអង្គភាពនៃរាជរដ្ឋាភិបាល ហើយសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងទាំងនេះក៏ទទួលបានការសាទរ និងកោតសរសើរពីសាធារណជនទូទៅផងដែរ។ ដូចនេះដើម្បីបន្តលើកកម្ពស់ការយល់ដឹង និងការគាំទ្រដល់ទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា, **អ.គ.ហ.** ដែលជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតែបន្តបេសកកម្មរបស់ខ្លួនឥតងាករេ ក្នុងការបញ្ជ្រាបការយល់ដឹងថ្មីៗបន្ថែម ក៏ដូចជាផ្សព្វផ្សាយនូវសមិទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់តាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ការផ្សព្វផ្សាយ និងកិច្ចប្រជុំនានា។

ជាក់ស្តែង សម្រាប់ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ១២ នេះ នឹងចងក្រងនូវព្រឹត្តិការណ៍ថ្មីៗ សុន្ទរកថា និង ទស្សនមតិរបស់ថ្នាក់ដឹកនាំ រួមទាំងអត្ថបទពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានតម្លៃជាច្រើន ដែលអាចផ្តល់ប្រយោជន៍បន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជនដែលចង់ឈ្វេងយល់អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ល៕

ថ្ងៃ ព្រហស្បតិ៍ ១៣ រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០២១

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - លេខ១២- ឆ្នាំ២០២២

## ព្រឹត្តិការណ៍


### ទំព័រទី០១
កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២ ប្រចាំឆមាសទី១ ឆ្នាំ២០២១

### ទំព័រទី០៤
វគ្គបណ្តុះបណ្តាលសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលដោយមន្ទីរអង្គភាព

### ទំព័រទី១២
សមិទ្ធផលកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ទំព័រទី១៥
លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើកទី៣ ឆ្នាំ២០២១

### ទំព័រទី២១
ប្រព័ន្ធ FMIS ដើរតួយ៉ាងសំខាន់ និងមិនអាចខ្វះបាននៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាល ព្រមទាំងនៅក្នុង

### ទំព័រទី២៣
បទពិសោធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការកែទម្រង់ការបើកផ្តល់បៀវត្សតាមនីតិវិធីថ្មីស្របភ្ជាប់ជាមួយនឹងប្រព័ន្ធ FMIS


## អត្ថបទ


### ទំព័រទី៧
អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ÷ ភាពចាំបាច់ នៃការកែទម្រង់រចនាសម្ព័ន្ធ

### ទំព័រទី៩
ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ២០២១- ២០២៥

### ទំព័រទី២៥
ការវិវត្តរចនាសម្ព័ន្ធកម្មវិធីនិងការផ្ទេរសិទ្ធិជូនអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ទំព័រទី២៩
គោលការណ៍គ្រឹះនៃថវិកា ÷ សសរស្តម្ភនៃវិន័យថវិកា

**ទំព័រទី៣៣**
តួនាទីស្ថាប័ននីតិប្បញ្ញត្តិ និងការិយាល័យថវិកាក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ របកគំហើញសម្រាប់កម្ពុជា

**ទំព័រទី៣៩**
បច្ចុប្បន្នភាពនៃមុខងារសវនកម្មផ្ទៃក្នុង

**ទំព័រទី៤១**
តួនាទី និងសារៈសំខាន់នៃគណនេយ្យភាពក្នុងការងារកែទម្រង់

## សុន្ទរកថា

**ទំព័រទី៤៣**
សុន្ទរកថា ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពិធីប្រកាសដាក់ដំណើរការជាផ្លូវការប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន- ដំណាក់កាលទី២

**ទំព័រទី៤៧**
សុន្ទរកថា របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងសិក្ខាសាលាស្តីពី ការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

## ទស្សនៈ និងមតិ

**ទំព័រទី៥៣**
ទស្សនៈ និងមតិ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ទំព័រទី៥៣**
ទស្សនៈ និងមតិ របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ទំព័រទី៥៤**
ទស្សនៈ និងមតិ របស់ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**ទំព័រទី៥៤**
ទស្សនៈ និងមតិ របស់ឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



# ផ្នែកទី ១

# ព្រឹត្តិការណ៍

# កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២ ប្រចាំឆមាសទី១ ឆ្នាំ២០២១

*នាព្រឹកថ្ងៃចន្ទ ១៥ កើត ខែស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ នាទី នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរៀបចំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិភាក្សាអំពីរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆមាសទី១ ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) និងមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*

កិច្ចប្រជុំនេះ ផ្ដោតសំខាន់លើការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២ និងវឌ្ឍនភាព នៃការអនុវត្តគម្រោង FMIS ប្រចាំឆមាសទី១ ឆ្នាំ២០២១។

ជាលទ្ធផល នៅក្នុងត្រីមាសទី១ និងទី២ ឆ្នាំ២០២១ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ បូក២ សម្រេចបានដូចខាងក្រោម÷

❖ “ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា”

គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២១ រក្សាបានក្នុងស្ថានភាពល្អ និងអាចទុកចិត្តបាន ដែលការអនុវត្តចំណូល គឺស្ថិតនៅក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់តាមរយៈការបន្តពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការអនុវត្តផែនការប្រមូលចំណូល ជាពិសេសការខិតខំប្រឹងប្រែងអនុវត្តផែនការសកម្មភាព




*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*

ដូចមានចែងក្នុងយុទ្ធសាស្ត្រកៀរគរចំណូល។ រីឯការអនុវត្តចំណាយយឺតជាងផែនការបន្តិចក្តី តែស្ថិតក្នុងស្ថានភាពដែលអាចសម្រេចបានតាមគោលដៅក្នុងឆ្នាំ។ ទន្ទឹមនេះ ដំណើរការនៃការអនុវត្តថវិកាចាប់ផ្តើមកែលម្អតាមរយៈ ការសិក្សា និងដាក់ចេញផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះ ពង្រីកការទូទាត់ចំណាយថវិកាជាតិតាម E-Transfer ការរៀបចំគោលការណ៍ណែនាំហិរញ្ញវត្ថុសាធារណៈ




តាមក្រសួង ស្ថាប័ន និងការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តផែនការយុទ្ធសាស្រ្តកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈជាដើម។

❖ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"

ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ត្រូវបានពង្រឹង និងពង្រីកការអនុវត្ត តាមរយៈ ការបន្តដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមក្រសួង-ស្ថាប័ន ការពង្រីកមុខងារបន្ថែមថ្មីក្នុងប្រព័ន្ធ FMIS ជាពិសេសការពង្រីកការអនុវត្តគម្រោង FMIS ដល់រដ្ឋបាលរាជធានី ខេត្តទាំង២៥។ កម្រិតអនុលោមភាព នៃរបាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អ។ ទន្ទឹមនេះ លិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ បាននឹងកំពុងបន្តរៀបចំជាបន្តបន្ទាប់។

❖ "ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

ក្របខណ្ឌថវិការយៈពេលមធ្យម ឆ្នាំ២០២២ ដោយមានពិតានតាមវិស័យតាមក្រសួង-ស្ថាប័ន ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២២ ត្រូវបានរៀបចំសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ រីឯ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម ឆ្នាំ២០២៣-២០២៥ គ្រោងនឹងដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០២២ ដែលឯកសារទាំងអស់នេះនឹងបង្កលក្ខណៈងាយស្រួលដល់ក្រសួង-ស្ថាប័នក្នុងការរៀបចំថវិកា ដោយមានការកំណត់តាមក្រសួង-ស្ថាប័ន តាមវិស័យ, ការធ្វើសមាហរណកម្មថវិកាចរន្ត និងវិនិយោគ។ ជាមួយគ្នានេះ ការគ្រប់គ្រងគម្រោងវិនិយោគបាននឹងកំពុងកែលម្អតាមរយៈការរៀបចំយន្តការ និងលិខិតគតិយុត្តនានា ដូចមានចែងក្នុងផែនការយុទ្ធសាស្រ្ត។



ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

❖ "ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម"

សម្រាប់ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មជាការចាំបាច់ ដែលត្រូវបញ្ចប់ សម្រាប់ដាក់ឱ្យអនុវត្តនៅឆ្នាំ២០២២ ក្នុងនោះរួមមាន÷ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), អនុក្រឹត្យលេខ៨១ និង ៨២ និងក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម។




ជាមួយគ្នា ប្រព័ន្ធតាមដាន និងត្រួតពិនិត្យសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។

❖ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត"

សម្រាប់ ស្ថិតក្នុងបរិការណ៍កូវីដ-១៩ ការអនុវត្តការបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយ អាចអនុវត្តបានដោយផ្អែក ដោយត្រូវធ្វើតាមប្រព័ន្ធអនឡាញ រីឯវគ្គបណ្តុះបណ្តាល ដែលតម្រូវឱ្យចុះអនុវត្តផ្ទាល់ត្រូវបានពន្យារពេល ប៉ុន្តែមិនរងផលប៉ះពាល់ដល់ចលនការ នៃការកែទម្រង់ទេ។ ជាមួយគ្នានេះ ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង ព្រមទាំង គ្រោងពង្រីកដល់ក្រសួង-ស្ថាប័ននៅឆ្នាំ២០២២។ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផលដែលគ្រោងនឹងបញ្ចប់នៅត្រីមាសទី៣ នឹងចូលរួមក្នុងការរៀបចំផែនការសកម្មភាព និងសូចនករសមិទ្ធកម្មគន្លឹះ ឱ្យកាន់តែមានភាពច្បាស់លាស់។

ជាទីបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កន្លងមករហូតសម្រេចបានសមិទ្ធផលនេះ ទោះបី

*ក្របខណ្ឌថវិការយៈពេលមធ្យមឆ្នាំ២០២២ ដោយមានពិតានតាមវិស័យ តាមក្រសួង-ស្ថាប័ន ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២២ ត្រូវបានរៀបចំ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២*

កម្ពុជាកំពុងស្ថិតក្នុងវិបត្តិកូវីដ-១៩ក៏ដោយ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ក៏បានស្នើគ្រប់អង្គភាពក្រោមឱវាទក្រសួង បន្តជំរុញការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២ ដើម្បីសម្រេចតាមគោលដៅដែលបានគ្រោងទុក និងជូនពរគ្រប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។■

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធ*

# វគ្គបណ្តុះបណ្តាលសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរអង្គភាពជំនាញរាជធានី ខេត្ត

*ប្រតិបត្តិតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ បានរៀបចំវគ្គបណ្តុះបណ្តាលសារាចរលេខ០០៦ សហវ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរអង្គភាពជំនាញរាជធានី ខេត្ត ដែលប្រព្រឹត្តទៅតាមរយៈប្រព័ន្ធវីឌីអូអនឡាញ ។*

វគ្គបណ្តុះបណ្តាលនេះ ដឹកនាំដោយឯកឧត្តម **យ៉េត វីរៈណុល** អនុរដ្ឋលេខាធិការនៃ កសហវ. និងជាអគ្គលេខាធិការរង នៃ **អ.គ.ហ.** តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការនៃ កសហវ. និងជាអគ្គលេខាធិការនៃ**អ.គ.ហ.** អមដោយលោក **អ៊ុំ យុទ្ធី** ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យវាយតម្លៃ ព្រមទាំងមានការអញ្ជើញចូលរួមជាវាគ្មិនពីតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ព្រមទាំងលោក លោកស្រី អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ទីចាត់ការហិរញ្ញវត្ថុ អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងមន្ទីរជំនាញប្រមូលចំណូលមិនមែនសារពើពន្ធ នៃរដ្ឋបាលរាជធានី-ខេត្តទាំង ២៥ ដោយមានការសម្របសម្រួលពីមន្ទីរ សហវ. និងរតនាគាររាជធានី ខេត្ត។

វគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅចំនួន ៣លើក គឺ**លើកទី១** នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ ដោយចូលរួមពីរដ្ឋបាលខេត្តចំនួន៨ រួមមាន÷ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ។ **លើកទី២** នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ដោយមានការចូលរួមពីរដ្ឋបាលខេត្តចំនួន ៨ រួមមាន÷ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តព្រះវិហារ និងខេត្តកណ្តាល។ **លើកទី៣** នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ដោយចូលរួមពីរដ្ឋបាលរាជធានី-ខេត្តចំនួន ៩ រួមមាន÷ រាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ



ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប។ អ្នកចូលរួមសរុបប្រមាណ ៧៣០ រូប។ ការរៀបចំវគ្គបណ្តុះបណ្តាល ចំនួន ៣ លើកនេះ គឺក្នុងគោលបំណង ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យ លេខ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត សំដៅដោះស្រាយបញ្ហា ដែលកំពុង ប្រឈមពាក់ព័ន្ធនឹង ការគ្រប់គ្រងចំណូល មិនមែនសារពើពន្ធ និងការបែងចែកប្រាក់ រង្វាន់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។


ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

សារាចរ
ស្តីពី
នីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវានិងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត



## គ.សាវតារនៃការរៀបចំវគ្គបណ្តុះបណ្តាល

កាលពីអំឡុងត្រីមាសទី១ ឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសនៃ **អ.គ.ហ.** ដឹកនាំដោយ ឯកឧត្តម **យ៉េត វីណែល** បានចុះប្រមូលព័ត៌មាននៅរដ្ឋបាលរាជធានី-ខេត្ត មួយចំនួន ដើម្បីជាធាតុចូលក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។ ក្នុងអំឡុងពេលនោះ ក្រុមការងារបានរកឃើញបញ្ហាប្រឈមទាក់ទិននឹងការគ្រប់-គ្រងចំណូលមិនមែនសារពើពន្ធ និងការបែងចែកប្រាក់រង្វាន់សម្រាប់ឆ្នាំ២០២០ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីចាត់វិធានការដោះស្រាយជាបន្ទាន់ **អ.គ.ហ.** បានរៀបចំកិច្ចប្រជុំ ពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ. ដែលជាលទ្ធផល **អ.គ.ហ.** ពិនិត្យឃើញថា អនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត ត្បិតត្រូវបានដាក់ឱ្យអនុវត្ត ប៉ុន្តែមិនទាន់មានសារាចរណែនាំដែលចែងអំពីនីតិវិធីលម្អិតអំពីការបែងចែកនិងការបង់ចំណូល ព្រមទាំងការកត់ត្រាកិច្ចបញ្ជិកាគណនេយ្យនៅឡើយ។ ស្ថិតក្នុងអន្តរកាលនោះ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ. បាននិងកំពុងរៀបចំសារាចរណែនាំដែលចែងអំពីនីតិវិធីលម្អិតសម្រាប់ពង្រឹងការអនុវត្តអនុ-ក្រឹត្យលេខ២៥ អនក្រ.បកនេះ។

ក្នុងស្មារតីនេះ ដោយប្រតិបត្តិតាមអនុ-សាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គ-បណ្ឌិតសភាចារ្យ** ព្រមទាំងទទួលបានការចាត់តាំងពីឯកឧត្តម **រស់ សីលវ៉ា**,ឯកឧត្តម **យ៉េត វីណែល** បានដឹកនាំកិច្ចប្រជុំកម្រិតបច្ចេកទេសចំនួន ៥លើក ជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ. និងអគ្គនា-យកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ដើម្បីជំរុញការរៀបចំសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកា នៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត ព្រមទាំងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត។ ជាលទ្ធផល សារាចរនេះទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិត-សភាចារ្យ** នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ដែលមានអនុភាពអនុវត្តចាប់ពីខែមករា ឆ្នាំ២០២០ និងត្រូវបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយម្តងរួចមកហើយជូនអង្គភាព និងមន្ទីរជំនាញពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត ទាំង២៥ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។

ក្នុងន័យនេះ ដោយយោងតាមតម្រូវការចាំបាច់ស្របតាមស្មារតីសិក្ខាសាលាខាងលើ, **អ.គ.ហ.** សហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ. និងអគ្គនា-យកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ បានរៀបចំវគ្គបណ្តុះបណ្តាលនេះម្តងទៀត ជូនរដ្ឋបាលរាជធានី-ខេត្តទាំង២៥ រួមជាមួយនឹងអង្គភាព និងមន្ទីរជំនាញពាក់ព័ន្ធ តាមរយៈ Video Conference សំដៅបញ្ជ្រាបការយល់ដឹងបន្ថែម និងដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗ ដែលកំពុងជួបការប្រឈមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ.ការប្រព្រឹត្តទៅនៃវគ្គបណ្តុះបណ្តាល និងការចាត់វិធានការបន្ត

ដើម្បីបំពេញតម្រូវការដែលស្នើដោយ

សិក្ខាកាម និងដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមានឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, វគ្គបណ្ដុះបណ្ដាលនេះ ផ្ដោតលើបទបង្ហាញចំនួន៥ ដូចខាងក្រោម÷

**(១).** អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត

**(២).** គោលការណ៍ទូទៅនៃសារាចរលេខ ០០៦ សហវ.

**(៣).** ការគ្រប់គ្រងចំណូលពីសេវាសាធារណៈ និងពិន័យនៅតាមរាជធានី-ខេត្ត

**(៤).** រំហូរបង់ចំណូលមិនមែនសារពើពន្ធ

**(៥).** កិច្ចបញ្ជិកាគណនេយ្យជាគុណប្រយោជន៍របស់រដ្ឋបាលរាជធានី-ខេត្ត។

វគ្គបណ្ដុះបណ្ដាលទាំង៣ លើកនេះប្រព្រឹត្តទៅយ៉ាងពេញលេញ និងផុលផុសដោយមានសំណួរសំខាន់ៗចោទសួរពីជាច្រើនពីអ្នកចូលរួម។ ឯកឧត្ដម **យ៉េត វីណែល** អនុរដ្ឋលេខាធិការ កសហវ. និងជាអគ្គលេខាធិការរង **អ.គ.ហ.** បានកត់សម្គាល់ឃើញថា វគ្គបណ្ដុះបណ្ដាលទាំង៣ លើកនេះបានដោះស្រាយបញ្ហាស្មុគស្មាញមួយចំនួនធំ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអាទិ៍÷ (១). ការសម្របសម្រួលរវាងអគ្គនាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរវាងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋបាលរាជធានី-ខេត្ត និងមន្ទីរ អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានី-ខេត្ត, (២). ការគ្រោងចំណូល និងឥណទានសម្រាប់ទូទាត់ប្រាក់រង្វាន់ពីចំណូលកម្រៃសេវាសាធារណៈ ឱ្យបានគ្រប់ជ្រុងជ្រោយ និងការអនុវត្តនីតិវិធីបែងចែកប្រាក់រង្វាន់តាមប្រភេទសេវាដែលមានក្នុងប្រកាសអន្តរក្រសួង និងការបង់ចំណែកថវិកាជាគុណប្រយោជន៍រដ្ឋបាលថ្នាក់ក្រោមជាតិ និងការស្នើសុំឥណទានបន្ថែមសម្រាប់ទូទាត់ប្រាក់រង្វាន់, (៣). ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និង(៤). ការពង្រឹងយន្តការតាមដាន និងវាយតម្លៃការអនុវត្តរបស់អង្គភាពច្រកចេញចូលតែមួយ ឬការផ្ដល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ របស់ក្រសួងមហាផ្ទៃ ជាពិសេសការទូទាត់អាណត្តិ ការកត់ត្រាកិច្ចបញ្ជិការគណនេយ្យ និងការរៀបចំរបាយការណ៍ជាដើម។ ទោះជាយ៉ាងនេះក្ដី ដើម្បីបន្តដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ និងបញ្ហាប្រឈមដែលនឹងបន្តកើតមាន ឯកឧត្ដម **យ៉េត វីណែល** បានស្នើជាវិធានការ ដូចខាងក្រោម÷

> *ការរៀបចំវគ្គបណ្ដុះបណ្ដាលសម្រាប់រដ្ឋបាលរាជធានី-ខេត្តទាំង២៥ រួមទាំងមន្ទីរ និងអង្គភាពជំនាញពាក់ព័ន្ធដែលមានការពិភាក្សាគ្នាយ៉ាងផុសផុល គឺជាធាតុចូល និងជាមូលដ្ឋានចាំបាច់បំផុតសម្រាប់រៀបចំក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារនិងចែករំលែកចំណូលមិនមែនសារពើពន្ធពីក្រសួង-ស្ថាប័នឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានគ្រប់ជ្រុងជ្រោយ និងឈានទៅកែសម្រួលប្រកាសអន្តរក្រសួងនានាទាក់ទិននឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ*

- ◈ ស្នើរដ្ឋបាលរាជធានី-ខេត្ត សហការជាមួយមន្ទីរ អង្គភាពជំនាញជុំវិញរាជធានី-ខេត្ត ពិនិត្យលើការគ្រោងថវិកាឱ្យបានគ្រប់ជ្រុងជ្រោយ ស្របទៅនឹងសក្ដានុពលក្នុងការកៀរគរចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលរាជធានី-ខេត្ត
- ◈ ស្នើរដ្ឋបាលរាជធានី-ខេត្តព្រមទាំងមន្ទីរ អង្គភាពជំនាញ រៀបចំ និងផ្ញើរបាយការណ៍ស្ដីពីការទូទាត់ប្រាក់រង្វាន់ និងរបាយការណ៍ចំណាយសម្រាប់ពង្រឹងយន្តការស្ថាប័នមកមន្ទីរ សហវ រាជធានី-ខេត្ត ពិនិត្យ និងបូកសរុបផ្ញើមក កសហវ.
- ◈ **អ.គ.ហ.** នឹងសិក្សាលទ្ធភាពបញ្ចូលបញ្ហាប្រឈមទាក់ទិនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងផែនការសកម្មភាពរួមក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ន ដើម្បីពិនិត្យ តាមដាន អនុវត្តបន្ត
- ◈ **អ.គ.ហ.** សហការជាមួយអង្គភាពក្រោមឱវាទ កសហវ. នឹងសម្របសម្រួលជំរុញការរៀបចំក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីក្រសួង-ស្ថាប័នឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានរួចរាល់នៅដំណាច់ឆ្នាំ២០២១។

ការរៀបចំវគ្គបណ្ដុះបណ្ដាលសម្រាប់រដ្ឋបាលរាជធានី-ខេត្តទាំង២៥ រួមទាំងមន្ទីរ និងអង្គភាពជំនាញពាក់ព័ន្ធដែលមានការពិភាក្សាគ្នាយ៉ាងផុលផុសគឺជាធាតុចូល និងជាមូលដ្ឋានចាំបាច់បំផុតសម្រាប់រៀបចំក្របខណ្ឌគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងចែករំលែកចំណូលមិនមែនសារពើពន្ធពីក្រសួង-ស្ថាប័ន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានគ្រប់ជ្រុងជ្រោយ និងឈានទៅកែសម្រួលប្រកាសអន្តរក្រសួងនានា ទាក់ទិននឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ព្រមទាំងផ្ដល់រូបភាពកាន់តែច្បាស់លាស់ និងមានភាពងាយស្រួលសម្រាប់ការអនុវត្តសំដៅ អនុលោមតាមទិសដៅនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការផង៕■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*



# ផ្នែកទី ២

# អត្ថបទ

# ភាពចាំបាច់នៃការកែទម្រង់រចនាសម្ព័ន្ធរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

*នៅកម្ពុជា វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បាននិងកំពុងមានសន្ទុះរីកចម្រើនយ៉ាងស្វាហាប់ ខណៈវិស័យហិរញ្ញវត្ថុ និងផលិតផលហិរញ្ញវត្ថុមិនមែនធនាគារថ្មីៗនឹងលេចចេញជារូបរាងបន្ថែមទៀតនាពេលអនាគត ជាពិសេសវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុដែលមិនទាន់មានក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតសម្រាប់កំណត់ការគ្រប់គ្រងនៅឡើយ។*

នៅក្នុងបរិបទនៃសកលភាវូបនីយកម្មសេវានិងផលិតផលហិរញ្ញវត្ថុថ្មីៗត្រូវបានបង្កើតឡើងជាច្រើនដោយបញ្ញត្តិករហិរញ្ញវត្ថុកម្ពុជា។ មុនពេលចេញច្បាប់នេះ ការគ្រប់គ្រង និងត្រួតពិនិត្យវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅកម្ពុជា ស្ថិតនៅក្រោមសមត្ថកិច្ចរបស់និយ័តករចំនួន២គឺ÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ្រប់គ្រងលើវិស័យធានារ៉ាប់រង និងសោធនឯកជន, វិស័យសន្តិសុខសង្គម, វិស័យបរធនបាលកិច្ច, វិស័យគណនេយ្យ និងសវនកម្ម, និងវិស័យអចលនវត្ថុ ព្រមទាំងវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន) និងគណៈកម្មការមូលបត្រកម្ពុជា (គ្រប់គ្រងលើវិស័យមូលបត្រ)។ ចំណែក ឯធនាគារជាតិនៃកម្ពុជាជាបញ្ញត្តិករវិស័យធនាគារ (គ្រប់គ្រងលើវិស័យធនាគារ)។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្តែងស្របតាមបរិបទនៃស្ថានភាពសកលភាវូបនីយកម្មសេវានិងផលិតផលហិរញ្ញវត្ថុថ្មីៗ របស់កម្ពុជា ហើយដោយយល់ឃើញពីសារៈសំខាន់ និងអត្ថប្រយោជន៍ នៃការច្របាច់បញ្ចូលគ្នាជានិយ័តករនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការបានផ្តួចផ្តើមគិតគូរអំពីការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ ជាមួយគ្នានោះ រាជរដ្ឋាភិបាលយល់ឃើញថារចនាសម្ព័ន្ធបញ្ញត្តិករនាពេលបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ជួបប្រទះនូវបញ្ហាប្រឈមធំៗ មួយចំនួនរួមមាន÷ ១). កង្វះប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យ ២). អសង្គតិភាពនៃការរៀបចំគោលនយោបាយ និងបទបញ្ញត្តិ ៣). ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ និង ៤). ការចំណាយ។

ឈរលើមូលដ្ឋានដ៏ចាំបាច់នេះ រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (សរសេរជាអក្សរកាត់ថា **អ. ស. ហ.**) ដើម្បីធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រង និងត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានជាអាទិ៍÷ វិស័យធានារ៉ាប់រង និងសោធនឯកជន, វិស័យមូលបត្រ, វិស័យសន្តិសុខសង្គម, វិស័យបរធនបាលកិច្ច, វិស័យគណនេយ្យ និងសវនកម្ម, វិស័យអចលនវត្ថុ និងបញ្ចាំ ព្រមទាំងប្រាតិភោគដោយអនុប្បទាន ក្នុងគោលបំណងពង្រឹង និងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅកម្ពុជា។

ច្បាប់នេះត្រូវបានរដ្ឋសភាអនុម័ត នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំលើកទី៥ នីតិកាលទី៦ និងព្រឹទ្ធសភាបានពិនិត្យ និងផ្តល់យោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៤ នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ស្របនឹងរដ្ឋធម្មនុញ្ញ។ ច្បាប់នេះក៏ត្រូវបានចូលរួមសិក្សា



*ការដាក់បញ្ចូលនិយ័តករវិស័យហិរញ្ញវត្ថុមិនមែនឱ្យស្ថិតនៅក្រោមបញ្ញត្តិករតែមួយ គឺមានសារៈសំខាន់ណាស់ក្នុងការធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យវិស័យទាំងនេះ ដើម្បីធានាបាននូវស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។*

ស្រាវជ្រាវតាមរយៈកម្មវិធីទស្សនកិច្ចសិក្សាអំពីបទពិសោធរបស់បណ្ដាប្រទេសនានាដូចជា÷ប្រទេសជប៉ុន, កូរ៉េ, ឥណ្ឌូនេស៊ី, និងថៃ និងតាមរយៈកិច្ចប្រជុំពិភាក្សាក្រុមការងារផ្ទៃក្នុងចំនួន២៥ លើក ព្រមទាំងកិច្ចប្រជុំអន្តរក្រសួងចំនួន១ លើក នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ និងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន១ លើក នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ដែលជាកិច្ចប្រជុំកម្រិតនយោបាយ។

អត្ថប្រយោជន៍ នៃការតាក់តែងច្បាប់






ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានជាអាទិ៍÷ ១).ឆ្លើយតបនឹងការវិវឌ្ឍនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារដែលទាមទារឱ្យមានការពង្រឹងយន្តការស្ថាប័ន, ២).បញ្ញត្តិករតែមួយអាចមើលឃើញពីទិដ្ឋភាពរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ជាពិសេសនៅពេលស្ថាប័នហិរញ្ញវត្ថុធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុ ទៅកាន់វិស័យហិរញ្ញវត្ថុផ្សេងៗទៀត អាចធានាបាននូវសង្គតិភាពនៃការដាក់ចេញបទប្បញ្ញត្តិ និងអាចកាត់បន្ថយភាពចន្លោះប្រហោងក្នុងបទបញ្ញត្តិ (Regulatory Arbitrage) ជាពិសេសបទប្បញ្ញត្តិសម្រាប់សេវាហិរញ្ញវត្ថុថ្មីៗ, ៣).បង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងវិស័យនីមួយៗ ដែលនឹងស្ថិតក្រោមស្ថាប័នតែមួយ តាមរយៈការបែងចែកព័ត៌មាន និងការសម្របសម្រួលក្នុងការចេញបទប្បញ្ញត្តិឆ្លងវិស័យ និង ៤).អាចកាត់បន្ថយចំណាយ (បុគ្គលិក, ពេលវេលា, សម្ភារៈ...) តាមរយៈការទាញយកអត្ថប្រយោជន៍ពីសហថាមភាព (Synergy) នៃការដាក់ស្ថាប័ននិយ័តករ ឱ្យស្ថិតនៅក្រោមបញ្ញត្តិករតែមួយ។ ដូច្នេះ ការដាក់បញ្ចូលនិយ័តករវិស័យហិរញ្ញវត្ថុមិនមែនធនាគារឱ្យស្ថិតនៅក្រោមបញ្ញត្តិករតែមួយ គឺមានសារៈសំខាន់ណាស់ក្នុងការធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យវិស័យទាំងនេះ ដើម្បីធានាបាននូវស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

រាជរដ្ឋាភិបាលរំពឹងទុកថាច្បាប់ និងយន្តការថ្មីនេះ នឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រឹង និងធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍នៃ អ.គ.ហ.*

# ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ២០២១-២០២៥

*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋនៅតាមបណ្តាក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នីតិបុគ្គលសាធារណៈ និងឯកជនដែលទទួលបានផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។*

ក្នុងតួនាទីជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាល លើកិច្ចការអធិការកិច្ចហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានអគ្គាធិការដ្ឋានជាសេនាធិការក្នុងការបំពេញបេសកកម្មត្រួតពិនិត្យលើអនុលោមភាព សមិទ្ធកម្ម នៃការគ្រប់គ្រង និងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋផ្អែកលើហានិភ័យ ករណីសង្ស័យ បណ្តឹងតវ៉ា និងបណ្តឹង បរិហារ ដើម្បីចូលរួមធានាការរក្សា




វិន័យហិរញ្ញវត្ថុសាធារណៈ ធានាការគោរព និងការអនុវត្តច្បាប់ និងលិខិត បទដ្ឋានគតិយុត្តពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ កំណត់អំពើបំពានហិរញ្ញវត្ថុសាធារណៈ បង្ការ និង/ ឬ ចាត់វិធានការចំពោះការប្រព្រឹត្តកំហុសដោយចេតនា ឬអចេតនាលើការគ្រប់គ្រង និង/ ឬការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីសម្រេចបានតាមចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានគ្រោងទុកនៃក្របខណ្ឌមុខងារ ភារកិច្ចអធិការកិច្ចហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាស្ថាប័នមានសិទ្ធិអំណាចស្របច្បាប់ ក្នុងការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើគ្រប់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងអង្គភាពទទួលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ បានរៀបចំ**ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុរយៈពេល ៥ឆ្នាំ (ឆ្នាំ២០២១-២០២៥)** និងត្រូវបានដាក់ឱ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈប្រកាសលេខ២០៥ សហវ.ប្រក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២១ ព្រមទាំងបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ឆាយ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូ (Video Conference)។ យុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ២០២១-២០២៥ ជាផែនការរយៈពេលមធ្យមរៀបចំឡើងដើម្បីកំណត់ទិសដៅយុទ្ធសាស្ត្រ និងជា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២០៥ សហវ.ប្រក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ២...

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ... តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/០១០ ចុះថ្ងៃទី១២ ... ដាក់ឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- ព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ... ប្រើច្បាប់ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យស...
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ... ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ... ដាក់ឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែ... ឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ... ដាក់ឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស...
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ... ប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ... ដាក់ឱ្យប្រើច្បាប់ស្តីពីសម្បទាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមី... ប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ... ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ផែនទីចង្អុលផ្លូវក្នុងការចូលរួមគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" និងដំណាក់កាលអន្តរកាលទី៣ បូក២ ដោយគ្រោងបញ្ចប់នៅឆ្នាំ២០២២ នេះ និងដំណាក់កាលទី៤ គឺ "**គណនេយ្យភាពសមិទ្ធកម្ម**" ដែលគ្រោងចាប់ពីឆ្នាំ២០២៣ ដល់២០២៧ ព្រមទាំងរួមចំណែកក្នុងការអនុវត្តនូវ**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥** ដែលប្រែក្លាយពី "ប្រព័ន្ធថវិកាផ្អែកលើធាតុចូលនិងមជ្ឈការ" ទៅជា "ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ" ព្រមទាំងជួយឱ្យសម្រេចផងដែរនូវគោលបំណងគោលនយោបាយទី២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ ពង្រឹងនិងបង្កើនស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋក្នុងកម្មវិធីទី៤ "ការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" អនុកម្មវិធីទី៤.៨ "ការគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុ"។

ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ ឆ្នាំ២០២១-២០២៥ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹង និងលើកកម្ពស់សមត្ថភាពស្ថាប័ន ការធ្វើទំនើបកម្មប្រព័ន្ធ និងយន្តការអធិការកិច្ចហិរញ្ញវត្ថុ អភិវឌ្ឍសមត្ថភាពធនធានមនុស្ស ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន និងប្រតិបត្តិការការងារអធិការកិច្ចហិរញ្ញវត្ថុមានលក្ខណៈស្តង់ដាវិជ្ជាជីវៈ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈតាមរយៈទិសដៅយុទ្ធសាស្ត្រចំនួន ៤ រួមមាន៖

★ **យុទ្ធសាស្ត្រទី១៖** *លើកកម្ពស់ការអភិវឌ្ឍក្របខណ្ឌការងារអធិការកិច្ចហិរញ្ញវត្ថុ*

★ **យុទ្ធសាស្ត្រទី២៖** *ពង្រឹងការអភិវឌ្ឍផែនការសកម្មភាព និងលើកកម្ពស់មុខងារភារកិច្ចអធិការកិច្ចហិរញ្ញវត្ថុ*

★ **យុទ្ធសាស្ត្រទី៣៖** *លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពមន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ*

★ **យុទ្ធសាស្ត្រទី៤៖** *ពង្រឹងការរៀបចំប្រព័ន្ធការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន។*


០២១-២០២៥
កញ្ញា ឆ្នាំ២០១៨ ស្តីពីការ
សីហា ឆ្នាំ២០១៩ ដែល
២០២០ ដែលប្រកាសឱ្យ
ថុនា ឆ្នាំ២០១៨ ដែល
សីហា ឆ្នាំ២០១៩ ដែល
ករា ឆ្នាំ២០១២ ដែលដាក់
ថុនា ឆ្នាំ២០១១ ដែល
ឧសភា ឆ្នាំ២០០៨ ដែល
តុលា ឆ្នាំ២០០៧ ដែល
ឆ្នាំ២០០១ ដែលដាក់ឱ្យ
មករា ឆ្នាំ១៩៩៦ ដែល
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666


- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ ដែលដាក់ឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៦៨អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៩៧១ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**សម្រេច**

**ប្រការ ១.-**
ដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ២០២១-២០២៥ដែលមានខ្លឹមសារ និងឧបសម្ព័ន្ធដូចមានភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**
គ្រប់មន្ត្រីរាជការក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យានៃអគ្គាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តដោយអនុលោមតាមផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ ឆ្នាំ២០២១-២០២៥ ដែលមានបញ្ជាក់ក្នុងប្រការ១ នៃប្រកាសនេះ។

**ប្រការ ៣.-**
នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២១
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ១.លើកកម្ពស់ការអភិវឌ្ឍក្របខណ្ឌការងារអធិការកិច្ចហិរញ្ញវត្ថុ

ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការងារ ការពង្រឹងក្របខណ្ឌការងារគឺជាកិច្ចការចាំបាច់សម្រាប់អគ្គាធិការដ្ឋានក្នុងការចូលរួមចំណែកអនុវត្ត ឱ្យសម្រេចបានតាមគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសំដៅ៖ ❶.បន្តលើកកម្ពស់ការពង្រឹងសមត្ថភាពការគ្រប់គ្រងក្របខណ្ឌការងារអធិការកិច្ចហិរញ្ញវត្ថុ, ❷.ពង្រឹងគុណភាពសេវាគាំទ្រទូទៅ ដំណើរការកិច្ចការរដ្ឋបាល បុគ្គលិក និងប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ, ❸.ពង្រឹងរៀបចំកែលម្អនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ, ❹.ពង្រឹងប្រសិទ្ធភាពយន្តការការងារអធិការកិច្ចហិរញ្ញវត្ថុ និង❺.រៀបចំកំណត់ក្របខណ្ឌប្រព័ន្ធអធិការកិច្ច និងសវនកម្មរបស់ក្រសួង-ស្ថាប័ន ឱ្យបានច្បាស់លាស់ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន អង្គភាពដែលពាក់ព័ន្ធកិច្ចការត្រួតពិនិត្យ អធិការកិច្ច សវនកម្ម

ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជឿទុកចិត្តបាននៃការងារអធិការកិច្ចហិរញ្ញវត្ថុ។

### ២.ពង្រឹងការអភិវឌ្ឍផែនការសកម្មភាព និងលើកកម្ពស់មុខងារ ភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ

ផែនការសកម្មភាពអធិការកិច្ចហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងសម្រាប់ជាផែនទីចង្អុលផ្លូវដល់ការងារ អធិការកិច្ច ហិរញ្ញវត្ថុក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានលក្ខណៈបត់បែនទៅតាមឆ្នាំនីមួយៗ ដូចនេះផែនការសកម្មភាពត្រូវមានភាពគ្រប់ជ្រុងជ្រោយ បង្ហាញអំពីសកម្មភាព សូចនាករ សមិទ្ធកម្មគន្លឹះ ពេលវេលាសម្រាប់តាមដាន ការអនុវត្ត ត្រួតពិនិត្យលទ្ធផលនៃប្រតិបត្តិការ ផ្អែកលើបេសកកម្មភារកិច្ច និងវិសាលភាពនៃប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាវិនិយោគឆ្នាំ២០១៩-២០២៥។

### ៣.លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពមន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ

ការកសាងអភិវឌ្ឍធនធានមនុស្ស គឺជាសកម្មភាពវិនិយោគដែលមានលក្ខណៈជាយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍបន្ថែមនូវសមត្ថភាពរបស់មន្ត្រីអគ្គាធិការដ្ឋាន ក្នុងការបំពេញមុខងារ និងតួនាទីរបស់ខ្លួនប្រកបដោយគុណភាព និងវិជ្ជាជីវៈខ្ពស់។ ការអភិវឌ្ឍ

*ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ ឆ្នាំ២០២១-២០២៥ គឺជាត្រីវិស័យសម្រាប់ចង្អុលទិស ជាយុទ្ធសាស្ត្ររយៈពេលមធ្យម ក្នុងការអនុវត្តផែនការសកម្មភាពរបស់អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព តម្លាភាព និងភាពជឿទុកចិត្តបានលើប្រតិបត្តិការការងារអធិការកិច្ចហិរញ្ញវត្ថុ។*

ធនធានមនុស្ស គឺជាការទទួលខុសត្រូវរួមគ្នារបស់មន្ត្រីរាជការម្នាក់ៗ អ្នកគ្រប់គ្រង និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់។ សកម្មភាពនេះ ត្រូវអនុញ្ញាតឱ្យមានការចូលរួម និងផ្តោតលើលទ្ធផលដែលអាចត្រួតពិនិត្យបាន និងមានលក្ខណៈចីរភាព។ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស ត្រូវមានលក្ខណៈសមស្រប សន្សំសំចៃ ទន់ភ្លន់ និងឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព របស់អគ្គាធិការដ្ឋាន ក្នុងទិសដៅពង្រឹង និងអភិវឌ្ឍសមត្ថភាពស្ថាប័នដោយ ❶.ធ្វើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងអគ្គាធិការដ្ឋាន ❷.អភិវឌ្ឍជំនាញអធិការកិច្ចហិរញ្ញវត្ថុសាធារណៈឆ្លើយតបនឹងការវិវឌ្ឍសេដ្ឋកិច្ចជាតិ។ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រខាងលើ អគ្គាធិការដ្ឋានកំណត់នូវសកម្មភាពដូចខាងជា÷ ១.លើកកម្ពស់គុណភាពបណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈ, ២.ការកំណត់គោលការណ៍ ដើម្បីធានាឱ្យមន្ត្រីបំពេញការងារអស់លទ្ធភាព និង៣. ទំនើបកម្មកិច្ចសហប្រតិបត្តិការ និងការផ្សព្វផ្សាយ។

### ៤.ពង្រឹងការរៀបចំប្រព័ន្ធការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន

ដើម្បីរួមចំណែកបង្កើននូវគណនេយ្យភាពចំពោះសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាគោលបំណងក្នុងដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដែលនឹងត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០២៧ និងគោលដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ គឺប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីមជ្ឈការផ្តោតលើធាតុចូលទៅជាវិមជ្ឈការផ្តោតលើធាតុចេញ ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS) ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការជួយគាំទ្រ ពន្លឿន និងជំរុញគណនេយ្យភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ក្រសួង- ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាជនកម្ពុជាទូទាំងប្រទេស។

ជារួមផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ២០២១-២០២៥នេះ គឺជាត្រីវិស័យសម្រាប់ចង្អុលទិស ជាយុទ្ធសាស្ត្ររយៈពេលមធ្យមក្នុងការអនុវត្តផែនការសកម្មភាពរបស់អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព តម្លាភាព និងភាពជឿទុកចិត្តបានលើប្រតិបត្តិការការងារអធិការកិច្ចហិរញ្ញវត្ថុ។ ទន្ទឹមនេះ អគ្គាធិការដ្ឋាន ក្នុងនាមជាសេនាធិការបច្ចេកទេសឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានលើកឡើងខាងលើ ជាពិសេសបន្តអនុវត្តឱ្យមានប្រសិទ្ធភាពកម្មវិធីកែទម្រង់ស៊ីជម្រៅ លើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៥យ៉ាង “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**”៕■

*រៀបចំដោយ÷ អគ្គាធិការដ្ឋាន និង ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍នៃ អ.គ.ហ.*

# សមិទ្ធផលកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាអាទិភាពនៃការអនុវត្ត* ***យុទ្ធសាស្ត្រចតុកោណ*** *នៅគ្រប់ដំណាក់កាល ពិសេសបានក្លាយជាអាទិភាពទី១ នៅក្នុងដំណាក់កាលទី៣ និងទី៤ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការ និងការទទួលខុសត្រូវជាដើម សម្រាប់រួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ និងលើកកម្ពស់កម្រិតជីវភាពជូនប្រជាពលរដ្ឋ។*

ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល៣ បូក២ ដែលជាចំណុចរបត់ដ៏សំខាន់ និងស្មុគស្មាញដោយភាពជាម្ចាស់ និងការទទួលខុសត្រូវភាគច្រើនលើការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានផ្ទេរទៅកាន់ក្រសួង-ស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រការនេះ តម្រូវឱ្យគ្រប់ក្រសួង-ស្ថាប័ន ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាព និងជំនាញវិជ្ជាជីវៈជូនមន្ត្រីរាជការរបស់ខ្លួន។ ក្នុងន័យនេះ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការដឹកនាំ និងណែនាំអនុវត្តផ្ទាល់ពី ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាព,ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការលើមុខងារបណ្តុះបណ្តាល និងវិក្រឹតការបានយកចិត្តទុកដាក់ជានិច្ច លើការកសាង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ក្នុងគោលដៅលើកកម្ពស់ឆន្ទៈ សមត្ថភាពជំនាញ និងជំរុញការចូលរួម និងការត្រៀមលក្ខណសម្បត្តិ ដើម្បីសម្រេចគោលដៅ របស់អង្គភាពការងារ សំដៅរួមចំណែកគាំទ្រនិងអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។



ក្នុងន័យនេះ កន្លងមក ការងារកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ លើជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេចបានសមិទ្ធផល សំខាន់ៗ ដូចខាងក្រោម៖

### ១.ការរៀបចំផែនការយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសមត្ថភាពបច្ចុប្បន្នកម្ម

ស្របទៅនឹងដំណាក់កាលផ្លាស់ប្តូរនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការធ្វើបច្ចុប្បន្នកម្ម ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ត្រូវបានរៀបចំឡើង ដើម្បីកំណត់ទិសដៅ និងសម្រាប់ជាផែនទីចង្អុលផ្លូវលើការអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និងកោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និងមនសិការ ជូនមន្ត្រីរាជការក្នុងមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបំពេញតួនាទី ភារកិច្ច ប្រកបដោយ ឆន្ទៈ ស្មារតីទទួលខុសត្រូវ និងភាពម្ចាស់ការសម្រាប់រួមចំណែកសម្រេចគោលដៅ ពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង ការកសាងគណនេយ្យភាពចំពោះសមិទ្ធកម្ម តាមរយៈការពង្រឹងពង្រីកការស្រាវជ្រាវ អភិវឌ្ឍ និងអនុវត្តការបណ្តុះបណ្តាលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ

លើជំនាញពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ដំណាក់កាល៣ ប្លុក២ និងដំណាក់កាលទី៤។ ការរៀបចំផែនការយុទ្ធសាស្ត្រនេះ ត្រូវបានធ្វើឡើង ស្របតាមវិធីសាស្ត្រ បច្ចេកទេស ដោយមានការវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ដំណាក់កាលទី៣, ការចុះសិក្សាអំពីតម្រូវការបណ្តុះបណ្តាលនៅតាមអគ្គនាយកដ្ឋានជំនាញ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងមន្ទីរអង្គភាពជំនាញក្រោមឱវាទ ព្រមទាំងដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ, ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងការប្រជុំចង្អៀតលើទិដ្ឋភាពបច្ចេកទេស ជាមួយ **អ.គ.ហ.** និងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាបានភាពគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពទាំងពេលវេលា សមត្ថភាពជំនាញ និងធនធាន លើការកសាង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ សម្រាប់ចូលរួមគាំទ្រ និងអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព និងចីរភាព។

## ២.ការពង្រឹង និងពង្រីកកិច្ចសហការជាមួយដៃគូជាតិ-អន្តរជាតិ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាសេនាធិការបច្ចេកទេសលើមុខងារបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពក៏ទទួលបានលទ្ធផលល្អប្រសើរក្នុងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអន្តរជាតិ ដូចជាវិទ្យាស្ថានហិរញ្ញវត្ថុ និងអភិវឌ្ឍអាស៊ី-ប៉ាស៊ីហ្វិក (AFDI) នៃទីក្រុងសៀងហៃ ប្រទេសចិន, សកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង (NTU), សាលារដ្ឋបាលសាធារណៈ (CSC) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) នៃប្រទេសសិង្ហបុរីជាដើម លើសកម្មភាពបណ្តុះបណ្តាល និងវិក្រឹតការជូនមន្ត្រីរាជការ របស់ក្រសួង-ស្ថាប័ន និងមន្ទីរអង្គភាពពាក់ព័ន្ធនៃរាជធានី-ខេត្ត ដើម្បីបង្កើនសមត្ថភាព ការយល់ដឹង និងដកស្រង់បទពិសោធន៍ លើការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយសាធារណៈសំខាន់ៗដូចជា រដ្ឋបាលសាធារណៈ អភិបាលកិច្ច និងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈជាដើម។ ក្នុងឆ្នាំ២០២១ នេះ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលារដ្ឋបាលសាធារណៈ (CSC) របស់ប្រទេសសិង្ហបុរីបានសហការ និងរៀបចំវគ្គបណ្តុះបណ្តាលពីចម្ងាយដើម្បីពង្រឹងសមត្ថភាពទេពកោសល្យជូនគ្រូបង្គោល និងគ្រូឧទ្ទេសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើប្រធានបទសំខាន់ៗរួមមាន: ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល, ជំនាញសម្របសម្រួលឱ្យប្រកបដោយប្រសិទ្ធភាព និងការបណ្តុះបណ្តាលជំនាញគរុកោសល្យ ដែលចែករំលែកដោយសាស្ត្រាចារ្យ ប្រកបដោយបទពិសោធរបស់សាលារដ្ឋបាលសាធារណៈ ប្រទេសសិង្ហបុរី។ ជាមួយនេះ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលារដ្ឋបាលសាធារណៈ ប្រទេសសិង្ហបុរីបានសហការរៀបចំសិក្ខាសាលាពីចម្ងាយចែករំលែកបទពិសោធពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាជាតិ និងអភិបាលកិច្ចល្អជូនថ្នាក់ដឹកនាំ ដែលជារដ្ឋលេខាធិការ អគ្គនាយក និងប្រធាននាយកដ្ឋាន សរុបប្រមាណជា ២២០នាក់ (ស្ត្រីចំនួន ៤៨នាក់)ដែលមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន ដោយមានការចូលរួមធ្វើបទឧទ្ទេសដោយសាស្ត្រាចារ្យ ប្រកបដោយបទពិសោធមកពីសាលារដ្ឋបាលសាធារណៈ ប្រទេសសិង្ហបុរី ព្រមទាំងថ្នាក់ដឹកនាំជំនាញមកពីអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងវិទ្យាស្ថានហិរញ្ញវត្ថុ និងអភិវឌ្ឍអាស៊ីប៉ា-ស៊ីហ្វិច (AFDI) នៃទីក្រុងសៀងហៃ ប្រទេសចិនបានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជូនដល់ថ្នាក់ដឹកនាំកម្រិតអគ្គនាយកដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងគ្រប់ក្រសួង-ស្ថាប័នចំនួន៥៩នាក់ (ស្ត្រី ១០នាក់)។


ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ៣.ការកសាង និងការអភិវឌ្ឍជំនាញបច្ចេកទេស រយៈពេលមធ្យមកម្រិតវិញ្ញាបនបត្រ (Certificate Program)

ក្នុងគោលដៅកសាងនូវប្រព័ន្ធបណ្តុះបណ្តាលដែលមានលក្ខណៈប្រមូលផ្តុំ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ សំដៅធានាគុណភាព ប្រសិទ្ធភាព និងមានលក្ខណៈ

*ការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ត្រូវបានរៀបចំឡើងដើម្បីកំណត់ទិសដៅ និងសម្រាប់ជាផែនទីចង្អុលផ្លូវលើការអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈ និងកោសល្យឯកទេស ប្រកបដោយគុណភាព នវានុវត្តន៍ និងមនសិការ ជូនមន្ត្រីរាជការក្នុងមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

វិជ្ជាជីវៈស៊ីជម្រៅ សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកសាងប្រព័ន្ធកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេក-ទេស រយៈពេលមធ្យមកម្រិតវិញ្ញាបនបត្រ (Certificate Program) ផ្សារភ្ជាប់នឹងមុខតំណែង របស់មន្ត្រីដែលត្រូវតែងតាំង ឬ ប្រគល់ភារកិច្ចក្នុងមុខងារ ទទួលបន្ទុកពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




ដែលមានសារៈសំខាន់ជាសារវន្ត។ ប្រព័ន្ធកម្មវិធីបណ្តុះបណ្តាលនេះ បានកំណត់យន្តការកាន់តែមុតមាំទាំងលើសមត្ថភាពស្ថាប័ន សិក្ខាកាមគោលដៅ គ្រូបង្គោលមុខវិជ្ជាសិក្សា ចំនួនម៉ោងសិក្សា វិន័យ-សិក្សា ការវាយតម្លៃ និងលទ្ធផលសិក្សាជាដើម។ ប្រព័ន្ធកម្មវិធីបណ្តុះបណ្តាលនេះនឹងត្រូវបន្តអនុវត្ត និងអភិវឌ្ឍបន្ថែមទៀតដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ផ្សារភ្ជាប់មុខងារ តួនាទី ភារកិច្ច ទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅនឹងកម្រិតក្របខណ្ឌសមត្ថភាពជំនាញវិជ្ជាជីវៈជាក់លាក់ ដែលបច្ចុប្បន្ននេះ វិទ្យាស្ថានកំពុងតែរៀបចំទស្សនាទានស្តីពីការកំណត់គុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីកំណត់លក្ខណវិនិច្ឆ័យ សម្រាប់ការជ្រើសរើសសិក្ខាកាមគោលដៅ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសស្របតាមលក្ខខណ្ឌបច្ចេកទេស នៃក្របខណ្ឌសមត្ថភាព ជំនាញការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរៀបចំលិខិតបទដ្ឋានគតិយុត្តឱ្យបានសម្រេចយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០២១ នេះ។ ក្នុងឆ្នាំ២០១៩-២០២០ កន្លងទៅនេះ ការបណ្តុះបណ្តាលតាមកម្មវិធីជំនាញបច្ចេក-ទេសនេះ សម្រេចបានសិក្ខាកាមដែលប្រឡងបញ្ចប់ការសិក្សាដោយប្រឡងជាប់ជោគជ័យជាស្ថាពរប្រមាណជា៨៣% នៃសិក្ខាកាមសរុប ១៣៦០នាក់ ហើយវិទ្យា-ស្ថានកំពុងបន្តខិតខំប្រឹងប្រែងបំពេញបេ-សកកម្មរបស់ខ្លួន ដោយពង្រឹងសមត្ថភាពលើការបណ្តុះបណ្តាលពីចម្ងាយ តាមប្រព័ន្ធអនឡាញដែលជាវិធីសាស្ត្រថ្មីនៃការកសាង និងអភិវឌ្ឍសមត្ថភាព នៅក្នុងបរិបទឌីជី-ថល និងការគំរាមពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩៕■

*រៀបចំដោយ៖ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើកទី៣ ឆ្នាំ២០២១

*ចាប់តាំងពីឆ្នាំ២០០៤ មក, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) បាននិងកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបដិបត្តិតាមអភិក្រមជាខឿន ដើម្បីកសាង និងកែលម្អសមាសធាតុជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ឱ្យមានសមត្ថភាពគាំទ្រកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល តាមរយៈការធានាឱ្យបាននូវប្លូរណភាពនៃវិន័យថវិកា ប្រសិទ្ធភាពនៃថវិកាទាំងក្នុងផ្នែកវិភាជន៍និងផ្នែកប្រតិបត្តិ និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។*

ផ្អែកតាមគោលបំណងនេះ, **គ.ហ.ស.** បានអនុម័តនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ដើម្បីអភិវឌ្ឍប្រព័ន្ធ ក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស សម្រាប់គាំទ្រដល់មុខងារព្រមទាំងដំណើរការ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសនៅកម្រិតប្រតិបត្តិការតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត។ ដើម្បីបន្សីគោលដៅ និងសកម្មភាពកែទម្រង់ឱ្យមានសង្គតិភាព និងឆ្លើយតបទៅនឹងស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) តែងតែប្រើប្រាស់ក្របខណ្ឌ ព្រមទាំងឧបករណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ក្នុងការពិនិត្យបម្រែបម្រួល នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។




ដ្យាក្រាមទី១÷ អភិក្រមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

PEFA ត្រូវបានប្រើប្រាស់នៅតាមបណ្តាប្រទេសជាច្រើនលើសកលលោក ដើម្បីវាយតម្លៃ និងរាយការណ៍ភាពខ្លាំង និងភាពខ្សោយ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការវាស់វែងសូចនាករសមិទ្ធកម្មជាតួលេខ ដែលសម្គាល់ពីកម្រិតអនុលោមភាពរបស់សមាសធាតុ និងដំណើរការនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ធៀបនឹងឧត្តមានុវត្តន៍អន្តរជាតិ។ លទ្ធផលនៃការវាយតម្លៃ PEFA ត្រូវបានយកទៅពិនិត្យជាមូលដ្ឋានសម្រាប់ធ្វើផែនការកែទម្រង់, ពិភាក្សាពីយុទ្ធសាស្ត្រនិងអាទិភាពនៃការកែទម្រង់, និងវិភាគពីវឌ្ឍនភាពនៃការកែទម្រង់។ PEFA មានសសរស្តម្ភ (Pillar) ចំនួន៧ដែលតំណាងឱ្យសមាសធាតុសំខាន់នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សសរស្តម្ភនីមួយៗមានសូចនាករសមិទ្ធកម្ម (Performance Indicators) និងអនុ-

សូចនាករសមិទ្ធកម្ម (Dimensions) មួយចំនួន ដែលសរុបមានចំនួន**៣១** សូចនាករសមិទ្ធកម្ម និង**៩៤** អនុសូចនាករសមិទ្ធកម្ម។ ការដាក់ពិន្ទុលើអនុសូចនាករសមិទ្ធកម្មនីមួយៗត្រូវផ្អែកតាមសក្ខីកម្មនិងវិធីសាស្ត្រតឹងរឹង ដែលសុទ្ធសឹងទាមទារការយកចិត្តទុកដាក់ និងពិនិត្យសុពលភាពយ៉ាងល្អិតល្អន់។

ក្នុងឆ្នាំ២០២០ កន្លងទៅ **អ.គ.ហ.** បានសហការជាមួយប្រតិភូសហភាពអឺរ៉ុប ដោយមានគាំទ្រពីជំនាញការអន្តរជាតិចំនួន ២ រូប គឺលោក Phil Sinnett ដែលជាអតីតប្រធានលេខាធិការដ្ឋាន PEFA និងលោកស្រី Sylvie Zaitra Beck ជាជំនាញការ PEFA ហើយបានបញ្ចប់ការរៀបចំ PEFA (លើកទី៣) ព្រមទាំងទទួលបានការត្រួតពិនិត្យគុណភាពពីលេខាធិការដ្ឋាន PEFA ហៅថាកាត់ថា PEFA Check នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអនុម័តនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១។ កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដឹកនាំធ្វើការវាយតម្លៃ ២ដងរួចមកហើយ គឺលើកទី១ នៅឆ្នាំ២០១០ និងលើកទី២ នៅឆ្នាំ២០១៥។

ការវាយតម្លៃ PEFA (លើកទី៣) នេះតម្រូវឱ្យមានការប្រើប្រាស់ក្របខណ្ឌវាយតម្លៃ ដែលមានជាធរមាន គឺក្របខណ្ឌឆ្នាំ២០១១ និងក្របខណ្ឌកែសម្រួលថ្មីឆ្នាំ២០១៦។ ការប្រើប្រាស់ក្របខណ្ឌវាយតម្លៃឆ្នាំ២០១១ មានគោលបំណងធានាសង្គតិភាពនៃការឆ្លុះបញ្ចាំងពីបម្រែបម្រួលនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដោយប្រៀបធៀបបម្រែបម្រួល នៃពិន្ទុសម្រាប់ការវាយតម្លៃនាឆ្នាំ២០១០, ២០១៥ និងឆ្នាំ២០២០។ ដោយឡែក ការប្រើប្រាស់ក្របខណ្ឌវាយតម្លៃឆ្នាំ២០១៦ គឺជាការធ្វើបច្ចុប្បន្នកម្មនៃការវាយតម្លៃឱ្យស្របទៅនឹងឧត្តមានុវត្តន៍ ហើយក៏បង្កើតជាបន្ទាត់គោលថ្មី សម្រាប់ប្រៀបធៀបទៅនឹងការវាយតម្លៃនាពេលអនាគត។




ដ្យាក្រាមទី២÷ សសរស្តម្ភនៃក្របខណ្ឌនិងឧបករណ៍វាយតម្លៃ PEFA

## ១.លទ្ធផល និងការប្រៀបធៀបលទ្ធផលនៃការវាយតម្លៃ PEFA លើកទី៣ ដោយប្រើប្រាស់ក្របខណ្ឌឆ្នាំ២០១១

ក្របខណ្ឌ PEFA ឆ្នាំ២០១១ ត្រូវបានប្រើប្រាស់សម្រាប់ប្រៀបធៀបវឌ្ឍនភាពនៃការវាយតម្លៃ PEFA កន្លងមកពោលគឺរវាងលទ្ធផលនៃការវាយតម្លៃ PEFA ក្នុងឆ្នាំ២០១៥ និងឆ្នាំ២០២១។ ដូចមានបង្ហាញក្នុងតារាងទី១, លទ្ធផលនៃការវាយតម្លៃនិងការប្រៀបធៀបបានឱ្យដឹងថា÷ សូចនាករសមិទ្ធកម្ម PEFA (ដែលហៅកាត់ PI) ចំនួន៩ រួមមាន PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI-19, PI-23 និង PI-25 ទទួលបានពិន្ទុខ្ពស់ជាងមុន។ ដោយឡែកសូចនាករលទ្ធផលនៃការប្រមូលចំណូល (PI-3) ទទួលបានពិន្ទុទាបជាងការវាយតម្លៃលើកទី២ (ពីពិន្ទុ A មកពិន្ទុ D) ដោយហេតុថាការអនុវត្តចំណូលក្នុងឆ្នាំ២០១៧-២០១៩ មានទំហំធំជាង ១៥% ធៀបនឹងច្បាប់ថវិកា។ គម្លាត ១៥% រវាងទំហំនៃការអនុវត្តធៀបនឹងច្បាប់នេះពុំឆ្លុះបញ្ចាំងពីឧត្តមានុវត្តន៍នៃក្របខណ្ឌវាយតម្លៃ PEFA ហេតុនេះទើបទទួលបានពិន្ទុទាប។ ទោះជាយ៉ាងនេះក្តី ការអនុវត្តចំណូលកើនឡើងខ្ពស់ជាងការព្យាករក្នុងច្បាប់ថវិកា បង្ហាញពីប្រសិទ្ធភាព នៃការអនុវត្តការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣, ហើយក៏បានរួមចំណែកដល់រាជរដ្ឋាភិបាលក្នុងការសន្សំឥណទាន ដើម្បីប្រើប្រាស់សម្រាប់ហេតុការណ៍កើតឡើងជាយថាហេតុ ជាក់ស្តែងការទប់ស្កាត់ជំងឺកូវីដ-១៩ ជាដើម។

**តារាងទី១÷ សង្ខេបតាម PI ដែលកើនឡើងពិន្ទុ ដោយប្រើប្រាស់ក្របខណ្ឌឆ្នាំ២០១១**

| សូចនាករ PEFA (PEFA Indicators) | ពិន្ទុ 2015 | ពិន្ទុ 2020 | សមាសភាព (Dimensions) |
|---|---|---|---|
| PI-2: សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | D | B+ | គម្លាតការអនុវត្តថវិកាធៀបនឹងច្បាប់ថវិកាតាមក្រសួង-ស្ថាប័នមានកម្រិតទាបជាង ១0% ក្នុងរយៈពេលបីឆ្នាំចុងក្រោយ (ពោលគឺ ៣,៨% ក្នុងឆ្នាំ២០១៧, ៨,៨% ក្នុងឆ្នាំ២០១៨ និង ៥,៧% ក្នុងឆ្នាំ២០២០ ។ ជាមួយគ្នានេះ ទំហំចំណាយមិនបានគ្រោងទុកក្នុងឆ្នាំ ២០១៧-២០១៩ សម្រេចបានជាមធ្យម 0,៥១% ធៀបនឹងច្បាប់ថវិកានៃឆ្នាំនីមួយៗ ។ |
| PI-6: ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | C | B | សមាសធាតុចំនួន ៦ ក្នុងចំណោម ៩ នៃឯកសារថវិកា រួមមានការសន្មតម៉ាក្រូសេដ្ឋកិច្ច, ឱនភាពថវិកា, ហិរញ្ញប្បទានសម្រាប់ឱនភាព, លទ្ធផលការអនុវត្តថវិកាឆ្នាំមុន (N-1), ឆ្នាំថវិកា (N) និងការសង្ខេបទិន្នន័យថវិកាតាមចំណាត់ថ្នាក់រដ្ឋបាល គឺមានបង្ហាញក្នុងសេចក្តីព្រាងច្បាប់ថវិកាឆ្នាំដែលបានបញ្ជូនទៅរដ្ឋសភា ។ |
| PI-7: ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | C | B | កម្រិតចំណាយនៅក្រៅរបាយការណ៍ហិរញ្ញវត្ថុ (ច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំ) មានកម្រិតទាបធៀបនឹងថវិការដ្ឋបាលថ្នាក់ កណ្តាល ។ ទន្ទឹមនោះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនីតិវិធីថ្មីសម្រាប់គ្រប់គ្រងគ្រឹះស្ថានសាធារណរដ្ឋបាល។ |
| PI-10: លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | D | B | លទ្ធភាពទទួលបានព័ត៌មានថវិកាមានការកើនឡើង ដោយសារ សាធារណជនអាចពិនិត្យឯកសារថវិកាទាន់ពេលវេលារួមមាន របាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ, ការទទួលបានព័ត៌មានពាក់ព័ន្ធលទ្ធកម្មសាធារណៈពាក់ព័ន្ធនឹងការប្រគល់កិច្ចសន្យាលទ្ធកម្ម និងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ។ |
| PI-13: តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | C+ | B | ការកើនឡើងពិន្ទុលើការផ្តល់សេវាពន្ធប្រសើរជាងមុន និងការផ្តល់ព័ត៌មានទៅសាធាណជនមានភាពទំលំទូលាយ រួមទាំងការបង្វិលសង VAT និងការបង្កើតគណៈកម្មាធិការដោះស្រាយវិវាទពន្ធដារ ។ |
| PI-14: ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ | D+ | C+ | អគ្គនាយកដ្ឋានពន្ធដារបានកែលម្អនីតិវិធីការងារ, ប្រព័ន្ធចុះបញ្ជី និងបង្កើតលក្ខខណ្ឌវិនិច្ឆ័យហានិភ័យ ។ |
| PI-19: តម្លាភាពការប្រកួត-ប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | D | C+ | កសហវ. បានបំពេញនូវលក្ខខណ្ឌ PEFA ចំនួន៥, ផ្សព្វផ្សាយឯកសារលទ្ធកម្មសាធារណៈចំនួន៤ និងបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មសាធារណៈ អនុលោមតាមអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ។ |
| PI-23: អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | D | B | ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុជា Excel Spreadsheet (សម្រាប់រៀបចំផែនការថវិកានិងការអនុវត្តថវិកា) នៅតាមសាលារៀន រីឯក្រសួងសុខាភិបាលក៏មានប្រព័ន្ធកត់ត្រាតាមដានមន្ទីរពេទ្យកម្រិតមួយ, កម្រិតពីរ និងកម្រិតបី ។ |
| PI-25: គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | D+ | C+ | ក្រុមប្រឹក្សាជាតិគណនេយ្យបានរៀបចំ និងដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ ។ ជាមួយគ្នានេះ កម្រិតអនុលោមភាពរបាយការណ៍ IPSAS ត្រូវបានកើនឡើង ។ |

ទន្ទឹមនោះ PI-11 ទទួលពិន្ទុទាបផងដែរ ដោយសារកង្វះព័ត៌មានមួយចំនួននៅក្នុងឆ្នាំ២០១៥។ ចំណែកឯសូចនាករ ដែលជាសមត្ថកិច្ច របស់អាជ្ញាធរសវនកម្មជាតិ (PI-26) មិនត្រូវបានវាយតម្លៃជាពិន្ទុទេ ដែលនាំឱ្យ PI-27 និង PI-28 ពាក់ព័ន្ធនឹង

សមត្ថកិច្ចរបស់ស្ថាប័ននីតិប្បញ្ញត្តិពិនិត្យលើរបាយការណ៍សវនកម្មឯករាជ្យ គឺមិនអាចវាយតម្លៃបានផងដែរ។ ជាចុងក្រោយ សូចនាករដែលពាក់ព័ន្ធនឹងដៃគូអភិវឌ្ឍន៍ (D1-D3) ពុំទាន់មានភាពចាំបាច់ក្នុងកិច្ចការកែទម្រង់នៅឡើយ។

ជាការសន្និដ្ឋានផ្អែកតាមក្របខណ្ឌវាយតម្លៃឆ្នាំ២០១១ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ គឺមានទិសដៅច្បាស់លាស់ និងជវភាពទាំងទិដ្ឋភាពនៃការគ្រប់គ្រងចំណាយថវិកា និងចំណូលថវិកាមានភាពកាន់តែប្រសើរឡើងជាលំដាប់។ ការកែទម្រង់ប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវការពេលវេលាបន្ថែម និងការចូលរួមគ្រប់តួអង្គពាក់ព័ន្ធ ប្រកបដោយបុរេសកម្ម និងអន្តរសកម្ម។

## ២.លទ្ធផលនៃការវាយតម្លៃ PEFA លើកទី៣ ដោយប្រើប្រាស់ក្របខណ្ឌឆ្នាំ២០១៦

សម្រាប់ការប្រើប្រាស់ក្របខណ្ឌវាយតម្លៃឆ្នាំ២០១៦, លទ្ធផលនៃការវាយតម្លៃ PEFA (លើកទី៣)នេះ បង្ហាញនូវពិន្ទុ ដូចមានបង្ហាញក្នុងតារាងទី២។ ពិន្ទុនេះអាចត្រូវបានបកស្រាយ ដូចតទៅ÷

តារាងទី២÷ លទ្ធផលនៃការដាក់ពិន្ទុការវាយតម្លៃ PEFA (លើកទី៣) ដោយប្រើប្រាស់ក្របខណ្ឌឆ្នាំ២០១៦

| សូចនាករសមិទ្ធកម្ម | | វិធីសាស្ត្រដាក់ពិន្ទុ | អនុសូចនាករ | | | | ពិន្ទុរួម |
|---|---|---|---|---|---|---|---|
| | | | i. | ii. | iii. | iv. | |
| **សសរស្តម្ភទី១÷ ភាពជឿទុកចិត្តនៃថវិកា** | | | | | | | |
| PI-1 | **លទ្ធផលអនុវត្តចំណាយសរុប** | M1[1] | **A** | | | | **A** |
| PI-2 | **លទ្ធផលអនុវត្តចំណាយតាមសមាសភាគ** | M1 | C | B | A | | **C+** |
| PI-3 | **លទ្ធផលប្រមូលចំណូល** | M2[2] | D | B | | | **C** |
| **សសរស្តម្ភទី២÷ តម្លាភាពនៃហិរញ្ញវត្ថុសាធារណៈ** | | | | | | | |
| PI-4 | ការបែងចែកចំណាត់ថ្នាក់ថវិកា | M1 | C | | | | **C** |
| PI-5 | ឯកសារថវិកា | M1 | B | | | | **B** |
| PI-6 | ប្រតិបត្តិការរបស់រដ្ឋាភិបាលថ្នាក់កណ្តាលក្រៅរបាយការណ៍ហិរញ្ញវត្ថុ | M2 | B | B | D | | **C+** |
| PI-7 | ការផ្ទេរធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | M2 | A | A | | | **A** |
| PI-8 | ព័ត៌មានសមិទ្ធកម្មនៃការផ្តល់សេវា | M2 | C | C | B | C | **C+** |
| PI-9 | ការទទួលបានព័ត៌មានហិរញ្ញវត្ថុដោយសាធារណជន | M1 | D | | | | **D** |
| **សសរស្តម្ភទី៣÷ ការគ្រប់គ្រងទ្រព្យសម្បត្តិនិងបំណុល** | | | | | | | |
| PI-10 | ការរាយការណ៍ពីហានិភ័យហិរញ្ញវត្ថុ | M2 | C | D | D | | **D+** |

[1] 'Weakest link": M1 (WL) ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃសូចនាករសមិទ្ធកម្ម ដែលមានអនុសូចនាករណាមួយមានពិន្ទុទាប ហើយអាចបណ្តាលឱ្យប៉ះពាល់ដល់អនុសូចនាករដទៃនៃសូចនាករតែមួយ។

[2] 'Averaging": M2 (AV) ត្រូវប្រើប្រាស់តារាងដាក់ពិន្ទុ ដែលរៀបចំដោយលេខាធិការដ្ឋាន PEFA ដើម្បីកំណត់ពិន្ទុរួម ។

| សូចនាករសមិទ្ធកម្ម | | វិធីសាស្ត្រដាក់ពិន្ទុ | អនុសូចនាករ | | | | ពិន្ទុរួម |
|---|---|---|---|---|---|---|---|
| | | | i. | ii. | iii. | iv. | |
| PI-11 | ការគ្រប់គ្រងវិនិយោគសាធារណៈ | M2 | C | D | D | C | D+ |
| PI-12 | ការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ | M2 | C | C | C | | C |
| PI-13 | ការគ្រប់គ្រងបំណុល | M2 | C | A | A | | B+ |
| សសរស្តម្ភទី៤៖ គោលនយោបាយហិរញ្ញវត្ថុ និងថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ | | | | | | | |
| PI-14 | ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | M2 | B | C | C | | C+ |
| PI-15 | យុទ្ធសាស្ត្រហិរញ្ញវត្ថុ | M2 | C | C | B | | C+ |
| PI-16 | ក្របខណ្ឌចំណាយរយៈពេលមធ្យម | M2 | D | C | C | D | D+ |
| PI-17 | ដំណើរការនៃការរៀបចំថវិកា | M2 | A | C | A | | B+ |
| PI-18 | ការត្រួតពិនិត្យថវិកាដោយអង្គនីតិបញ្ញត្តិ | M1 | C | C | A | A | C+ |
| សសរស្តម្ភទី៥៖ ភាពអាចប៉ាន់ស្មានបាន និងការគ្រប់គ្រងការអនុវត្តថវិកា | | | | | | | |
| PI-19 | រដ្ឋបាលចំណូល | M2 | A | B | D | D* | C+ |
| PI-20 | គណនេយ្យចំណូល | M1 | A | A | C | | C+ |
| PI-21 | ភាពអាចប៉ាន់ស្មានបាននៃការវិភាជធនធានក្នុងឆ្នាំ | M2 | C | B | B | C | C+ |
| PI-22 | ចំណាយកកស្ទះ | M1 | D | C | | | D+ |
| PI-23 | ការគ្រប់គ្រងលើបៀវត្ស | M1 | B | B | B | D | D+ |
| PI-24 | លទ្ធកម្ម | M2 | D | D | D | A | D+ |
| PI-25 | ការគ្រប់គ្រងផ្ទៃក្នុងលើចំណាយមិនមែនបៀវត្ស | M2 | C | C | C | | C |
| PI-26 | សវនកម្មផ្ទៃក្នុង | M1 | A | B | C | C | C+ |
| សសរស្តម្ភទី៦៖ គណនេយ្យនិងការរៀបចំរបាយការណ៍ | | | | | | | |
| PI-27 | សុចរិតភាពនៃទិន្នន័យហិរញ្ញវត្ថុ | M2 | B | D | C | B | C+ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| PI-28 | របាយការណ៍ថវិកាក្នុងឆ្នាំ | M1 | C | B | C | | **C+** |
| PI-29 | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | M1 | C | D | B | | **D+** |
| **សសរស្តម្ភទី៧÷ ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ** | | | | | | | |
| PI-30 | សវនកម្មផ្ទៃក្រៅ | M1 | NU | NU | NU | NU | **NU** |
| PI-31 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្រៅដោយអង្គនីតិបញ្ញត្តិ | M2 | NA | NA | NA | NA | **NA** |

ផ្អែកលើលទ្ធផលនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១៦ ដូចមានគូសបញ្ជាក់ក្នុងតារាងទី២, **អ.គ.ហ.** អាចទាញការសន្និដ្ឋានថា÷

**ទី១.វិន័យថវិកា÷** ការអនុវត្តចំណាយថវិកាមានភាពកាន់តែល្អប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើបញ្ហាចំណាយកកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលមរតក)។ ចំពោះការអនុវត្តចំណូលថវិកាវិញ ត្រូវបន្តពង្រឹងការព្យាករចំណូល, ការពង្រឹងរដ្ឋបាលប្រមូលចំណូល ជាពិសេសលើការលើកកម្ពស់អនុលោមភាព និងការគ្រប់គ្រងហានិភ័យ និងការតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។

**ទី២.ប្រសិទ្ធភាពវិភាជន៍ថវិកា÷** ការរៀបចំថវិកាប្រចាំឆ្នាំទទួលបានពិន្ទុល្អ ដោយសារគោរពតាមប្រតិទិនថវិកាច្បាស់លាស់ និងមានផ្សព្វផ្សាយឯកសារថវិកាសម្ប្របែប ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាព នៃការរៀបចំឯកសារថវិកាទាំងនោះបន្ថែមទៀត។ ការរៀបចំថវិការយៈពេលមធ្យម គឺកំពុងស្ថិតក្នុងដំណាក់កាលចាប់ផ្តើម ដោយហេតុថាក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) ពុំទាន់ត្រូវបានអនុវត្ត ហើយក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ក៏ត្រូវបាននិងកំពុងអនុវត្តសាកល្បងនៅឡើយ។

**ទី៣.ស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ÷** បច្ច័យនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើការផ្តល់សេវាសាធារណៈ នៅពុំទាន់អាចពិនិត្យឃើញនៅឡើយ ដោយសារកត្តាផ្សេងៗរួមមាន កង្វះប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម, កិច្ចលទ្ធកម្មសាធារណៈនៅមិនទាន់មានការប្រកួតប្រជែង, ការផ្សព្វផ្សាយឯកសារថវិកាសម្រាប់ក្រសួង ស្ថាប័នផ្តល់សេវាសាធារណៈនៅមានកម្រិត។ ជាមួយគ្នានេះ មុខងារសវនកម្មផ្ទៃក្នុងក៏ត្រូវលើកកម្ពស់ ដោយពង្រឹងប្រព័ន្ធត្រួតពិនិត្យ ដើម្បីធានាប្រសិទ្ធភាពការចំណាយថវិកា និងសមិទ្ធកម្មនៅតាមក្រសួង-ស្ថាប័ន។

*លទ្ធផលវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាត្រូវបានកែលម្អ ដោយបានបំពាក់នូវសមាសធាតុសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានវិន័យថវិកា ព្រមទាំងវិភាជថវិកាឱ្យកាន់តែមានប្រសិទ្ធភាព។*

ជារួម លទ្ធផលវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ របស់កម្ពុជាត្រូវបានកែលម្អ ដោយបានបំពាក់នូវសមាសធាតុសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានវិន័យថវិកា ព្រមទាំងវិភាជថវិកាឱ្យកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនោះ សមាសធាតុផ្សេងទៀតក៏កំពុងរៀបចំក្នុងក្របខណ្ឌផែនការសកម្មភាពរួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបំពេញបុរេលក្ខណៈ (pre-requisites) ក្នុងការបញ្ជ្រាបវប្បធម៌សមិទ្ធកម្ម (performance culture) និងបង្កើនតួនាទីនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងការផ្តល់សេវាសាធារណៈ។ យ៉ាងណាមិញ បើប្រៀបធៀបទៅនឹងស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានៅមានគម្លាតនៅឡើយ ដែលចាំបាច់ត្រូវបន្តកែលម្អលើវដ្តថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការលើកកម្ពស់តម្លាភាពថវិកា ព្រមទាំងការពង្រឹងជាជំហានៗបន្ថែម ដូចមានកំណត់ក្នុងគោលដៅយុទ្ធសាស្ត្រគន្លឹះនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ **អ.គ.ហ.** បានកំណត់ភាពខ្សោយនៃប្រព័ន្ធ និងរៀបចំតាមលំដាប់អាទិភាព ព្រមបានដាក់បញ្ចូលជាផែនការសកម្មភាពគន្លឹះៗ ក្នុងក្របខណ្ឌសកម្មភាពរួម៣ បូក២ (CAP3+2) និងបន្តពិនិត្យបន្ថែមទៀតដាក់បញ្ចូលក្នុង CAP4 សម្រាប់អនុវត្តចាប់ពីឆ្នាំ២០២៣ តទៅ៕■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៃ អ.គ.ហ.*

# តួនាទីសំខាន់របស់ប្រព័ន្ធ FMIS ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសេដ្ឋកិច្ចឌីជីថលកម្ពុជា

*ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានគូសបញ្ជាក់ថា ប្រព័ន្ធ FMIS ដើរតួនាទីយ៉ាងសំខាន់ និងមិនអាចខ្វះបាននៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាល ព្រមទាំងនៅក្នុង "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"។ ឯកឧត្តមបណ្ឌិតសភាចារ្យ ថ្លែងបែបនេះ នៅក្នុងឱកាសបើកកម្មវិធី "ការបញ្ជ្រាបការយល់ដឹងអំពីប្រព័ន្ធ FMIS" ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលបន្ថែមថ្មីចំនួន១១ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។*

នាពេលថ្មីៗនេះរដ្ឋាភិបាល តាមរយៈគណៈកម្មការអន្តរក្រសួងដែលមានឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ជាប្រធាន បានគិតគូរយ៉ាងម៉ត់ចត់ និងបានដាក់ចេញនូវ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ក្នុងគោលដៅឆ្លើយតបខ្ពស់ទៅនឹងនិន្នាការសកលនៃបដិវត្តន៍ឧស្សាហកម្ម៤.០ ក៏ដូចជាបរិវត្តកម្មឌីជីថល ដែលបាន និងកំពុងធ្វើឱ្យនិម្មាបនកម្មសេដ្ឋកិច្ចពិភពលោក និងតំបន់មានការវិវឌ្ឍឥតឈប់ឈរ ជាពិសេសបទពិសោធ និងមេរៀននៃការវិបត្តិជំងឺកូវីដ-១៩ ក្នុងបរិការណ៍ដែលចាប់តាំងពីឆ្នាំ២០២០ មកបានបង្ហាញអំពីសក្តានុពលកាន់តែសំខាន់នៃបរិវត្តកម្មឌីជីថល ក្នុងការជំរុញការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច កំណត់នូវចក្ខុវិស័យក្នុងការ "កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយកនិងបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងប្រជាជន និងទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីថ្មី"។ គោលនយោបាយនេះ នឹងត្រូវផ្តោតលើអាទិភាពចំនួន៥ ធំៗរួមមាន (១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល, (២). ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល, (៣). ការកសាងពលរដ្ឋឌីជីថល, (៤). ការកសាងរដ្ឋាភិបាលឌីជីថល និង (៥). ការជំរុញធុរកិច្ចឌីជីថល។

តាមរយៈការរៀបចំក្របខណ្ឌគោលនយោបាយនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** បានសង្កត់ធ្ងន់ថា វត្តមាននៃ*ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ហៅកាត់ថា "ប្រព័ន្ធអេហ្វអឹមអាយអេស"* របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺពិតជាបាននិងកំពុងដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការចូលរួមចំណែកជាមូលដ្ឋានគ្រឹះសម្រាប់ឈានឆ្ពោះទៅរកការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឱ្យសម្រេចបានតាមគោលដៅ ដើម្បីប្រជែង





ឈ្នះជាមួយបណ្ដាប្រទេសក្នុងតំបន់ និងអន្តរជាតិ។ តាមរយៈការអនុវត្តគម្រោង FMIS កន្លងមក ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលក្រុមការងារសម្រេចបាន ក្នុងនោះក៏ទទួលបានការកោតសរសើរពីដៃគូអភិវឌ្ឍន៍ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ជុំវិញការបោះជំហានទៅមុខឥតឈប់ឈររបស់ គម្រោង FMIS ដែលជាចលករដ៏សំខាន់មួយក្នុងការជំរុញនូវការអនុវត្តថវិកានៅតាមក្រសួង-ស្ថាប័ន អង្គភាពចំណាយឱ្យកាន់តែមានក្រឹត្យក្រម និងវិន័យក្នុងការចាយវាយ ឱ្យចំគោលដៅប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលគោលដៅចុងក្រោយ គឺដើម្បីឱ្យការបម្រើនូវសេវាសាធារណៈជូនប្រជាពលរដ្ឋបានទាន់សភាពការណ៍និងតម្រូវការ។ គួរបញ្ជាក់ថា ស្របតាម "**ផែនការពង្រីកប្រព័ន្ធFMIS ជំហានទី២ ២០១៧-២០២០**" ប្រព័ន្ធ FMIS ត្រូវបានដាក់ ឱ្យប្រើប្រាស់ជាផ្លូវការបន្ថែមរួចរាល់នៅក្រសួង-ស្ថាប័នថ្នាក់ជាតិ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង២៥ ដែលមានអ្នកប្រើប្រាស់សរុបជាង ១១៦២ រូប។ ប្រព័ន្ធ FMIS ត្រូវបានបន្តពង្រីកការផ្ទើសន្ទានកម្មទិន្នន័យជាមួយនឹងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធអេឡិចត្រូនិកគយ ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ប្រព័ន្ធគ្រប់គ្រងចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រព័ន្ធធនាគាររបស់ធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជជាដៃគូ។

ដោយឡែក សម្រាប់ "**ផែនការពង្រីកប្រព័ន្ធFMIS ជំហានទី៣ ២០២១-២០២៥**" ក៏មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងនោះមុខងារបន្ថែមថ្មីចំនួនពីរ គឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ បានអភិវឌ្ឍរួចរាល់ និងដាក់ឱ្យប្រើប្រាស់ផ្លូវការនៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី ក្នុងឆ្នាំ២០២១ នេះ។ ទន្ទឹមនឹងនេះ ក្រុមការងារក៏បានអនុវត្តសកម្មភាពជាច្រើនទៀតផងដែរ (រួមមាន ការសិក្សាពីនីតិវិធីអនុវត្តការងារបច្ចុប្បន្ន និងនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ការសិក្សាលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការកំណត់ឈ្មោះអ្នកប្រើប្រាស់ប្រព័ន្ធ) ដើម្បីត្រៀមក្នុងការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងឆ្នាំ-២០២២ ខាងមុខរួមមាន **១.** ការប្រើប្រាស់មុខងារស្នូលនៃប្រព័ន្ធ FMIS នៅរដ្ឋបាលរាជធានី-ខេត្តទាំង២៥ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១១, **២.** ការប្រើប្រាស់មុខងាររៀបចំផែនការថវិកា នៅក្រសួង-ស្ថាប័ន ចំនួន១១ និង **៣.** ការប្រើប្រាស់មុខងារលទ្ធកម្មពេញលេញនៅក្រសួង-ស្ថាប័ន ចំនួន៣៤៕■

*វត្តមាននៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ហៅកាត់ថា "ប្រព័ន្ធអេហ្វអឹមអាយអេស" របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺពិតជាបាននិងកំពុងដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការចូលរួមចំណែកជាមូលដ្ឋានគ្រឹះសម្រាប់ឈានឆ្ពោះទៅរកការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឱ្យសម្រេចបានតាមគោលដៅ ដើម្បីប្រជែងឈ្នះជាមួយបណ្ដាប្រទេសក្នុងតំបន់ និងអន្តរជាតិ។*

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោង FMIS*



# បទពិសោធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការកែទម្រង់ការបើកផ្តល់បៀវត្សតាមនីតិវិធីថ្មីផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធ FMIS

*អនុលោមទៅតាមសារាចរណែនាំលេខ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត គ្រប់ក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផងដែរ បានកំពុងដំណើរការយ៉ាងរលូនក្នុងការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ដែលចាប់អនុវត្តពីខែមករា ឆ្នាំ២០១៩ មកដល់បច្ចុប្បន្ន។*

ដើម្បីឱ្យកិច្ចការនេះប្រព្រឹត្តទៅបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ទាំងការអនុវត្តក្នុង និងក្រៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវសារាចរណែនាំលំអិតលេខ០១១ សហវ ចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ និងអនុវត្តការទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារជាតិនៃកម្ពុជា (Electronic Fund Transfer។

លើសពីនេះទៀត អនុវត្តតាមផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ឆ្នាំ២០២០-២០២៥ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចាប់ផ្តើមអនុវត្តសាកល្បងមុនគេ ចាប់ពីខែមេសា ឆ្នាំ២០២០ នូវនីតិវិធីតម្រង់ទិសថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ ដើម្បីផ្តល់ជាគំរូ និងអនុសាសន៍សម្រាប់បន្តអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន។ នៅក្នុងជំហានដំបូងនេះ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរតនាគារជាតិ បានចូលរួមអនុវត្តនីតិវិធីតម្រង់ទិសថ្មី ដែលត្រូវបង្កើតប្រតិបត្តិការ



ចំណាយនៅក្នុងប្រព័ន្ធ FMIS ទាំងស្រុង ដោយមិនមានការរៀបចំសំណុំឯកសារអាណត្តិបើកប្រាក់ខាងក្រៅប្រព័ន្ធ FMIS ទៀតឡើយ ព្រមទាំងភ្ជាប់ជាមួយការស្កេននូវលិខិតយុត្តិការចំណាយមួយចំនួន ដើម្បីជាមូលដ្ឋានពិនិត្យការទូទាត់សាច់ប្រាក់ ឬទូទាត់បុរេប្រទាន និងធ្វើសវនកម្មតាមប្រព័ន្ធ FMIS បន្ទាប់មកធ្វើការត្រួតពិនិត្យ និងអនុម័តប្រតិបត្តិការនៅក្នុងប្រព័ន្ធ FMIS ជាផ្លូវការ ដោយពុំរង់ចាំឯកសារជាក្រដាសនោះទេ រួមជាមួយប្រព័ន្ធទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារជាតិនៃកម្ពុជា (Electronic Fund Transfer)។ ចំពោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្តាល ដែលមិនទាន់ប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវរៀបចំសំណុំឯកសារអាណត្តិបើកប្រាក់ រួចបញ្ជូនមកអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបន្តនីតិវិធីនៅក្នុងប្រព័ន្ធ FMIS ដោយមិនបញ្ជូនសំណុំឯកសារច្បាប់ដើមទាំងនោះបន្តទៀតទេ ហើយត្រូវបានអនុញ្ញាតឱ្យរក្សាទុកនៅសាមីអង្គភាព។

នៅក្នុងជំហានបន្ទាប់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ បានរួមសហការគ្នារៀបចំនូវបច្ចេកទេស



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ...០០៥...... សហវ.......

**សេចក្តីណែនាំ**
**ស្តីពី**
**ការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិល និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ រួមទាំងការអនុវត្តនីតិវិធីថ្មី សម្រាប់ដំណាក់កាលសាកល្បង**

ស្របតាមផែនការរួមដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ បានរួមសហការគ្នារៀបចំនូវបច្ចេកទេសសន្ទានកម្មផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិល និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្នុងគោលបំណងកែលម្អបន្ថែមនូវនីតិវិធីនៃការបើកផ្តល់បៀវត្សរវាងក្រសួង-ស្ថាប័នជាមួយក្រសួងមុខងារសាធារណៈ ផ្សារភ្ជាប់នឹងនីតិវិធីតម្រង់ទិសថ្មីនៃការបើកផ្តល់បៀវត្សតាមប្រព័ន្ធ FMIS ដែលបានដំណើរការនៅក្រសួងមួយចំនួនរួចរាល់ ដោយនឹងកាត់បន្ថយទាំងការងារនិងពេលវេលានៅក្នុងនីតិវិធី និងឈានដល់ការកាត់បន្ថយនូវការប្រើប្រាស់ឯកសារជាក្រដាសបន្ថែមទៀត ព្រមទាំងបង្កើននូវសង្គតិភាពនៃព័ត៌មានរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងគ្នារបស់រដ្ឋ ។ ក្រសួងដែលត្រូវអនុវត្តសន្ទានកម្មផ្លាស់ប្តូរទិន្នន័យខាងលើនេះនៅក្នុងដំណាក់កាលសាកល្បង រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ដែលនឹងផ្តល់ជាគំរូ និងមូលដ្ឋានក្នុងការឈានទៅអនុវត្តសម្រាប់ក្រសួង-ស្ថាប័នផ្សេងទៀតនៅដំណាក់កាលបន្ទាប់ ។

ការដាក់ឱ្យអនុវត្តសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធទាំងពីរខាងលើនេះ នឹងបណ្តាលឱ្យមានការកែសម្រួលនូវនីតិវិធីអនុវត្តការងារបច្ចុប្បន្នមួយចំនួននៅ**អង្គភាពទទួលបន្ទុកប្រតិបត្តិការចំណាយបៀវត្សតាមប្រព័ន្ធ FMIS** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ អង្គភាពទទួលបន្ទុកប្រតិបត្តិការចំណាយបៀវត្សតាមប្រព័ន្ធ FMIS នៃក្រសួងទាំងពីរ ដូចតទៅ÷

**១.** នៅរៀងរាល់កំឡុងពីសប្តាហ៍ទី២ នៃខែនីមួយៗ រហូតដល់សប្តាហ៍ទី១ នៃខែបន្ទាប់ ត្រូវធ្វើការពិនិត្យស្វែងរកនូវប្រតិបត្តិការចំណាយបៀវត្សថ្មីនៅក្នុងប្រព័ន្ធ FMIS ដែលនឹងបង្កើតដោយស្វ័យប្រវត្តិចេញពីទិន្នន័យដែលផ្តល់មកដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិល ។

**២.** បន្ទាប់ពីពិនិត្យឃើញថាមានប្រតិបត្តិការបៀវត្សត្រូវបានបង្កើតដោយស្វ័យប្រវត្តិនៅក្នុង FMIS រួចរាល់ ត្រូវធ្វើការផ្ទៀងផ្ទាត់ទិន្នន័យបៀវត្ស និង ពន្ធកាត់ទុកលម្អិត ។

**៣.** ករណីពិនិត្យឃើញថាមិនមានប្រតិបត្តិការរបស់អង្គភាពណាមួយនៅក្នុងប្រព័ន្ធ FMIS ក្នុងចន្លោះពេលដូចមានកំណត់ក្នុងចំណុចទី១ ខាងលើ ឬ ករណីពិនិត្យឃើញថាទិន្នន័យមិនត្រឹមត្រូវ ឬ មានកំហុសណាមួយ ត្រូវជូនដំណឹងទៅ

- 1 -

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ៖(+៨៥៥)២៣៨៩០៦៦៦
Phone : (+855) 23 890 666

ក្រុមការងារបច្ចេកទេសនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិល នៃក្រសួងមុខងារសាធារណៈ ឬលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យនិងដោះស្រាយ ។

**៤.** ករណីមិនមានបញ្ហាណាមួយដូចក្នុងចំណុចទី៣ ត្រូវបន្តនីតិវិធីដូចបច្ចុប្បន្ននៅក្នុងប្រព័ន្ធ FMIS ។

អង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងមុខងារសាធារណៈ ត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីខែ ឧសភា ឆ្នាំ ២០២១ តទៅ ។

*ថ្ងៃ........ខែ........ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០២១*

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

- 2 -

សន្ទានកម្ម ផ្លាស់ប្តូរទិន្នន័យ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលបំណងកែលម្អបន្ថែមនូវនីតិវិធីបើកផ្តល់បៀវត្សរវាងក្រសួង-ស្ថាប័ន ជាមួយក្រសួងមុខងារសាធារណៈ ផ្សារភ្ជាប់នឹងនីតិវិធីតម្រង់ទិសថ្មីនៃការបើកផ្តល់បៀវត្សតាមប្រព័ន្ធ FMIS។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ បានអនុវត្តសន្ទានកម្មផ្លាស់ប្តូរទិន្នន័យខាងលើនេះ ចាប់ពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ តាមរយៈការបង្កើតដោយស្វ័យប្រវត្តិនូវប្រតិបត្តិការចំណាយបៀវត្សថ្មីនៅក្នុងប្រព័ន្ធ FMIS ពីទិន្នន័យដែលផ្តល់មកដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល។ មកដល់បច្ចុប្បន្នក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុវត្តនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្សផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធ FMIS ប្រកបដោយភាពជោគជ័យ ស្របតាមនីតិវិធីបែបឧត្តមានុវត្តន៍ ដែលកំពុងអនុវត្តនៅតាមប្រទេសជឿនលឿននានាលើសាកលលោក៕■

*អនុវត្តតាមផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ឆ្នាំ២០២០-២០២៥ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច-និងហិរញ្ញវត្ថុបានចាប់ផ្តើមអនុវត្តអនុវត្តសាកល្បងមុនគេ ចាប់ពីខែមេសា ឆ្នាំ២០២០ នូវនីតិវិធីតម្រង់ទិសថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ ដើម្បីផ្តល់ជាគំរូ និងអនុសាសន៍សម្រាប់បន្តអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន។*

*រៀបចំដោយ÷ អគ្គលេខាធិការដ្ឋាន គសហវ.*

# ការវិវត្តរចនាសម្ព័ន្ធកម្មវិធីនិងការផ្ទេរសិទ្ធិជូនអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*គិតត្រឹមឆមាសទី២ ឆ្នាំ២០២១នេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំកែសម្រួលថ្មីនូវរចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ដោយបានដាក់ឱ្យដំណើរអង្គភាពថវិកាថ្មី និងការផ្ទេរសិទ្ធិក្នុងឋានៈជាអាណាប័កផ្ទេរសិទ្ធិពេញលេញជូនអង្គភាពថវិកាដែលនៅមិនទាន់បានទទួលសិទ្ធិពេញលេញនៅឡើយ ក្នុងគោលបំណងធានានិរន្តរភាពនៃការអនុវត្តថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមឱវាទនៃរាជរដ្ឋាភិបាលកម្ពុជា ដោយច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។ ចាប់ពីឆ្នាំ២០១៥ រហូតមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាក្រសួងមួយស្ថិតក្នុងចំណោមក្រសួងទាំង១០ ដំបូង ដែលបានអនុវត្តថវិកាកម្មវិធីពេញលេញ និងបានសម្រេចនូវសមិទ្ធផលជាបន្តបន្ទាប់ក្នុងការងារជំរុញ និងកសាងភាពជាគំរូក្នុងការអនុវត្តថវិកាកម្មវិធី។ ស្របតាមការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការអនុវត្តថវិកាកម្មវិធី ត្រូវអនុលោមតាមគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦។

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រចនាសម្ព័ន្ធកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅពុំទាន់មានសង្គតិភាពជាមួយនឹងការប្រែប្រួលនៃមុខងារ និងភារកិច្ចរបស់ក្រសួងនៅឡើយ ដែលជាកម្មវត្ថុក្នុងការពិនិត្យកែសម្រួលស្របតាមបច្ចុប្បន្នភាពនៃការកើនឡើងនៃចំនួនថ្នាក់ដឹកនាំក្រសួងក្នុងការណ៍នេះ រចនាសម្ព័ន្ធកម្មវិធីនាពេលបច្ចុប្បន្ន នៅបន្តអនុវត្តតាមរចនាសម្ព័ន្ធឆ្នាំ២០១៤ ពេលដែលក្រសួងទើបចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញនៅឡើយ។

ការចាប់ផ្តើមអនុវត្តថវិកាកម្មវិធីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាលើកដំបូង បានជួបប្រទះនូវបញ្ហាប្រឈមស្មើរគ្រប់ដំណាក់កាល នៃវដ្តថវិកា រួមមានទាំងដំណាក់កាលនៃការរៀបចំ, ការអនុវត្ត, ព្រមទាំងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា ទាំងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងគ្រប់អង្គភាពថវិកាក្រោមឱវាទក្រសួង។ ជាបច្ច័យ កាអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននាំមកនូវការផ្លាស់ប្តូរបរិបទការងារគួរឱ្យកត់សម្គាល់នៅគ្រប់ដំណាក់កាល នៃវដ្តថវិកា ទោះបីជាកត្តាពេលវេលា នូវតែជាបញ្ហាប្រឈមនៅឡើយ។ ការគិតគូរអំពីការវិវត្តនៃរចនាសម្ព័ន្ធកម្មវិធី និងការផ្ទេរសិទ្ធិជូនអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយពិនិត្យឡើងវិញនូវគោលបំណង គោលនយោបាយ កម្មវិធី និងអនុកម្មវិធីរបស់

ការវិវត្តរចនាសម្ព័ន្ធកម្មវិធី និងការផ្ទេរសិទ្ធិជូនអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ចាប់ពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន






ក្រសួង ដើម្បីធានាឱ្យបាននូវការផ្សារភ្ជាប់ និងឆ្លើយតបគ្នាទៅវិញទៅមករវាងរចនាសម្ព័ន្ធកម្មវិធី និងមុខងារស្នូលរបស់ក្រសួង។ ដោយឡែក ការគិតគូរបន្ថែមសម្រាប់ឆ្នាំ២០២២ ខាងមុខ រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ត្រូវបានគិតគូរយ៉ាងល្អិតល្អន់គ្រប់ជ្រុងជ្រោយ និងផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងស្របតាមលក្ខណៈដោយឡែក របស់ក្រសួងផងដែរ។ ជាក់ស្តែង ការបង្កើតអង្គភាពថវិកាថ្មី ក្នុងកម្រិតជាអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, ឬវិទ្យាស្ថាន អង្គភាពថវិកាថ្មីទាំងនោះត្រូវបានដាក់ឱ្យអនុវត្តក្នុងកម្រិតជាអង្គភាពថវិកាមួយដោយបន្ថែមអនុកម្មវិធីថ្មីមួយទៅក្នុងកម្មវិធីណាមួយនៃរចនាសម្ព័ន្ធកម្មវិធីដែលមានស្រាប់ ឱ្យស្របតាមគោលការណ៍ណែនាំ នៃការអនុវត្តថវិកាកម្មវិធី និងបទដ្ឋានគតិយុត្តជាធរមាន។

## ហេតុអ្វីបានជាត្រូវផ្ទេរសិទ្ធិជូនអង្គភាពថវិកា?

ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី គឺជាឯកសារគតិយុត្តចាំបាច់ ដែលត្រូវបានរៀបចំឡើងសម្រាប់ឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញក្រោមឱវាទ អាចដំណើរការអនុវត្តកម្មវិធី អនុកម្មវិធី និងសកម្មភាពរបស់ខ្លួនបានដោយរលូន មានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងប្រកបដោយការសន្សំសំចៃ។ នីតិវិធីអនុវត្តថវិកាកម្មវិធីនេះ មានគោលបំណងរៀបចំជាក្របខណ្ឌគតិយុត្ត គ្រប់ជ្រុងជ្រោយសម្រាប់ក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធីដោយគ្របដណ្តប់បរិបទចំណាយចាប់ពីដំណាក់កាលវិភាជន៍ឥណទានថវិកា រហូតដល់ដំណាក់កាលទូទាត់ ពិសេសសំដៅធានាបានថា ថវិកាវិភាជន៍ត្រូវបានចំណាយដោយអនុលោមតាមនីតិវិធីហិរញ្ញវត្ថុដែលមានជាធរមាន និងកត់ត្រាបានត្រឹមត្រូវតាមមាតិកាថវិកា ព្រមទាំងស្របតាមកម្មវិធី អនុកម្មវិធី និងសកម្មភាពតាមការគ្រោងទុក។ នីតិវិធីនេះ ក៏បានគូសបញ្ជាក់ អំពីការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះការប្រើប្រាស់ ព្រមទាំងការគ្រប់គ្រងធនធានសាធារណៈរបស់ក្រសួង-ស្ថាប័ន ក៏ដូចជា អង្គភាពថវិកាក្នុងដំណើរការអនុវត្តសកម្មភាព ឆ្ពោះទៅសម្រេច ឱ្យបាននូវលទ្ធផលទៅតាមគោលបំណងគោលនយោបាយជាអាទិភាពរបស់ខ្លួន។ ដោយផ្អែកតាមក្របខណ្ឌគតិយុត្តនេះ សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្ត ហើយមាន *វិសាលភាពអនុវត្តលើចំណាយចរន្តថ្នាក់ជាតិប៉ុណ្ណោះ* ចំណែក ឯចំណាយមូលធន

*ត្រូវបន្តអនុវត្តទៅតាមនីតិវិធីនិងបទដ្ឋានគតិយុត្តដែលមានជាធរមាន។*

អង្គភាពថវិកាដែលទទួលបានការផ្ទេរសិទ្ធិ ឬអាណាប័កផ្ទេរសិទ្ធិ ត្រូវបានកំណត់ជាធរមាននៅក្នុងក្របខណ្ឌថវិកាកម្មវិធី។ សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អាណាប័ក មានចែងច្បាស់នៅក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធី នៃការអនុវត្តថវិកាកម្មវិធី គឺថាអាណាប័កគឺជាអភិបាលកំពូលនៃក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលមានសិទ្ធិអំណាចគ្រប់គ្រាន់តាមច្បាប់ក្នុងការបញ្ជាចំណូល និងបញ្ជាចំណាយថវិការបស់ខ្លួន។ ក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ អាណាប័កចាត់ចែងក្រោមការទទួលខុសត្រូវរបស់ខ្លួនក្នុងកម្រិតឥណទាន ដែលខ្លួនទទួលបានដើម្បីស្នើសុំធានាចំណាយ អនុវត្តកិច្ចលទ្ធកម្មសាធារណៈ បោះផ្សាយអាណត្តិបើកប្រាក់ និងកិច្ចបញ្ជិការក្នុងវង្វង់ឥណទានថវិការបស់ខ្លួន។

ក្នុងឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងក្រោមរចនាសម្ព័ន្ធថវិកាកម្មវិធីដោយមានគោលបំណងគោលនយោបាយចំនួន២ កម្មវិធីចំនួន៥ និងអនុកម្មវិធីចំនួន១៦ (មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ស្ថិតក្នុងអនុកម្មវិធីមួយក្នុងចំណោមអនុកម្មវិធីទាំង១៦)។ ការផ្ទេរសិទ្ធិជូនអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានគិតគូរចាប់ពីដំណាក់កាលចាប់ផ្តើមអនុវត្តថវិកាកម្មវិធីមក ដោយបានផ្ទេរសិទ្ធិពេញលេញលើឥណទានថវិកានៃឆ្នាំអនុវត្តថវិកាជូនអង្គភាពថវិកាថ្នាក់កណ្តាលចំនួន ៣ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ទាំង ២៥ សរុបមានចំនួន២៨ អង្គភាព។ ទន្ទឹមនឹងការផ្ទេរសិទ្ធិពេញលេញជូនអង្គភាពថវិកាមួយចំនួនក្នុងឆ្នាំ២០១៥នេះ ក្រសួង


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៩១១ សហវ.ប្រក

ប្រកាស
ស្តីពី
ការដាក់ឱ្យអនុវត្ត
គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ខែមករា ឆ្នាំ២០១២ ដែលប្រកាសដាក់ឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ

១

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សេដ្ឋកិច្ច និងហិរញ្ញវត្ថុបានគិតគូរជំហានដំបូងសម្រាប់អង្គភាពថវិកាដែលមិនទាន់ទទួលបានការផ្ទេរសិទ្ធិចំនួន០២ រួមមាន÷

១. ផ្ទេរសិទ្ធិជូនអង្គភាពថវិកាដែលមិនមែនជាអាណាប័កផ្ទេរសិទ្ធិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវអនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ជាធរមាន។

២. ការប្រគល់សិទ្ធិលើឥណទានរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ឆ្នាំ២០១៦** ស្ថិតក្រោមរចនាសម្ព័ន្ធថវិកាកម្មវិធីដោយមានគោលបំណង គោលនយោបាយចំនួន២ កម្មវិធីចំនួន៥ ដដែល អនុកម្មវិធីបានឡើង៣ បន្ថែមទៀត សរុបចំនួន១៩ អនុកម្មវិធី ប៉ុន្តែមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ស្ថិតក្នុងអនុកម្មវិធីមួយក្នុងចំណោមអនុកម្មវិធីទាំង១៩ នោះ។ ការផ្ទេរសិទ្ធិជូនអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានកើនឡើង២ បន្ថែមទៀតសម្រាប់អង្គភាពថវិកាថ្នាក់កណ្តាលសរុបមានចំនួន៣០អង្គភាព។

**ឆ្នាំ២០១៧-២០១៨** ស្ថិតក្រោមរចនាសម្ព័ន្ធថវិកាកម្មវិធីដោយមានគោលបំណងគោលនយោបាយចំនួន២ កម្មវិធីចំនួន៥ ដដែល បម្រែបម្រួលនៃអនុកម្មវិធីបានកើនឡើង២ បន្ថែមទៀត សរុបចំនួន២១



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពី
សិទ្ធិអំណាច ការទទួលខុសត្រូវ
និង នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នព្រះរាជាណាចក្រកម្ពុជា
្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង
ជាណាចក្រកម្ពុជា
្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល
ាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
លេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ
ៅនៃគណៈរដ្ឋមន្ត្រី
លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ
ួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យ
រញ្ញវត្ថុសាធារណៈ
លេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី
ការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
លេខនស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យ
ោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ
ខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្ត
ទំព័រ ।

ញ កម្ពុជា
CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
១៦

អនុកម្មវិធី ប៉ុន្តែមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ស្ថិតក្នុងអនុកម្មវិធីមួយក្នុងចំណោមអនុកម្មវិធីទាំង២១។ ការផ្ទេរសិទ្ធិជូនអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានកើនឡើង៣ បន្ថែមទៀតនៅអង្គភាពថវិកាថ្នាក់កណ្តាល សរុបមានចំនួន៨ អង្គភាព សរុបមានចំនួន៣១ អង្គភាព។

ឆ្នាំ២០១៩-២០២០ ស្ថិតក្រោមរចនាសម្ព័ន្ធថវិកាកម្មវិធីដោយមានគោលបំណងគោលនយោបាយចំនួន២ កម្មវិធីចំនួន៥ ដដែល។ បម្រែបម្រួលនៃអនុកម្មវិធីបានឡើង៦ បន្ថែមទៀត សរុបចំនួន២៧ អនុកម្មវិធី ប៉ុន្តែនៅពេលនោះមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ទាំង២៥ **ត្រូវបានគិតគូរបន្ថែមក្នុងការកែសម្រួលអនុកម្មវិធីដែលទទួលបន្ទុកដោយដកចេញពីអនុកម្មវិធីរួមមួយ ទៅជាជ្រកក្រោមអនុកម្មវិធី៤ ផ្សេងគ្នា ដើម្បីបន្សុីគ្នារវាងមុខងាររបស់មន្ទីរជាមួយនឹងកម្មវិធីទាំងនោះ។** ការផ្ទេរសិទ្ធិជូនអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានកើនឡើង២ បន្ថែមទៀតសម្រាប់អង្គភាពថវិកាថ្នាក់កណ្តាល សរុបមានចំនួន៣៥ អង្គភាព។

*រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ត្រូវបានរៀបចំឡើងដោយមិនប្រាសចាកនូវមុខងារស្នូលទាំង៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន÷ ការគ្រប់គ្រងវិស័យសេដ្ឋកិច្ច, ការគ្រប់គ្រងហិរញ្ញវត្ថុ, និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់គិតគូរបន្ថែម ក្នុងកម្រិតគោលបំណង គោលនយោបាយ កម្មវិធី និងអនុកម្មវិធី។*

ឆ្នាំ២០២១ គឺជាការគិតគូរទាំងស្រុងពីសំណាក់ថ្នាក់ដឹកនាំ នៃអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ អគ្គនាយកដ្ឋានថវិកា និងការសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២០ ដែលបានរៀបចំប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានអង្គភាពថវិកាដែលមិនទាន់ទទួលបានការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិដើម្បីទទួលបានសិទ្ធិពេញលេញក្នុងការអនុវត្តថវិការបស់ខ្លួន។

## ភាពចាំបាច់នៃការវិវត្ត និងការកែសម្រួលរចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បរិបទមួយដ៏ចាំបាច់នៃការវិវត្តនៃរចនាសម្ព័ន្ធ និងមុខងាររបស់ក្រសួង បើទោះបីជាបេសកកម្មរបស់ក្រសួងមិនមានការផ្លាស់ប្តូរក៏ដោយ ក៏វិសាលភាពនៃការអនុវត្តមុខងាររបស់ក្រសួងបានពង្រីកកាន់តែធំដែលនាំឱ្យ ការបង្កើតថ្មីនូវអង្គភាពថវិកាមួយចំនួនស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងដដែល។ ក្នុងន័យនេះ ការបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ គឺជាបរិបទមួយថ្មី គួបផ្សំជាមួយនឹងការកើនឡើងនៃចំនួនថ្នាក់ដឹកនាំក្រសួងផងដែរ ដែលជាកត្តានាំឱ្យមានការកែសម្រួលរចនាសម្ព័ន្ធកម្មវិធីក្រសួងជាថ្មី ជាបន្តបន្ទាប់ពិសេសក្នុងឆ្នាំ២០២២ ខាងមុខនេះ គឺត្រូវបានពិនិត្យមើលឡើងវិញ នូវទិដ្ឋភាពរួមឡើងវិញដើម្បីធានាបាននូវសង្គតិភាពមុខងារ និងភារកិច្ចរបស់ក្រសួង។

ការកែសម្រួលរចនាសម្ព័ន្ធកម្មវិធីទៀតសោត គឺមានវិសាលភាពគ្រប់ដណ្តប់ទាំងគោលបំណង គោលនយោបាយចំនួន២ របស់ក្រសួង និងទាំងការរំលេចឱ្យឃើញនូវមុខងារស្នូលរបស់កម្មវិធីទាំង៥ របស់ក្រសួង រីឯអនុកម្មវិធីនីមួយៗ ត្រូវមានសង្គតិភាព និងវិសាលភាពតាមកម្មវិធីនីមួយៗ ព្រមទាំងឆ្លើយតបនឹងមុខងារលម្អិតនីមួយៗ និងមានសង្គតិភាពគ្នាជាមួយរចនាសម្ព័ន្ធរដ្ឋបាល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ។ រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ត្រូវបានរៀបចំឡើងដោយមិនប្រាសចាកនូវមុខងារស្នូលទាំង៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន÷ ការគ្រប់គ្រងវិស័យសេដ្ឋកិច្ច, ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុ, និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់គិតគូរបន្ថែមក្នុងកម្រិតគោលបំណង គោលនយោបាយ កម្មវិធី និងអនុកម្មវិធី៕■

*រៀបចំដោយ÷ អគ្គលេខាធិការដ្ឋាន គសហវ.*

# គោលការណ៍គ្រឹះនៃថវិកា ៖ សសរស្តម្ភនៃវិន័យថវិកា

*វិន័យថវិកាគឺជាគោលបំណងដ៏មានសារៈសំខាន់បំផុតមួយនៅក្នុងចំណោមគោលបំណងធំទាំង៣ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាឧត្តមានុវត្តន៍អន្តរជាតិ វិន័យនេះធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងការប្រើប្រាស់ថវិកា តាមរយៈគោលការណ៍គ្រឹះមួយចំនួនដែលមានដូចតទៅ៖*

**១.សកលភាព** (Universality)

គោលការណ៍នេះមានន័យថាគ្រប់ប្រភេទចំណូលទាំងអស់ អាចប្រើប្រាស់សម្រាប់រាល់មុខចំណាយដោយគ្មានលក្ខខណ្ឌ។ ចំណូលរបស់រដ្ឋាភិបាលរាប់បញ្ចូលទាំងចំណូលសារពើពន្ធ ចំណូលមិនមែនសារ-ពើពន្ធ និងចំណូលមូលធនដែលបានប្រមូលត្រូវកត់ត្រាទាំងស្រុង និងពុំអាចកាត់កងត្រង់នឹងចំណាយណាមួយជាក់លាក់ឡើយ។ ទោះយ៉ាងណា យោងតាមមាត្រា ២០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបើកឱ្យមានលទ្ធភាពក្នុងការវិភាជន៍ចំណូលមួយចំនួន សម្រាប់លើមុខសញ្ញាចំណាយមួយចំនួនដែរ តែត្រូវមានលក្ខខណ្ឌកំណត់ដោយច្បាប់។ លើសពីនេះ ការបង្កើនទឹកប្រាក់នៃឥណទានដែលបានអនុម័តដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយត្រូវបានហាមឃាត់។

ជាឧត្តមានុវត្តន៍អន្តរជាតិ គោលការណ៍នេះបង្កប់នូវអត្ថន័យលម្អិត ២ផ្សេងទៀត រួមមាន៖

**❶. គោលការណ៍មិនកាត់កង (Non-compensation Principle)** សំដៅដល់ការបង្ហាញថវិកាជាចំនួនទឹកប្រាក់ដុល និងមិនមែនទឹកប្រាក់សុទ្ធ មានន័យថាចំណូលទាំងអស់ពុំអនុញ្ញាតឱ្យមានការកាត់កងនឹងចំណាយណាមួយទេ។ បរិមាណទឹកប្រាក់ដែលជាចំណូល ត្រូវតែបង្ហាញជាចំនួនដុល។ ការអនុវត្តបែបនេះ ធានាបាននូវសុក្រឹតភាព និងភាពត្រឹមត្រូវនៃព័ត៌មានចំណូលសរុប និងជាពិសេសមិនធ្វើឱ្យបាត់មុខចំណាយជាក់ស្តែង។

**❷. គោលការណ៍មិនភ្ជាប់លក្ខខណ្ឌ (Non-Affectation Principle)** មានន័យថាគ្មានចំណូលណាមួយត្រូវបានយកទៅបែងចែកផ្ទាល់ជាហិរញ្ញប្បទានដល់ចំណាយពិសេសណាមួយឡើយ ពោលលទ្ធភាពនៃការប្រើប្រាស់ចំណូលពុំត្រូវបានរឹតត្បិត ឬកំណត់លក្ខខណ្ឌលើចំណាយជាក់លាក់ណាមួយឡើយ។

**២.សមាគតភាព** (Associability)

គោលការណ៍នេះសំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ និងគ្រប់មុខសញ្ញាទាំង-អស់ត្រូវបង់ និងទូទាត់តាមរយៈប្រព័ន្ធគណនីទោលរបស់រតនាគារជាតិ។ ប្រព័ន្ធគណនីទោលរបស់រតនាគារជាតិ គឺជាគោល-នយោបាយក្នុងការកំណត់ឱ្យមានគណនីរដ្ឋាភិបាលរួមតែមួយដែលស្ថិតនៅធនាគារ-ជាតិ និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប្រព័ន្ធនេះ ត្រូវបានប្រើប្រាស់សម្រាប់ការទទួលចំណូលគ្រប់ប្រភេទ និងទូទាត់រាល់ខ្ទង់ចំណាយរបស់រាជរដ្ឋាភិបាល។ ការអនុវត្តប្រព័ន្ធគណនីទោល គឺជាទម្រង់នៃការគ្រប់គ្រងសាច់ប្រាក់បែបទំនើប ដែលអាចធានាថាសាច់ប្រាក់មានគ្រប់គ្រាន់នៅពេលមានចំណាយកើតឡើង កាត់បន្ថយការខ្ជីសាច់ប្រាក់របស់រដ្ឋាភិបាល និងគ្រប់-គ្រងហានិភ័យសាច់ប្រាក់ជាដើម។ល។



យ៉ាងណាមិញ គោលការណ៍នេះពុំសំដៅដល់ការរឹតត្បិតឱ្យមានប្រតិបត្តិការចំណូល-ដែលរួមបញ្ចូលគណនីមួយចំនួននៅតាមធនាគារពាណិជ្ជផងដែរ។ ជាក់ស្តែង NRMIS គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការ

គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ របស់រាជរដ្ឋាភិបាល ដែលប្រព័ន្ធនេះផ្សារភ្ជាប់នឹងគណនីទោលរតនាគារជាតិ និងគណនីមួយចំនួននៅធនាគារពាណិជ្ជ ដែលអនុញ្ញាតឱ្យសាធារណជនអាចជ្រើសរើសក្នុងការបង់ថ្លៃសេវាសាធារណៈនៅតាមធនាគារពាណិជ្ជ។ ជារៀងរាល់ថ្ងៃ សមតុល្យពីគណនីធនាគារពាណិជ្ជ ត្រូវផ្ទេរទៅប្រព័ន្ធគណនីទោលរតនាគារជាតិ។




**៣.បូរណភាព** (Integrity)

គោលការណ៍នេះសំដៅដល់ហិរញ្ញវត្ថុសាធារណៈមានប្រព័ន្ធតែមួយដែលមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ គ្មានការប្រទាំងប្រទើសទាំងផ្នែកគោលនយោបាយ ក្របខណ្ឌច្បាប់ និងស្ថាប័ន ហើយដែលមិនអាចរំលោភបំពានបាន។ ក្នុងសេចក្តីនេះ ជាក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូលរបស់កម្ពុជា រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរួមមួយ ហើយគោលនយោបាយ ឬក្របខណ្ឌច្បាប់ផ្សេងទៀត ពុំអាចកំណត់ឱ្យប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមានលក្ខណៈផ្សេងពីនេះឡើយ។ ប្រព័ន្ធនេះ បានកំណត់តួអង្គជាក់លាក់ក្នុងការរៀបចំ ពិនិត្យ អនុម័ត និងគ្រប់គ្រងក្របខណ្ឌគតិយុត្ត ព្រមទាំងគោលនយោបាយនីមួយៗ ពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានរដ្ឋសភា ព្រឹទ្ធសភា គណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ យ៉ាងណាមិញ សម្រាប់ប្រទេសមួយចំនួន ដែលមានទម្រង់ជារដ្ឋសហព័ន្ធ គោលការណ៍នេះពុំត្រូវបានអនុវត្តឡើយ ដោយហេតុថាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានបង្កើត និងគ្រប់គ្រងនៅរដ្ឋាភិបាលនៃរដ្ឋនីមួយៗ។

**៤.ភាពជាអាជ្ញា** (Authoritativeness)

ភាពជាអាជ្ញាសំដៅដល់ភាពពុំអាចត្រូវបានបំពានដោយបុគ្គល ស្ថាប័ន ឬច្បាប់ដទៃណាមួយទៀតបានឡើយ។ ថវិកាជាច្បាប់ដែលអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ ហើយច្បាប់ទាំងនោះរួមមានច្បាប់គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់។ គោលការណ៍នេះ បានកំណត់នូវអានុភាពនៃច្បាប់ពាក់ព័ន្ធនឹងថវិកា ជាការតម្រូវឱ្យគោរព និងប្រតិបត្តិជាដាច់ខាតដោយគ្មានការបំពាន។ ការគោរព និងប្រតិបត្តិថវិកាអនុលោមទៅតាមគោលការណ៍វិន័យថវិកា វិន័យហិរញ្ញវត្ថុ និងវិន័យហិរញ្ញវត្ថុសាធារណៈ។ ក្នុងករណីមានការបំពានត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

**៥.ឯកត្តភាព** (Unity)

គោលការណ៍ឯកត្តភាព នៃថវិកាមានអត្ថន័យ ២យ៉ាង គឺ**ទី១.** ចំណូល-ចំណាយទាំងអស់ត្រូវដាក់ឱ្យរដ្ឋសភាអនុម័តសម្រាប់ឆ្នាំខាងមុខ និង **ទី២.** ចំណូល-ចំណាយត្រូវតែបង្ហាញដោយព្រមៗគ្នាតែម្តង ដើម្បីបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូល និងការអនុវត្តចំណាយ ព្រមទាំងឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃ**តុល្យភាពថវិកា**។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យបង្កើត ឬកែប្រែពន្ធដោយច្បាប់។ ពន្ធ អាករ និងចំណូលសារពើពន្ធផ្សេងៗត្រូវកំណត់ដោយច្បាប់ ព្រមទាំងត្រូវប្រមូល

និងត្រូតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា ១៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨)។ គ្រប់ក្រសួង-ស្ថាប័នប្រហាក់ប្រហែលសាធារណៈទាំងអស់ ត្រូវរាយការណ៍ឱ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹងពីចំណូលទាំងអស់ "ដើម្បីចាត់ថ្នាក់ចំណូលទាំងនោះនៅក្នុងមាតិកាចំណូលថវិកា ឱ្យបានសមស្រប" (មាត្រា ៥០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

ជាឧត្តមានុវត្តន៍អន្តរជាតិ យោងតាមអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានផ្តល់និយមន័យគោលការណ៍ឯកត្តភាពនេះថាជាចំណូល-ចំណាយ ដែលត្រូវបានពិចារណារួមជាមួយគ្នា ឬព្រមគ្នា ក្នុងការកំណត់នូវគោលដៅថវិកាប្រចាំឆ្នាំ។ ថវិកានោះត្រូវគ្របដណ្តប់លើគ្រប់ប្រតិបត្តិការរដ្ឋាភិបាលដែលឆ្លុះបញ្ចាំងជារូបភាពបូកសរុបនៃប្រតិបត្តិការទាំងនោះ និងត្រូវបានអនុម័តដោយសភា។

យោងតាមបទប្បញ្ញត្តិក្រុមប្រឹក្សារបស់សហគមន៍អឺរ៉ុប លេខ១៦០៥/២០០២ ស្តីពីបទប្បញ្ញត្តិហិរញ្ញវត្ថុអនុវត្តលើថវិកាទូទៅនៃសហគមន៍អឺរ៉ុបនិងសន្ធានុក្រមស្តីពីថវិកា និងកម្មវិធីហិរញ្ញវត្ថុនៃគណៈកម្មការអឺរ៉ុប បានផ្តល់និយមន័យគោលការណ៍ឯកតភាពនេះថា ជាគោលការណ៍ដែលរាល់ចំណូល និងចំណាយរបស់សហគមន៍អឺរ៉ុបត្រូវបានព្យាករណ៍ និងអនុម័តរៀងរាល់ឆ្នាំតាមរយៈថវិកាសហគមន៍អឺរ៉ុប។

## ៦.វិសេសភាព (Specialty or Specification)

គោលការណ៍វិសេសភាពនៃថវិកា សំដៅជាពិសេសទៅដល់ឥណទានចំណាយ ដែលត្រូវបានលម្អិត និងធ្វើវិសេសកម្មទៅតាមតារាងថវិកាដែលត្រូវភ្ជាប់នឹងសេចក្តីព្រាងឱ្យសភាអនុម័ត និងដើម្បីអាចអនុវត្តបានក្នុងកម្រិតណាមួយ។ អ្វីដែលអនុម័តដោយសភា មិនអាចកែប្រែបានឡើយ លុះត្រាមានការកែតម្រូវតាមក្រោយដោយច្បាប់កែតម្រូវ។ ផ្អែកលើតារាងថវិកា និងគោលដៅឥណទានចំណាយ ដែលបានអនុម័តនេះ រដ្ឋាភិបាលយកទៅលម្អិតបន្តក្នុងរចនាសម្ព័ន្ធនៃមាតិកាថវិកា ក្នុងកម្រិតនៃសិទ្ធិអំណាចរបស់ខ្លួន ដែលមានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន។

## ៧.ភាពគ្រប់ជ្រុងជ្រោយ (Comprehensiveness)

ភាពគ្រប់ជ្រុងជ្រោយនៃថវិកា សំដៅដល់ថវិកាពេញលេញដែលឆ្លុះបញ្ចាំងគ្រប់ប្រភពចំណូល និងគ្រប់មុខសញ្ញាចំណាយ។ ចំពោះគោលការណ៍នេះគឺមិនអាចកាត់ផ្តាច់នូវគោលការណ៍វិស្សាសភាព (Sincerity) នោះទេ ដែលសំដៅដល់ថវិកាដែលត្រូវមានព័ត៌មាន (ឬទិន្នន័យ) ពេលលេញ គ្រប់ជ្រុងជ្រោយ ត្រឹមត្រូវ និងសង្គតិភាពដែលការពណ៌នាចំណូល និងចំណាយត្រូវមានភាពស្មោះត្រង់ និងសុចរិតភាព ដោយមិនបំផ្លើស ឬលាក់លៀមចំណូល ឬចំណាយណាមួយ។

## ៨.តុល្យភាព (Balance)

គោលការណ៍តុល្យភាពនៃថវិកា បានចែងយ៉ាងច្បាស់ក្នុងមាត្រា៤៧ មាត្រា៥២ និងមាត្រា៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨។ គោលការណ៍តុល្យភាពនៃថវិកានេះមានបញ្ចូល ឬមានភាពផ្សារភ្ជាប់គ្នាជាមួយនឹងគោលការណ៍ស្ថិរភាពនៃថវិកា ដែលសំដៅដល់ការរក្សាសមតារវាងចំណូល និងចំណាយ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងម៉ាក្រូសេដ្ឋកិច្ច។ មាត្រា៤៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានចែងថា÷ "សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ របាយការណ៍វិភាគពីនិន្នាការ និងការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និងការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវន្ត ពិសេសតុល្យភាពថវិកា។..."។

មាត្រា៥២ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ បានចែងថា "គ្មានវិសោធនកម្មណាមួយ លើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអាចត្រូវបានអនុញ្ញាតឱ្យធ្វើប៉ះពាល់ដល់តុល្យភាពនៃគម្រោងថវិកាដែលបានស្នើឡើង។ តុល្យភាពថវិកា ត្រូវបានធានាក្នុងមាត្រា៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ដោយបានចែងថា "នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញជាប្រកាសដើម្បីបង្កកមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ ក្នុងករណីដែលការបាត់តុល្យភាពនេះ មានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តក្នុងហិរញ្ញវត្ថុប្រចាំឆ្នាំ។"

## ៩.ការិយបរិច្ឆេទកំណត់មួយឆ្នាំ (Annuality)

គោលការណ៍នេះមានអត្ថន័យគន្លឹះនៅត្រង់ការអនុញ្ញាតរបស់សភា (តាមរយៈច្បាប់)

> *ថវិកាផ្អែកលើសមិទ្ធកម្ម គឺជាការរៀបចំថវិកា ទៅតាមគោលនយោបាយ និងផែនការអាទិភាពរបស់រដ្ឋាភិបាល និង ឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដែលត្រូវកំណត់លទ្ធផលគន្លឹះៗ ដែលជាបេសកកម្មត្រូវសម្រេចឱ្យបាន។*

ឱ្យរដ្ឋាភិបាលប្រមូលចំណូល និងអនុវត្តចំណាយមានសុពលភាពត្រឹមរយៈពេលមួយឆ្នាំតែប៉ុណ្ណោះ។ ការគ្រោង និងការអនុញ្ញាតលើប្រតិបត្តិការចំណូល-ចំណាយថវិកាសម្រាប់ឆ្នាំក្រោយ ត្រូវតែមានច្បាប់អនុញ្ញាតមួយផ្សេងទៀត ដែលគេហៅជាទូទៅថាច្បាប់ថវិកាប្រចាំឆ្នាំ ឬច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ អនុញ្ញាតមួយឆ្នាំម្តង មិនមែនមានន័យថាចាំបាច់ត្រូវតែចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ តាមឆ្នាំប្រតិទិននោះទេ ពោលគឺអាចចាប់ផ្តើមពេលណាក៏បានឱ្យតែមានគម្រប់មួយឆ្នាំនិងអាស្រ័យលើបរិបទជាក់ស្តែងនៅតាមប្រទេសនីមួយៗ។ ជាក់ស្តែង នៅប្រទេសមួយចំនួន ដូចជាករណីនៅអូស្ត្រាលី ឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី១ ខែកក្កដា និងបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា និងករណីនៅឥណ្ឌាគឺចាប់ផ្តើមនៅថ្ងៃទី១ ខែមេសា និងបញ្ចប់នៅថ្ងៃទី៣១ ខែមីនា។

បច្ចុប្បន្ន ជាឧត្តមានុវត្តន៍អន្តរជាតិ ការរៀបចំថវិកាប្រចាំឆ្នាំមាននូវក្របខណ្ឌពហុឆ្នាំមួយទៀត (ជាទូទៅ ៣ឆ្នាំ) ដែលមានភាពចាំបាច់ សម្រាប់គម្រោងទាំងឡាយដែលមិនអាចបញ្ចប់ក្នុងឆ្នាំបានហើយត្រូវការផែនការថវិកាក្នុងរយៈពេលមធ្យម។ គោលការណ៍ពហុឆ្នាំនៃថវិកានេះ មានតម្លៃគតិយុត្តអាស្រ័យលើប្រទេសនីមួយៗ ដែលករណីខ្លះជាច្បាប់អនុម័តដោយសភា ឬករណីផ្សេងទៀតអនុម័តត្រឹមកម្រិតរដ្ឋាភិបាលជាដើម។

**១០.តម្លាភាព** (Transparency)

តម្លាភាពសំដៅដល់ការបើកចំហ ដែលអាចធ្វើឡើងតាមរយៈការផ្សព្វផ្សាយ និងការអនុញ្ញាតឱ្យចូលរួម។ ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈការផ្តល់ជូនជាសាធារណៈនូវឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តថវិកា ក្រោមទម្រង់ជាឧបករណ៍ផ្សព្វផ្សាយ ឬក្រោមទម្រង់ជាកម្មវិធីផ្សព្វផ្សាយជាដើម។ ដោយឡែក ការចូលរួមអាចមានពីសំណាក់ប្រជាពលរដ្ឋ ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល និងសមាគមនានា ក្នុងដំណើរការនៃការរៀបចំ និងការអនុវត្តថវិកា។ តម្លាភាពជាគោលការណ៍មួយ ដែលតែងស្ថិតនៅជាចំណុចជជែកវែកញែកមិនចេះចប់មិនចេះហើយនៅក្នុងនីតិវិធីថវិកា ពីព្រោះតែឯកសារពាក់ព័ន្ធនឹងថវិកាគឺជាឯកសារដ៏មានសារៈសំខាន់បំផុតមួយរបស់រដ្ឋាភិបាល និងសម្រាប់សង្គមក៏ដូចជាប្រជាពលរដ្ឋ។

កម្រិតតម្លាភាពនៃថវិកាអាចមានភាពខុសគ្នាអាស្រ័យលើបទប្បញ្ញត្តិ នៃបណ្តាប្រទេសនីមួយៗ ហើយកម្រិតនោះត្រូវបានកត់ត្រាជាចំណុចសំខាន់មួយផងដែរ នៅក្នុងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសនីមួយៗ ក្នុងក្របខណ្ឌវាយតម្លៃអន្តរជាតិ PEFA។

**១១.សមិទ្ធកម្ម** (Performance)

សមិទ្ធកម្មជាពាក្យ ដែលត្រូវបានប្រើប្រាស់ច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះផ្តើមចេញពីការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានគោលដៅចុងក្រោយរបស់ខ្លួនគឺ គណនេយ្យភាពសមិទ្ធកម្ម ឬប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម នៅក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា។ សមិទ្ធកម្មសំដៅដល់ការផ្តោតលើលទ្ធផលជាមូលដ្ឋាននៃការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា។ ក្នុងន័យនេះ សមិទ្ធកម្មឬលទ្ធផលគឺជាគោលបំណងនៃថវិកា មិនមែនជាមធ្យោបាយ ឬសម្ភារៈដែលជាធាតុចូលនោះឡើយ។ ថវិកាផ្អែកលើសមិទ្ធកម្ម គឺការរៀបចំថវិកា ទៅតាមគោលនយោបាយ និងផែនការអាទិភាពរបស់រដ្ឋាភិបាល និងឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដែលត្រូវកំណត់លទ្ធផលគន្លឹះៗដែលជាបេសកកម្មត្រូវសម្រេចឱ្យបាន។ ក្នុងស្មារតីនេះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលត្រូវឆ្លើយតប និងរៀបចំបន្ស៊ីទៅនឹងរចនាសម្ព័ន្ធគោលនយោបាយ-កម្មវិធីនៃថវិកា ដើម្បីធានាគណនេយ្យភាពនៃការគ្រប់គ្រងថវិកាសំដៅសម្រេចបានសមិទ្ធកម្មតាមការគ្រោងទុកប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

គោលការណ៍សមិទ្ធកម្មនៃថវិកាធ្វើឱ្យការរៀបចំថវិកាត្រូវផ្លាស់ប្តូរទម្រង់ផងដែរ ពោលគឺមិនអាចប្រើប្រាស់វិធីសាស្ត្រចាស់ ឬប្រពៃណី ដែលជាការរៀបចំថវិកាផ្អែកលើតម្រូវការមធ្យោបាយហិរញ្ញវត្ថុ ឬសម្ភារៈ ដែលហៅជារួមថាធាតុចូល (Inputs) នោះឡើយ តែត្រូវរៀបចំទៅតាមគោលបំណងគោលនយោបាយ ឬលទ្ធផលដែលចង់បាន ឬហៅជារួមថាធាតុចេញ (Outputs) ឬការរៀបចំថវិកាកម្មវិធី (Program budgeting)៕■

*រៀបចំដោយ÷ ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃ អ.គ.ហ.*

# តួនាទីស្ថាប័ននីតិប្បញ្ញត្តិ និងការិយាល័យថវិកាក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖ របកគំហើញសម្រាប់កម្ពុជា

*នៅក្នុងប្រព័ន្ធនយោបាយប្រជាធិបតេយ្យ អង្គការនីតិប្បញ្ញត្តិជាស្ថាប័ននយោបាយដ៏មានសារៈសំខាន់បំផុតមួយ ព្រោះជាតួអង្គដែលត្រូវសម្រេច ត្រួតពិនិត្យ និងផ្តល់យោបល់កែតម្រូវទៅឱ្យរដ្ឋាភិបាលដែលជាអ្នកកាន់អំណាចអនុវត្ត។ តួនាទីនេះរឹតតែមានសារៈសំខាន់មិនអាចខ្វះបាននៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម ព្រោះជាទូទៅថ្វីត្បិតរដ្ឋាភិបាលជាអ្នកស្នើឡើងនូវគម្រោងថវិកានិងជាអ្នកអនុវត្តថវិកាក៏ពិតមែន ក៏ប៉ុន្តែថវិកាជាតិត្រូវអនុម័តឡើងដោយអង្គនីតិប្បញ្ញត្តិក្នុងទម្រង់ជាច្បាប់។*

ក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថាប័ននីតិប្បញ្ញត្តិមានតួនាទីដ៏សំខាន់ ពោលគឺជាមុខងារត្រួតពិនិត្យពិនិស្ស័យលើសំណើថវិកា ការអនុវត្ត ការកែសម្រួល និងសំណើទូទាត់ហិរញ្ញវត្ថុសាធារណៈ ពីអង្គនីតិប្រតិបត្តិ។ ជាកត្តាសត្យានុម័ត ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តមុខងាររបស់ខ្លួន ស្ថាប័ននីតិប្បញ្ញត្តិ ត្រូវមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់លើជំនាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ ថវិកា និងហិរញ្ញវត្ថុសាធារណៈ។ ស្ថាប័ននីតិប្បញ្ញត្តិ ត្រូវអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់ខ្លួន តាមជម្រើសមួយចំនួនដែលមានដូចជា**ទី១** ការរៀបចំនិងអនុវត្តកម្មវិធីកសាងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាលជាប្រចាំ និង**ទី២** ជាការបង្កើតរចនាសម្ព័ន្ធអចិន្ត្រៃយ៍បច្ចេកទេសក្នុងកម្រិតជាក់លាក់ណាមួយ ដើម្បីគាំទ្រក្នុងទិដ្ឋភាពបច្ចេកទេស ដែលមិនចំណុះឱ្យអាណត្តិផ្លាស់ប្តូរដែលកើតមាននៅរាល់ពេលបោះឆ្នោត។

នៅក្នុងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៣ កម្ពុជានឹងចាប់យកអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធភាព។ ដំណាក់កាលនីមួយៗវដ្តនៃថវិកានឹងមានភាពប្រែប្រួល ហើយអាទិភាពនៃការកែទម្រង់នឹងត្រូវផ្តោតសង្កត់ធ្ងន់ទៅលើវិមជ្ឈការដែលនឹងបង្កើនគណនេយ្យភាព និងសមិទ្ធកម្មរបស់ក្រសួង-ស្ថាប័ន ដែលទាមទារឱ្យមានការគិតគូរផងដែរលើការពង្រឹងតួនាទី និងការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័ននីតិប្បញ្ញត្តិ ទាំងកម្រិតបច្ចេកទេស កម្រិតគណៈកម្មការជំនាញ និងក្នុងកម្រិតរបស់សភាទាំងមូល។

ក្នុងស្មារតីនេះ ការសិក្សាស្រាវជ្រាវអំពី “តួនាទីស្ថាប័ននីតិប្បញ្ញត្តិ និងការិយាល័យថវិកាក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ របកគំហើញសម្រាប់កម្ពុជា” នឹងបង្ហាញអំពីបទពិសោធ និងឧត្តមានុវត្តន៍អន្តរជាតិលើតួនាទី សមត្ថកិច្ច និងនីតិវិធីនៃស្ថាប័ននីតិប្បញ្ញត្តិ នៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសនៅក្នុងដំណាក់កាលអនុម័តថវិកា។ ម្យ៉ាងទៀត ឯកសារស្រាវជ្រាវនេះក៏នឹងបង្ហាញអំពីដំណើរការនៃ “ការិយាល័យថវិកា” (Budget Bureau) ដែលជាការិយាល័យមួយស្ថិតក្នុងរចនាសម្ព័ន្ធរដ្ឋបាលនៃស្ថាប័ននីតិប្បញ្ញត្តិ ទទួលបន្ទុកលើការងារស្រាវជ្រាវ និងផ្តល់មតិយោបល់ជូនថ្នាក់ដឹកនាំ និងសមាជិកសភាដែលមានការពាក់ព័ន្ធ ទៅលើគម្រោងថវិកា និងឯកសារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល។

### ក.ការិយាល័យថវិកានៃស្ថាប័ននីតិប្បញ្ញត្តិ

ការិយាល័យថវិកា គឺជាឧទាហរណ៍មួយនៃការពង្រឹងសមត្ថភាពស្ថាប័ននីតិប្បញ្ញត្តិលើជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ព្រោះការិយាល័យនេះ គឺជារចនាសម្ព័ន្ធរដ្ឋបាលមួយដែលផ្តល់យោបល់ និងផ្តល់ការគាំទ្រផ្សេងទៀតដល់ការបំពេញមុខងាររបស់សមាជិកនៃស្ថាប័ននីតិប្បញ្ញត្តិ ក្នុងការពិនិត្យ និងអនុម័តទៅលើច្បាប់ថវិកាប្រចាំឆ្នាំ ឬការត្រួតពិនិត្យថវិកាប្រចាំឆ្នាំផងដែរ។ ការិយាល័យថវិកានៃស្ថាប័ននីតិប្បញ្ញត្តិ ជាឧត្តមានុវត្តន៍អន្តរជាតិឬនិន្នាការសកលមួយក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសាកល។ ជាក់ស្តែង ក្នុងឆ្នាំ២០១៤ អង្គការ OECD បានអនុម័តនូវ “អនុសាសន៍គន្លឹះនៃក្រុមប្រឹក្សាលើគោលការណ៍គ្រឹះនៃស្ថាប័នឯករាជ្យថវិកានីតិប្បញ្ញត្តិ (Independent Fiscal Institutions)”។ គោលការណ៍គ្រឹះទាំងនោះរួមមាន÷




១. ឯករាជ្យ និងមិនលំអៀង

២. ភាពជាអ្នកដឹកនាំត្រូវផ្អែកលើ គុណាធិបតេយ្យ (Merit) និងសមត្ថភាពបច្ចេកទេស ដោយមិនពាក់ព័ន្ធនឹងបក្សនយោបាយ

៣. មានអាណត្តិកិច្ចច្បាស់លាស់ ក្នុងការសិក្សា វិភាគ និងរៀបចំរបាយការណ៍

៤. មានធនធានផ្ទាល់ខ្លួន និងមានបន្ទាត់គណនេយ្យភាពផ្ទាល់ទៅនឹងស្ថាប័ននីតិប្បញ្ញត្តិ

៥. លទ្ធភាពក្នុងការចូលប្រើប្រាស់គ្រប់ទិន្នន័យពាក់ព័ន្ធដែលធានាដោយបទប្បញ្ញត្តិជាក់លាក់

៦. មានតម្លាភាពពេញលេញលើការរៀបចំ និងបោះផ្សាយរបាយការណ៍ និងការវិភាគជាសាធារណៈ

៧. ជាឧបករណ៍ទំនាក់ទំនងដ៏មានប្រសិទ្ធភាព ក្នុងការលើកកម្ពស់ការស្វែងយល់របស់សាធារណៈ អំពីការទទួលខុសត្រូវរដ្ឋាភិបាលលើកិច្ចការគ្រប់គ្រងធនធានសាធារណៈ

៨. អាចទទួលរងវាយតម្លៃដោយស្ថាប័នខាងក្រៅ។

### ក.១. ករណីប្រទេសហ្វីលីពីន

ក្នុងរដ្ឋបាលប្រទេសហ្វីលីពីន ការិយាល័យថវិកាជារចនាសម្ព័ន្ធមួយគាំទ្រប្រធានសភាតំណាងរាស្ត្រ ដែលត្រូវបានផ្លាស់ប្តូរឈ្មោះ និងកែសម្រួលរចនាសម្ព័ន្ធជាច្រើនលើក។ ក្នុងឆ្នាំ១៩៨៧ អង្គភាពនេះមានឈ្មោះថា ការិយាល័យផែនការសេដ្ឋកិច្ច (Congressional Economic Planning Service - CEPS)។ ក្នុងឆ្នាំ១៩៩០ ការិយាល័យនេះផ្លាស់ប្តូរឈ្មោះជាការិយាល័យផែនការ និងហិរញ្ញវត្ថុ (Congressional Planning and Budget Offic -CPBD)។ រហូតដល់ក្នុងឆ្នាំ២០១០ ការិយាល័យនេះផ្លាស់ប្តូរឈ្មោះទៅជា នាយកដ្ឋានស្រាវជ្រាវគោលនយោបាយ និងថវិកា (Congressional Policy and Budget Research Department - CPBRD )វិញ។

នាយកដ្ឋាន CPBRD ជារចនាសម្ព័ន្ធនៃដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានសភាតំណាងរាស្ត្រ។ នាយកដ្ឋាននេះដឹកនាំដោយអគ្គនាយកមួយរូប និងបែងចែកជាការិយាល័យចំនួន២ គឺការិយាល័យស្រាវជ្រាវសង្គម-សេដ្ឋកិច្ច (Socio-Economic Research Bureau-SERB) និងការិយាល័យស្រាវជ្រាវថវិកា និងសារពើពន្ធ (Budget and Tax Research Bureau-BTRB)។ ការិយាល័យស្រាវជ្រាវសង្គមសេដ្ឋកិច្ច ដឹកនាំដោយ ប្រធានមួយរូប (EPRS Executive Director) និងបំពេញកិច្ចការចំនួន២ គឺការងារស្រាវជ្រាវគោលនយោបាយសេដ្ឋកិច្ច និងការងារស្រាវជ្រាវគោលនយោបាយសង្គម។ រីឯការិយាល័យស្រាវជ្រាវថវិកា និងសារពើពន្ធដឹកនាំដោយប្រធានមួយរូប (BTRB Executive Director) និងបំពេញកិច្ចការចំនួន២ ដូចគ្នា គឺការងារស្រាវជ្រាវគោលនយោបាយថវិកា និងការងារស្រាវជ្រាវគោលនយោបាយសារពើពន្ធ។ ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាយកដ្ឋាន CPBRD នេះមានតួនាទីជាក់លាក់មួយចំនួន ដូចតទៅ÷

- សិក្សាស្រាវជ្រាវគោលនយោបាយពាក់ព័ន្ធនឹងសង្គម សេដ្ឋកិច្ច និងថវិកា ដើម្បីបម្រើការ គាំទ្រផ្អែកព័ត៌មានលើការរៀបចំច្បាប់ និងការត្រួតពិនិត្យ
- រៀបចំរបាយការណ៍វិភាគលើផែនការអភិវឌ្ឍជាតិ ផែនការថវិកាជាតិប្រចាំឆ្នាំ និងកម្មវិធី ឬគោលនយោបាយជាតិពាក់ព័ន្ធនានា
- ជួយគាំទ្រ សមាជិកសភា ក្នុងរបៀបវារៈ

រៀបចំនិងតាក់តែងច្បាប់

- ផ្តល់ព័ត៌មានបច្ចេកទេស ជូនសមាជិកសភា លើគោលនយោបាយសំខាន់ៗ ពាក់ព័ន្ធនឹងសង្គមកិច្ច សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងស្ថាប័ន
- រៀបចំការសិក្សានិងវិភាគស៊ីជម្រៅលើបច្ច័យនៃការតាក់តែងច្បាប់ និងបញ្ហានៃគោលនយោបាយជាក់លាក់ណាមួយ
- ជាជំនួយបច្ចេកទេសសម្រាប់អ្នកនាំពាក្យនៃស្ថាប័នសភា និងគណៈកម្មការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍ (House Panel for the Legislative Executive Development Advisory Council é LEDAC)
- សហការជាមួយនឹងស្ថាប័នស្រាវជ្រាវដៃគូអភិវឌ្ឍ ស្ថាប័នសាធារណៈ និងឯកជននានា ក្នុងកិច្ចសន្ទនា គោលនយោបាយ ការចែករំលែកចំណេះដឹង និងការកសាងសមត្ថភាព។

## ក.២. ករណីប្រទេសកូរ៉េខាងត្បូង

ការិយាល័យថវិកានៃរដ្ឋសភា គឺជាអង្គភាពបង្កើតឡើងដោយមាត្រា២១ និង២២ នៃច្បាប់ស្តីពីរដ្ឋសភា (National Assembly Act) នៅខែតុលា ឆ្នាំ២០០៣។ អង្គភាពនេះគាំទ្រដល់ស្ថាប័ននីតិប្បញ្ញត្តិ និងមានគោលដៅធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃតួនាទីអង្គនីតិប្បញ្ញត្តិ ដើម្បីពិនិត្យ និងតាមដាន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការិយាល័យនេះ មានចក្ខុវិស័យ÷ “ក្លាយជាមជ្ឈមណ្ឌលគំនិត (Think tank) លើកិច្ចការហិរញ្ញវត្ថុសាធារណៈ ដែលបម្រើដល់រដ្ឋសភានៃប្រទេសកូរ៉េខាងត្បូង និងប្រជាជន” ដោយមានបេសកកម្មចំនួន ៣ គឺ÷ (១). ការពិនិត្យស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយលើការវិភាគហិរញ្ញវត្ថុ (Fiscal analysis) និងគោលបំណង នៃកម្មវិធីហិរញ្ញវត្ថុ (Objective fiscal program) (២). ប្រសិទ្ធភាពនៃការវិភាគជាក់លាក់លើការព្យាករណ៍ទំហំសារពើពន្ធ និងចំណាយ (៣). ការវិភាគដោយប្រសិទ្ធភាពលើការព្យាករណ៍សេដ្ឋកិច្ច។ តួនាទីរបស់ការិយាល័យនេះ មានចំនួន៥ ជាគន្លឹះ ដែលរួមមាន ការវិភាគថវិកា (Budget analysis), ការសិក្សា និងរៀបចំគម្រោងថវិកា, ការព្យាករណ៍, ការវាយតម្លៃ និងការស្រាវជ្រាវ។

ជារចនាសម្ព័ន្ធ ការិយាល័យថវិកា ស្ថិតក្រោមការដឹកនាំ របស់ប្រធានរដ្ឋសភា (Speaker) ហើយស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធាន (Chief) មួយរូប និងបែងចែកការិយាល័យបច្ចេកទេសចំនួន៤ រួមមាន÷ ១) ការិយាល័យផែនការ និងគ្រប់គ្រង ២) ការិយាល័យវិភាគថវិកា ៣) ការិយាល័យព្យាករណ៍ និងវិភាគសារពើពន្ធ និង៤) ការិយាល័យវិភាគសេដ្ឋកិច្ច។

## ក.៣. ករណីប្រទេសថៃ

ការិយាល័យថវិកានៃរដ្ឋសភារបស់ប្រទេសថៃ (Parliamentary Budget Office-PBO) ត្រូវបានបង្កើតឡើងតាមរយៈមាត្រា ២៦ នៃប្រកាសរបស់រដ្ឋសភា (Parliament declaration) ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីផ្នែកចំណុះលេខាធិការដ្ឋាននៃរដ្ឋសភា។ រចនាសម្ព័ន្ធនៃការិយាល័យនេះ បែងចែកការិយាល័យថវិការបស់រដ្ឋសភាថៃ ត្រូវបានបែងចែកចេញជា៥ ផ្នែក ដែលរួមមាន÷ ផ្នែកវិភាគផ្នែកម៉ាក្រូសេដ្ឋកិច្ច, ផ្នែកវិភាគថវិកា, ផ្នែកវិភាគគម្រោងវិនិយោគសាធារណៈ, ផ្នែកផ្សព្វផ្សាយនិងព័ត៌មាន, និងផ្នែកគាំទ្រកិច្ចប្រតិបត្តិការរបស់រដ្ឋសភា។ តួនាទីនៃការិយាល័យថវិកានៃរដ្ឋសភាថៃ ត្រូវបានកំណត់ដូចតទៅ÷

- សិក្សា វិភាគ ស្រាវជ្រាវ ព្រមទាំងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងថវិកា ហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចហិរញ្ញវត្ថុរយៈពេលមធ្យម និងរយៈពេលវែង
- សិក្សា ស្រាវជ្រាវវិភាគ ព្រមទាំងរៀបចំរបាយការណ៍លើការងារពាក់ព័ន្ធនឹងថវិកា របាយការណ៍ចំណាយដោយឆ្លុះបញ្ចាំងនឹងគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ
- សិក្សា និងវិភាគលើចំណាយរបស់រដ្ឋាភិបាលដោយផ្អែកលើគោលនយោបាយដែលបានកំណត់ និងមូលដ្ឋានច្បាប់ ដើម្បីរៀបចំរបាយការណ៍ជូនរដ្ឋសភា
- សិក្សា វិភាគ និងប៉ាន់ប្រមាណទំហំប្រាក់ចំណូល ឬផលប្រយោជន៍នានា ដែលជាសមិទ្ធកម្មនៃផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍដោយអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុរដ្ឋ និងវិន័យថវិកា ដើម្បីពិចារណាលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ
- ពិគ្រោះយោបល់ក្នុងដំណើរការរៀបចំថវិកា ឬបញ្ហានានាដែលគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនៃរដ្ឋសភា និងព្រឹទ្ធសភា
- រៀបចំឯកសារសម្រាប់ពិចារណា លើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ដើម្បីគាំទ្រការអនុវត្តរបស់គណៈកម្មការ អនុគណៈកម្មការ និងសមាជិកនៃរដ្ឋសភា និងព្រឹទ្ធសភា
- បង្កើតមូលដ្ឋានទិន្នន័យនៃសេដ្ឋកិច្ចហិរញ្ញវត្ថុ និងថវិការបស់រដ្ឋទាក់ទងនឹងការពិចារណាលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ និងផ្សារភ្ជាប់ព័ត៌មានជាមួយអង្គភាពនានា
- រៀបចំនិងផ្សព្វផ្សាយលទ្ធផលនៃការសិក្សាអំពីសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងថវិកាដល់គណៈកម្មការ អនុគណៈកម្មការ និងសមាជិកនៃរដ្ឋសភា និងព្រឹទ្ធសភា និងសាធារណជន។

## ក.៤. ករណីប្រទេសអូស្ត្រាលី

ក្នុងប្រទេសអូស្ត្រាលី គោលគំនិតនៃការរៀបចំការិយាល័យថវិកាក្នុងស្ថាប័ននីតិប្ប-

ញត្តិ ដែលអាចបំពេញការងារដោយឯករាជ្យ បានលេចឡើងតាំងពីអំឡុងឆ្នាំ១៩៨០ មកម្ល៉េះ ហើយរហូតដល់ឆ្នាំ២០០៥ ទើបគោលគំនិតនេះបានក្លាយជាប្រធានបទពិភាក្សាក្នុងស្ថាប័នជួររដ្ឋាភិបាលទាំងមូល។ ការិយាល័យថវិកាសភា (Parliamentary Budget Office-PBO) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ តាមរយៈវិសោធនកម្មនៃច្បាប់ស្តីពីមុខងារភារកិច្ចសភា (Parliamentary Service Act) ឆ្នាំ១៩៩៩ ដើម្បីផ្តល់មតិប្រឹក្សាដោយឯករាជ្យនិងមិនលំអៀងជូនស្ថាប័នសភាទាំង២ថ្នាក់លើ កិច្ចការវិភាគថវិកា គោលនយោបាយហិរញ្ញវត្ថុ និងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៃសេចក្តីព្រាងឯកសារថវិកា។ ប្រធានការិយាល័យថវិកាសភា (Parliamentary Budget Officer) ត្រូវបានតែងតាំងដោយមានការឯកភាពពីគណៈកម្មការចម្រុះស្តីពីគណនីសាធារណៈ និងសវនកម្ម (Joint Committee of Public Account and Audit)។ ជារចនាសម្ព័ន្ធ ការិយាល័យថវិកាសភានៃប្រទេសអូស្ត្រាលី ដឹកនាំដោយប្រធាន ១រូប និងបែងចែកជា ៣ផ្នែកធំៗ គឺ÷ ផ្នែករៀបចំគម្រោងថវិកានិងវិភាគថវិកា (Parliamentarian Costing and Analysis Division), ផ្នែកវិភាគគោលនយោបាយហិរញ្ញវត្ថុ (Fiscal Policy Analysis Division) និងផ្នែកយុទ្ធសាស្ត្រសាជីវកម្ម (Corporate Strategy Branch)។

យោងតាមវិសោធនកម្មច្បាប់ស្តីពីមុខងារភារកិច្ចសភាខាងលើ ការិយាល័យថវិកាសភា មានតួនាទីដូចជា÷

- រៀបចំគោលនយោបាយចំណាយ តាមសំណើរបស់ប្រធាន និងសមាជិកព្រឹទ្ធសភា ដោយអាចរក្សាជាការសម្ងាត់ក្នុងករណីមានការស្នើសុំដោយប្រធាន ឬសមាជិកព្រឹទ្ធសភានោះ ក្នុងអាណត្តិនៃសភាតំណាងរាស្ត្រ (Outside the caretaker period)
- រៀបចំគោលនយោបាយចំណាយ តាមសំណើរបស់ប្រធាន និងសមាជិកព្រឹទ្ធសភា ឬសមាជិកគណបក្សនយោបាយដែលមានសិទ្ធិ តែគោលនយោបាយនោះត្រូវផ្សព្វផ្សាយជាសាធារណៈ នៅក្នុងអំឡុងពេលរៀបចំអាណត្តិថ្មី នៃសភាតំណាងរាស្ត្រ (Inside the caretaker period) មានន័យថាមុននឹងអាណត្តិថ្មីនៃសភាតំណាងរាស្ត្រត្រូវបានរៀបចំរាល់សំណើរៀបចំសិក្សាគោលនយោបាយចំណាយមិនអាចរក្សាការសម្ងាត់បានឡើយ
- រៀបចំការឆ្លើយតបពាក់ព័ន្ធនឹងថវិកាជូនព្រឹទ្ធសភា និងសមាជិកដោយអាចរក្សាការសម្ងាត់តាមការស្នើសុំ
- រៀបចំការឆ្លើយតបទៅកាន់គណៈកម្មការសភាទាំងពីរថ្នាក់ តាមការស្នើសុំជាសាធារណៈ
- រៀបចំរបាយការណ៍ស្តីពីផលប៉ះពាល់នៃថវិកា ផ្អែកលើគោលនយោបាយនៃគណបក្សជាប់ឆ្នោត បន្ទាប់ពីការបោះឆ្នោតសាកលត្រូវបានបញ្ចប់
- រៀបចំ ផ្តួចផ្តើម គម្រោងសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងថវិកា និងការរៀបចំគោលនយោបាយហិរញ្ញវត្ថុរឺឯលទ្ធផលនៃការស្រាវជ្រាវកំណត់ជាឯកសារសាធារណៈ។

*ស្ថាប័ននីតិប្បញ្ញត្តិ មានតួនាទីសំខាន់ក្នុងដំណាក់កាលទី៣ **"ការអនុម័តថវិកា"** ដែលត្រូវពិនិត្យពិនិស្ស័យ លើសេចក្តីព្រាងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់*

### ក.៥. ករណីប្រទេសបារាំង

ក្រុមប្រឹក្សាជាន់ខ្ពស់នៃហិរញ្ញវត្ថុសាធារណៈ (Haut Conseil des finances publiques-HCFP) គឺជាស្ថាប័នមួយដាច់ដោយឡែកពីស្ថាប័ននីតិប្រតិបត្តិនិងស្ថាប័ននីតិប្បញ្ញត្តិ ដែលដើរតួនាទីជាការិយាល័យថវិកាក្នុងរដ្ឋាភិបាលប្រទេសបារាំង ដែលចំណុចនេះមានលក្ខណៈដោយឡែកខុសពីករណីភាគច្រើនដែលឃើញមាននៅក្នុងបណ្តាប្រទេសដែលត្រូវបានសិក្សាខាងលើ។ ស្ថាប័ននេះត្រូវបានបង្កើតឡើងតាមរយៈច្បាប់អង្គការស្តីពីការរៀបចំផែនការ និងអភិបាលកិច្ចនៃហិរញ្ញវត្ថុចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២[9]។ ក្រុមប្រឹក្សានេះដឹកនាំដោយប្រធាន ១រូប មានសមាជិក ១០រូប និងមានលេខាធិការប្រមាណ ៥រូប។ ប្រធាន និងសមាជិក មានសមាសភាពមកពី ៦ ស្ថាប័នផ្សេងៗពីគ្នាដូចតទៅ÷

- ប្រធាន ១រូប គឺជាប្រធាននៃតុលាការគណនី (Court of Auditors)
- សមាជិក ៤រូប មកពីអង្គចៅក្រមនៃតុលាការគណនី ដែលជ្រើសតាំងដោយប្រធានតុលាការគណនី
- សមាជិកចំនួន ៥រូប ជាអ្នកជំនាញបច្ចេកទេសក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈដែលជ្រើសតាំងដោយប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា ប្រធានគណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភា និងព្រឹទ្ធសភា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន (Conseil "conomique, social et environnemental) និង
- សមាជិក ១រូប ជាអគ្គនាយកនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ (Institut national de la statistique et des "tudes "conomiques -INSEE)។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃហិរញ្ញវត្ថុសាធារណៈ (HCFP) មានតួនាទីផ្តល់មតិយោបល់លើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងហិរញ្ញវត្ថុ

[9] Loi Organique du 17 D"cembre 2012 relative » la Programmation et » la Gouvernance des Finances Publiques

សាធារណៈ មុននឹងត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ។ នីតិវិធីនៃការផ្តល់មតិយោបល់របស់ស្ថាប័ននេះជា កាតព្វកិច្ចតម្រូវដោយច្បាប់ តែរាល់មតិយោបល់ដែលស្នើឡើងដោយក្រុមប្រឹក្សាពុំតម្រូវឱ្យរដ្ឋាភិបាលត្រូវតែគោរពអនុវត្តតាមនោះឡើយ (non-binding)។ មតិប្រឹក្សារបស់ HCFP ត្រូវបានកំណត់ឱ្យបោះផ្សាយជាសាធារណៈ។ សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ដែលតម្រូវឱ្យមានមតិយោបល់របស់ HCFP រួមមានដូចតទៅ៖

- ច្បាប់ស្តីពីកម្មវិធីហិរញ្ញវត្ថុសាធារណៈ (Public Finance Programming Laws)
- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញប្បទានសន្តិសុខសង្គម (Draft Financial Law and Social Security Financing Laws)
- វិសោធនកម្មច្បាប់ហិរញ្ញវត្ថុ និងច្បាប់សន្តិសុខសង្គម (Amended Financial Laws and Amended Social Security Laws)
- ច្បាប់ទូទាត់ថវិកា (Budget Settlement Laws)
- កម្មវិធីស្ថិរភាព (Stability Programmes) សម្រាប់គណៈកម្មការអឺរ៉ុប និងក្រុមប្រឹក្សាអឺរ៉ុប។

**ខ.ស្ថាប័ននីតិប្បញ្ញត្តិកម្ពុជាក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

វដ្តនៃថវិកា ត្រូវបានបែងចែកជា ៣ ដំណាក់កាល រួមមាន៖ ១)"**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា**" ២) "**ការរៀបចំកញ្ចប់ថវិកា**" និង៣) "**ការអនុម័តថវិកា**"។ ស្ថាប័ននីតិប្បញ្ញត្តិ មានតួនាទីស្នូលក្នុងដំណាក់កាលទី៣ "**ការអនុម័តថវិកា**" ដែលត្រូវពិនិត្យពិនិស្ស័យលើសេចក្តីព្រាងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់។ ជារចនាសម្ព័ន្ធ សមាជិករដ្ឋសភា និងព្រឹទ្ធសភា បែងចែកជាគណៈកម្មការបច្ចេកទេសមួយចំនួន ហើយគណៈកម្មការ ដែលទទួលខុសត្រូវលើកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ឬគណៈកម្មការទី២។ ជានីតិវិធី ស្ថាប័នទាំងពីរមានលទ្ធភាពរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ជាសាធារណៈពីភាគីពាក់ព័ន្ធ រួមទាំងសមាជិករាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលផងដែរ។ យ៉ាងណាមិញ ផ្នែកតាមរចនាសម្ព័ន្ធជាធរមាន ស្ថាប័ននីតិប្បញ្ញត្តិទាំងពីរកម្រិតក៏មាននូវអង្គភាពស្រាវជ្រាវ និងប្រឹក្សាយោបល់ដែលស្ថិតក្រោមរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានក្នុងន័យគាំទ្រជាជំនួយបច្ចេកទេសលើការងារស្រាវជ្រាវ និងប្រឹក្សាយោបល់ជូនគណៈកម្មការបច្ចេកទេស ជាឧទាហរណ៍ អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងអគ្គនាយកដ្ឋានស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ វិសាលភាពនៃសមត្ថកិច្ចស្រាវជ្រាវ និងប្រឹក្សាយោបល់របស់អង្គភាពទាំងពីរមានលក្ខណៈទូលំទូលាយ ហើយរចនាសម្ព័ន្ធជានាយកដ្ឋាន ឬការិយាល័យនៃអគ្គនាយកដ្ឋានទាំងពីរ ក៏ពុំមាននូវនាយកដ្ឋាន ឬការិយាល័យដែលទទួលបន្ទុកលើការងារសេដ្ឋកិច្ច ថវិកា និងហិរញ្ញវត្ថុសាធារណៈជាក់លាក់ឡើយ។

តាមរយៈការវាយតម្លៃដោយប្រើប្រាស់ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ ឃើញថា តួនាទីនៃស្ថាប័ននីតិប្បញ្ញត្តិលើការត្រួតពិនិត្យ និងពិនិស្ស័យថវិកានៅមានកម្រិតនៅឡើយ ជាពិសេសគឺលើវិសាលភាពនៃការអនុម័តថវិកា និងអនុសាសន៍ របស់ស្ថាប័ននីតិប្បញ្ញត្តិលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុ។ ជាសត្យានុម័ត មានកត្តាចំនួន ២ យ៉ាងតិច ដែលនាំឱ្យលទ្ធផលនៃការ



វាយតម្លៃស្ថិតក្នុងកម្រិតខាងលើដែលរួមមាន ទី១ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានកម្រិតវិសាលភាពនៃការអនុម័តថវិការបស់ស្ថាប័ននីតិប្បញ្ញត្តិតែលើសេចក្តីព្រាងឯកសារថវិកាប្រចាំឆ្នាំតែប៉ុណ្ណោះ និងទី២ សមត្ថភាពបច្ចេកទេសរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងរចនាសម្ព័ន្ធគាំទ្រលើជំនាញហិរញ្ញវត្ថុសាធារណៈ នៅមានកម្រិតដែលត្រូវយកចិត្តទុកដាក់អភិវឌ្ឍជាបន្ត។

សរុបមក ស្របតាមទិសដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទីស្ថាប័ននីតិប្បញ្ញត្តិកាន់តែមានសារៈសំខាន់ទ្វេឡើង ព្រោះស្ថាប័នកំពូលនេះគឺជាតួអង្គស្នូលមួយនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធថវិការបស់កម្ពុជា។ ក្នុងន័យនេះ ការកសាងសមត្ថភាពជំនាញបច្ចេកទេស និងការអភិវឌ្ឍស្ថាប័នពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងសមិទ្ធកម្ម កាន់តែគួរត្រូវបានចាត់ទុកជាសកម្មភាពអាទិភាពមួយរបស់ស្ថាប័ននេះ ដើម្បីគាំទ្រការអនុវត្តមុខ-



ងាររបស់ខ្លួនស្របទៅតាមទិសដៅកែទម្រង់របស់រាជរដ្ឋាភិបាល។

### គ. របកគំហើញ

លទ្ធផលនៃការសិក្សានៃឧត្តមានុវត្តន៍ជាអន្តរជាតិ និងករណីសិក្សាតាមប្រទេសទាំង៥ ខាងលើ ពាក់ព័ន្ធនឹងតួនាទីស្ថាប័ននីតិប្បញ្ញត្តិ និងការិយាល័យថវិកាក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានផ្តល់ឱ្យនូវរបកគំហើញមួយចំនួន ដែលអាចធ្វើជាមូលដ្ឋាននៃគតិពិចារណាមួយចំនួនដូចត-ទៅ÷

**១.វិសាលភាពនៃការត្រួតពិនិត្យ និងពិនិ-ស្ម័យលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ÷** ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ បានកំណត់ថាការត្រួតពិនិត្យ និងពិនិស្ម័យលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនៃស្ថាប័ននីតិប្បញ្ញត្តិ ផ្តោតតែលើព័ត៌មានពាក់ព័ន្ធនឹងថវិកា ការខ្ចី និងការធានារបស់រដ្ឋក្នុងឆ្នាំតែប៉ុណ្ណោះ។ ជាអនុ-សាសន៍ វិសាលភាពនេះគួរពិនិត្យលទ្ធភាពក្នុងការពង្រីកឱ្យមានភាពគ្រប់ជ្រុងជ្រោយលើសេចក្តីព្រាងឯកសារថវិកាប្រចាំឆ្នាំទាំងមូល មានន័យថាស្ថាប័ននីតិប្បញ្ញត្តិគួរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងពិនិស្ម័យផងដែរ លើក្របខណ្ឌរយៈពេលមធ្យមផ្សេងទៀតសំខាន់ៗ រួមមានក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យមជាដើម ។ គួរបញ្ជាក់ថា ការពង្រីកវិសាលភាពខាងលើជាឧត្តមានុវត្តន៍អន្តរជាតិជារួម និងក៏ជាអនុសាសន៍ ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍វាយ-តម្លៃក្របខណ្ឌចំណាយ និងគណនេយ្យ-ហិរញ្ញវត្ថុឆ្នាំ២០២០ ផងដែរ។

**២. បង្កើតការិយាល័យ ឬអង្គភាពទទួលបន្ទុកលើការងារថវិកា÷** បច្ចុប្បន្ន ស្ថាប័ននីតិប្បញ្ញត្តិ ជាពិសេស រដ្ឋសភា មានរចនា-សម្ព័ន្ធស្រាវជ្រាវមួយចំនួនជាសេនាធិការ ក៏ប៉ុន្តែ មិនមាននូវអង្គភាពច្បាស់លាស់ណាមួយដែលទទួលបន្ទុកជាក់លាក់លើការងារថវិកា ឬការងារពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះឡើយ។ ជាអនុសាសន៍ គួរមានការសិក្សាលទ្ធភាពលើការបង្កើតអង្គភាពបែបនេះ ដើម្បីជាសេនាធិការបច្ចេកទេសដ៏រឹងមាំមួយជូនស្ថាប័ននីតិប្បញ្ញត្តិ។ ការរៀបចំការិយាល័យថវិកានេះ អាចបត់បែនទៅតាមបរិការណ៍របស់រដ្ឋបាល និងពុំចាំបាច់ជារចនាសម្ព័ន្ធរឹងនៃស្ថាប័ននីតិប្បញ្ញត្តិនោះឡើយ ឧទា-ហរណ៍ ក្រុមប្រឹក្សាជាន់ខ្ពស់នៃហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសបារាំង ត្រូវបានបង្កើតឡើងដែលរចនាសម្ព័ន្ធឯករាជ្យ ក្រៅពីស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិ។

**៣. អភិវឌ្ឍសមត្ថភាពស្ថាប័ន÷** ការពង្រឹងសមត្ថភាពស្ថាប័ននីតិប្បញ្ញត្តិ គួរត្រូវបានចាប់ផ្តើមរៀបចំពីពេលនេះទៅ និងចាត់ទុកជាអាទិភាពខ្ពស់មួយ ដោយហេតុថាស្ថាប័នកំពូលនេះនឹងដើរតួនាទីកាន់តែសំខាន់ក្នុងការត្រួតពិនិត្យ និងពិនិស្ម័យថវិកាប្រចាំឆ្នាំ ព្រោះការអនុម័តនឹងត្រូវផ្អែកលើឯកសារបន្ថែមដូចជា ក្របខណ្ឌ និងព័ត៌មានសមិទ្ធ-កម្ម ក្របខណ្ឌគោលនយោបាយអភិវឌ្ឍវិស័យនៃក្រសួង-ស្ថាប័ន ជាដើម។

**៤. ផែនការសកម្មភាពកែទម្រង់ក្នុងយុទ្ធ-សាស្ត្រកែទម្រង់ប្រព័ន្ធថវិកា÷** ដូចបានលើកឡើងខាងលើ យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០២១-២០២៥ គ្របដណ្តប់ទាំងដំណាក់កាលអនុម័តផងដែរ បានន័យថាមានការពាក់ព័ន្ធនឹងតួនាទី នៃស្ថាប័ននីតិប្បញ្ញត្តិក្នុងការងារនេះ ក៏ប៉ុន្តែផែនការសកម្មភាពលម្អិត នៃយុទ្ធសាស្ត្រនេះមិនមានបញ្ជាក់អំពីផែនការសកម្មភាពកែទម្រង់ដែលស្ថាប័ននីតិប្បញ្ញត្តិត្រូវរៀបចំ និងចូលរួមអនុវត្តនោះឡើយ។ ចំណុចនេះអាចមិនត្រូវបានលើកឡើងដោយសារកត្តាឯករាជ្យ-ភាពរបស់ស្ថាប័ននីតិប្បញ្ញត្តិ ដែលគួរមានការពិនិត្យអំពីកិច្ចសម្របសម្រួល និងកិច្ច-សហការ ដើម្បីស្វែងរកដំណោះស្រាយរួមមួយរវាងអង្គការនីតិប្បញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ៕■

*រៀបចំដោយ÷ ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែន-សារពើពន្ធនៃ អ.គ.ហ.*

# បច្ចុប្បន្នភាពនៃមុខងារសវនកម្មផ្ទៃក្នុង

*អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) ជាអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) មានមុខងារ និងភារកិច្ចអនុលោមតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមុខងារសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ។*

មុខងារសំខាន់នៃសវនកម្មផ្ទៃក្នុង គឺវាយតម្លៃដោយឯករាជ្យ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ដំណើរការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិង អភិបាលកិច្ច របស់ក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីរួមចំណែកធានាឱ្យគោលបំណង និងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួនសម្រេចបានដោយជោគជ័យតាមការកំណត់។

សវនកម្មផ្ទៃក្នុង គឺជាសកម្មភាពពិគ្រោះយោបល់ និងការអះអាងដោយឯករាជ្យ មិនលម្អៀង ដើម្បីផ្ដល់តម្លៃបន្ថែម និងកែលម្អប្រតិបត្តិការរបស់អង្គភាព ដែលជួយឱ្យអង្គភាពសម្រេចបាន នូវគោលបំណងរបស់ខ្លួនដោយប្រើប្រាស់អភិក្រមជាប្រព័ន្ធមានជំនាញត្រឹមត្រូវក្នុងការវាយតម្លៃ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុង និងដំណើរការអភិបាលកិច្ចល្អ។

ជាផ្លែផ្កា នៃការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងសម្រេចបាននូវសមិទ្ធផលសំខាន់ៗ មានជាអាទិ÷

- ក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈបានដំណើរការនូវមុខងារសវនកម្មផ្ទៃក្នុងសរុបចំនួន៤៣ អង្គភាព (ក្រសួង ២៨ ស្ថាប័ន ៣ និងសហគ្រាស ១២)
- រៀងរាល់ឆ្នាំ **អ.ស.ក.** បានចុះអនុវត្តសវនកម្ម នៅតាមអង្គភាពក្រោមឱវាទ កសហវ. ទាំងថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋានជាមធ្យមក្នុងមួយឆ្នាំមានចំនួន១០០ គោលដៅ
- រៀងរាល់ឆ្នាំ **អ.ស.ក.** បានចុះត្រួតពិនិត្យប្រសិទ្ធភាពមុខងារ នៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួង-ស្ថាប័នចំនួន៨ ជាមួយការផ្ដល់យោបល់កែលម្អបន្ថែមដោយបានផ្ដល់អនុសាសន៍កែលម្អប្រមាណ៥០០ អនុសាសន៍ ក្នុងនោះមាន ៦០% ត្រូវបានអនុវត្តកែលម្អពេញលេញពីសវនដ្ឋាន (អង្គភាពរងសវនកម្ម)
- **អ.ស.ក.** បានជួយពង្រឹងការអនុវត្តសវនកម្មផ្ទៃក្នុងដល់អង្គភាពសវនកម្មផ្ទៃក្នុង នៃក្រសួង-ស្ថាប័ន តាមរយៈការរួមចំណែកផ្ដល់យោបល់កែលម្អលើរបាយការណ៍សវនកម្មផ្ទៃក្នុងតាមស្តង់ដារ ដែលបានផ្ញើមក កសហវ. ជាមធ្យមចំនួន២០ របាយការណ៍ក្នុងមួយឆ្នាំ
- **អ.ស.ក.** បានជំរុញការកែលម្អតាមអនុសាសន៍ ក្នុងរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ពាក់ព័ន្ធនឹងសមត្ថភាព កសហវ. តាមរយៈលិខិតជំរុញ យ៉ាងតិចសម្រេចបានចំនួន៨ ក្នុងមួយឆ្នាំ
- ក្នុងនាមជាអ្នកនាំមុខលើជំនាញសវនកម្មផ្ទៃក្នុង **អ.ស.ក.** បានរួមចំណែកបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពសវនករផ្ទៃក្នុង



របស់រាជរដ្ឋាភិបាលតាមរយៈវគ្គសិក្ខាសាលា យ៉ាងហោច ១វគ្គ ក្នុង ១ឆ្នាំ ដែលមានសិក្ខាកាមចូលរួមជាមធ្យមប្រមាណ ១៣០នាក់ និងត្រូវបានជួយបណ្តុះបណ្តាលលើជំនាញសវនកម្មជាក់លាក់ផ្សេងទៀត ក្រោមរូបភាពស្នើសុំដោយឡែកពីក្រសួង-ស្ថាប័នសាមីផ្ទាល់។

**❋ ការពង្រីកបន្ថែមមុខងារសវនកម្មថ្មី**

ក្នុងបរិការណ៍នៃការវិវត្តសេដ្ឋកិច្ច-សង្គម និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងស្របតាមគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ប្លុក ២ ក្នុងខឿនទី៤ “**ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម**” អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានពង្រីកបន្ថែមនូវប្រភេទសវនកម្មថ្មីៗ ចំនួន ៣ ដែលគាំទ្រដោយ÷

-ប្រកាសលេខ៥៤២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ និងស្តង់ដារសវនកម្មសមិទ្ធកម្ម,

-ប្រកាសលេខ៥៤៣ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន និង

-ប្រកាសលេខ៦៧៣ សហវ.ប្រក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំសវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...សហវ....ប្រក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំសវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញ ប្រកាសលេខ ១៥៤៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ១ ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
2, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone: (+855) 23 890 666

គោលការណ៍ណែនាំទាំងនេះត្រូវបានផ្សព្វផ្សាយជូនសវនករផ្ទៃក្នុងនៃក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈតាមរយៈសិក្ខាសាលារួចរាល់ ដែលមានសិក្ខាកាមចូលរួមសរុបប្រមាណចំនួន ៤៨០នាក់ និងបានអនុវត្តសវនកម្មសាកល្បងលើគោលដៅមួយចំនួន រួមមាន÷

●គោលការណ៍ណែនាំ និងស្តង់ដារសវនកម្មសមិទ្ធកម្ម÷ នៅក្នុងឆ្នាំ២០២០ បានចុះសវនកម្មលើសមិទ្ធកម្មសាកល្បងចំនួន ២គោលដៅគឺ (១). សវនកម្មលើប្រធានបទ “គម្រោងអង្កេតសហគ្រាសនៅអគ្គនាយកដ្ឋានពន្ធដារ” និង (២). សវនកម្មលើប្រធានបទ “គម្រោងស្វ័យប្រវត្តិកម្ម នៃការគ្រប់គ្រងការងារពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ” ហើយនៅក្នុងឆ្នាំ២០២១ កំពុងអនុវត្តសាកល្បងបន្ថែមទៀតក្រោមការណែនាំពីទីប្រឹក្សាក្នុងស្រុកនៅក្រសួង-ស្ថាប័នចំនួន ៦ ដែលរួមមានក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

●គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន÷ ក្នុងឆ្នាំ២០២០ បានចុះអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បងចំនួន ១គោលដៅ លើប្រធានបទ “ប្រសិទ្ធភាពស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រង

*មុខងារសំខាន់នៃសវនកម្មផ្ទៃក្នុង គឺវាយតម្លៃដោយឯករាជ្យ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ដំណើរការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចរបស់ក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីរួមចំណែកធានាឱ្យគោលបំណង និងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួនសម្រេចបានដោយជោគជ័យតាមការកំណត់។*

ការងារពន្ធដារ” ហើយនៅក្នុងឆ្នាំ២០២១ កំពុងអនុវត្តសាកល្បងនៅក្រសួង-ស្ថាប័នចំនួន ១០បន្ថែមទៀត រួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងព័ត៌មាន, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងយុត្តិធម៌, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, ក្រសួងទេសចរណ៍, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការ។

ដោយឡែក ចំពោះការធ្វើសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក៏ត្រូវបានអនុវត្តសាកល្បង និងពង្រឹងជាបណ្តើរៗនៅតាមក្រសួង-ស្ថាប័ន ដែលបានដាក់ឱ្យប្រើប្រាស់ និងដំណើរការប្រព័ន្ធFMIS។ លទ្ធផលសម្រេចបានក្នុងលក្ខណៈសវនកម្មសាកល្បងលើប្រព័ន្ធ FMIS រួមមាននៅក្រសួង ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយនឹងការរកឃើញចំណុចខ្វះចន្លោះមួយចំនួនទាក់ទងនឹងប្រសិទ្ធភាព និងសុវត្ថិភាពនៃប្រព័ន្ធ FMIS ដែលត្រូវកែលម្អបន្ថែម៕■

*រៀបចំដោយ÷ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង*

# តួនាទី និងសារៈសំខាន់នៃគណនេយ្យភាពក្នុងការងារកែទម្រង់

*គណនេយ្យភាព ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន អាស្រ័យតាមស្ថានភាពជាក់ស្តែង។ គណនេយ្យភាព ជាភាសាដែលនិយមប្រើនៅក្នុងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។*

គណនេយ្យភាព សំដៅលើភាពអាចទទួលខុសត្រូវ ភាពអាចគណនា និងភាពអាចពន្យល់បាន។ គណនេយ្យភាព គឺជាទស្សនាទានមួយនៃក្រមសីលធម៌ និងអភិបាលកិច្ច ដែលមានអត្ថន័យទូលំទូលាយ និងអាចត្រូវបានគេប្រើទាំងនៅក្នុងវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល។ ក្នុងន័យម្យ៉ាងទៀត "**គណនេយ្យភាព**" គឺសំដៅទៅលើការទទួលស្គាល់ និងការទទួលខុសត្រូវចំពោះសកម្មភាព ការសម្រេចចិត្ត និងគោលនយោបាយ ដែលបានអនុវត្តនៅក្នុងតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ[១]។

អ្នកស្រាវជ្រាវ Romzek & Dubnick[២] បានបែងចែកគណនេយ្យភាពជា៤ ប្រភេទ។

**១). គណនេយ្យភាពការិយាធិបតេយ្យ÷** មានន័យថា អ្នករដ្ឋបាលសាធារណៈ ផ្តោតការយកចិត្តទុកចិត្តលើអាទិភាពនៃឋានានុក្រមក្នុងការិយាធិបតេយ្យនៃអង្គភាពរបស់ខ្លួន។

**២). គណនេយ្យភាពគតិយុត្ត÷** ជាការទទួលខុសត្រូវ របស់អ្នករដ្ឋបាលសាធារណៈ ចំពោះមុខច្បាប់។

**៣). គណនេយ្យភាពវិជ្ជាជីវៈ÷** ត្រូវបានកំណត់ដោយការដាក់បញ្ហាលើសកម្មភាព និងការងារ របស់បុគ្គលិកជំនាញ ដើម្បីសម្រេចការងារឱ្យទទួលបានលទ្ធផលល្អសម្រាប់អង្គភាព។ រដ្ឋបាលសាធារណៈត្រូវពឹងផ្អែកលើជំនាញ ឬឯកទេសរបស់បុគ្គលិក ហើយបុគ្គលិកត្រូវឆ្លើយតប និងផ្តល់នូវដំណោះស្រាយចំពោះការងារឱ្យបានល្អ។

**៤). គណនេយ្យភាពនយោបាយ÷** អ្នករដ្ឋបាលសាធារណៈត្រូវបានរំពឹងថាឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយ និងកម្មវិធី ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត[២]។




[១] ក្រុមប្រឹក្សាជាតិភាសាខ្មែរ

[២] Romzek, B. S., & Dubnick, M. J. (1987). Accountability in the public sector: Lessons from the Challenger tragedy. Public administration review.




*គណនេយ្យភាព គឺសំដៅទៅការលើការទទួលស្គាល់ និងការទទួលខុសត្រូវចំពោះសកម្មភាព ការសម្រេចចិត្ត និងគោលនយោបាយ ដែលបានអនុវត្តនៅក្នុងតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។*

ប្រព័ន្ធគណនេយ្យភាព ជាឧបករណ៍គន្លឹះ ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់តួអង្គពាក់ព័ន្ធក្នុងការសម្រេច ឱ្យបាននូវសមិទ្ធកម្មរបស់អង្គភាព ស្របតាមគោលនយោបាយ និងការងារកែទម្រង់នានារបស់រដ្ឋាភិបាលដែលបានដាក់ចេញ។

ក្នុងនោះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ផ្ដោតសំខាន់លើគណនេយ្យភាពនេះផងដែរនៅគ្រប់ដំណាក់កាលនៃការកែទម្រង់ ជាពិសេសបានរំលេចនៅក្នុងដំណាក់កាលទី២ "**គណនេយ្យភាពហិរញ្ញវត្ថុ**" និងដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ឆ្ពោះទៅរកប្រសិទ្ធភាព និងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធក្នុងការបំពេញតួនាទី និងមុខងាររបស់ខ្លួន ឱ្យបានកាន់តែប្រសើរក្នុងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ សម្រាប់ស្ថាប័ន ឬអង្គភាពសាធារណៈ។

ទន្ទឹមនឹងនេះ គណនេយ្យភាពត្រូវបានប្រើយ៉ាងទូលំទូលាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដើម្បីពង្រឹងសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ពង្រឹងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ និងពង្រីកគណនេយ្យភាព របស់រដ្ឋបាលថ្នាក់ក្រោមទាំងនោះ ដើម្បីកែលម្អការផ្ដល់សេវាសាធារណៈ ឱ្យបានកាន់តែប្រសើរ និងមានប្រសិទ្ធភាព។ នៅក្នុងបរិបទ នៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គណនេយ្យភាព ត្រូវបានកំណត់និយមន័យប្រហាក់ប្រហែលគ្នាដូចខាងក្រោម÷

"គណនេយ្យភាព គឺជាកាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាច ដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ"[៣]។

"គណនេយ្យភាព គឺជាកាតព្វកិច្ចនៃអ្នកអនុវត្ត សិទ្ធិអំណាចក្នុងការឆ្លើយ បំភ្លឺអំពីសកម្មភាពនានារបស់ខ្លួនចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែលអាចដាក់នូវពិន័យក្នុងករណីខកខានមិនបានអនុវត្ត"[៤]។

"គណនេយ្យភាព គឺជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ នៃការធ្វើសេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដីសម្រេចចិត្តនោះ ដោយមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដែលបានរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត"[៥]។

ជារួម គណនេយ្យភាពបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងការងាររបស់មន្ត្រីមុខងារសាធារណៈ និងមន្ត្រីដែលកើតឡើងដោយការបោះឆ្នោត ឱ្យមានការទទួលខុសត្រូវកាន់តែខ្ពស់ចំពោះលទ្ធផលការងារដែលខ្លួនប្រតិបត្តិ ដើម្បីឆ្លើយតបទៅនឹងសមិទ្ធកម្ម អភិបាលកិច្ចរបស់អង្គភាពសាធារណៈ តម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេស ចូលរួមកសាងការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាលឱ្យបានរឹងមាំ៕■

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកានៃ អ.គ.ហ.*

[៣] សៀវភៅកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

[៤] សៀវភៅ ផអពទី២

[៥] សៀវភៅអភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៥



# ផ្នែកទី ៣

# សុន្ទរកថា

# សុន្ទរកថា ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្លែងតាមប្រព័ន្ធវីដេអូក្នុងពិធីប្រកាសដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន-ដំណាក់កាលទី២ នៅថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១*

*-ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា*

*-លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សជាអនេក ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ បំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាថ្មីម្តងទៀត ឱ្យធ្វើជាអធិបតី និងចូលរួមថ្លែងសុន្ទរកថាពី ចម្ងាយតាមប្រព័ន្ធវីដេអូ ក្នុង "ពិធីប្រកាសដាក់ដំណើរការជាផ្លូវការ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន-ដំណាក់កាលទី ២" ក្នុងគោលបំណងកែសម្រួលបរិយាកាសធុរកិច្ច និងវិនិយោគ សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និងជាពិសេសចូលរួមចំណែកដល់ការរក្សានិរន្តរភាពនៃសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមរយៈ ការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈ។

ខ្ញុំនៅចាំថា ខ្ញុំបានធ្វើជាអធិបតីដោយផ្ទាល់ ក្នុងពិធីដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី១ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ដោយមានការចូលរួមយ៉ាងច្រើនកុះករពីក្រសួង-ស្ថាប័ន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដែលនៅ ពេលនោះ យើងអាចមានលទ្ធភាពជួបជុំគ្នាផ្ទាល់បាន។




*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

បើទោះបីជាការបន្តឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ ជាពិសេសដោយសារព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ នៅមិនទាន់បានបិទបញ្ចប់ និងមិនទាន់អនុញ្ញាតឱ្យយើងទាំងអស់គ្នាអាចជួបជុំផ្ទាល់មុខគ្នាដូចសព្វដង ក៏ជំងឺដ៏កាចសាហាវ នេះមិនអាចបន្ទច់បង្អាក់ដល់ចង្វាក់ការងាររបស់យើងឡើយ។ ជាក់ស្តែង, ពិធីតាមប្រព័ន្ធវីដេអូនាពេលនេះ បានកំពុងដំណើរការយ៉ាងរលូន ដែលអនុញ្ញាតឱ្យយើងអាចជួបជុំគ្នាពីចម្ងាយ ដើម្បី ចូលរួមផ្សព្វផ្សាយ និងយល់ដឹងពី ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន-ដំណាក់កាលទី២ ដែលនឹងត្រូវដាក់ឱ្យដំណើរការចាប់ពីថ្ងៃនេះ។

ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងខិតខំប្រឹងប្រែងឥតឈប់ឈរ ក្នុងស្មារតី បេសកម្ម និងម៉ឺងម៉ាត់ ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងារនៃការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងប្រកបដោយស្មារតីបុរេសកម្មរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មិនបានបន្ថយនូវល្បឿនរបស់ខ្លួនឡើយ។ ជាក់ស្តែង, ការដាក់ឱ្យដំណើរការនូវ**ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី២** នៅថ្ងៃនេះ បង្ហាញយ៉ាងច្បាស់ថា ការដ្ឋាននៃការងារកែទម្រង់ដើម្បីលើកស្ទួយបរិយាកាសធុរកិច្ច និង វិនិយោគនៅកម្ពុជា បានសម្រេចនូវលទ្ធផលតាមការគ្រោងទុក។

នាខែឧសភា ឆ្នាំ២០២១ នេះ រាជរដ្ឋាភិបាលកម្ពុជា ក៏សម្រេចបាននូវសមិទ្ធផលផ្នែក គោលនយោបាយ តាមរយៈការដាក់ចេញនូវ "**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥**" ជាមួយនឹងចក្ខុវិស័យវែងឆ្ងាយក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល




រស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះ ជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ, ពលរដ្ឋ និងធុរជនដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លង "**ប្រក្រតីភាពថ្មី**"។ សម្រាប់កម្ពុជា ការធ្វើបរិវត្តកម្មឌីជីថល គឺជាការចាប់យក និងការទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និងកសាងសង្គមស៊ីវិល័យដែល ពលរដ្ឋ អាចទទួលបាននូវផលប្រយោជន៍ ពីការប្រើប្រាស់សេវាឌីជីថល ប្រកបដោយបរិយាបន្ន, ភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ ហើយដំណាលគ្នានេះក៏រក្សាឱ្យបាននូវអត្តសញ្ញាណ និង វប្បធម៌ជាតិ។ ក្នុងន័យនេះ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន -ដំណាក់កាលទី២ ក៏បានឆ្លើយតបយ៉ាងលឿន ក្នុងការចូលរួមអនុវត្តនូវក្របខណ្ឌគោលនយោបាយនេះ ដើម្បីទាញយកនូវប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ជាពិសេសក្នុងបរិបទ នៃការរីករាលដាលដោយជំងឺកូវីដ-១៩ ដែលតម្រូវឱ្យយើងត្រូវកាត់បន្ថយការជួបគ្នាផ្ទាល់ជាអតិបរមា ខណៈដែលយើងនៅតែបន្តខិតខំធានាឱ្យនិរន្តរភាពនៃការងារនៅបន្តជាប្រក្រតី។

*-ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី!*

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ដំណើរការជាផ្លូវការ **ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន-ដំណាក់កាលទី១** កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ កន្លងទៅ ដោយទទួលបានការចាប់អារម្មណ៍ និងការសាទរខ្ពស់ពីវិស័យឯកជន។ ប្រព័ន្ធនេះក៏បានចូលរួម ចំណែកយ៉ាងសំខាន់ ដល់ការរក្សានិរន្តរភាពសកម្មភាពសេដ្ឋកិច្ចក្នុងបរិការណ៍នៃវិបត្តិនៃជំងឺកូវីដ-១៩។ ជាក់ស្តែង, នៅក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល, មន្ត្រី បុគ្គលិក និយោជិតត្រូវបានអនុញ្ញាត ឱ្យធ្វើការងារពីផ្ទះ ហើយការធ្វើ ដំណើររបស់ប្រជាជនក៏ត្រូវបានរឹតត្បិតផងដែរ។ ប៉ុន្តែដោយប្រព័ន្ធនេះត្រូវបានរៀបចំឡើងមានលក្ខណៈអនឡាញទាំងស្រុង ហើយយន្តការគាំទ្រក៏ធ្វើឡើងតាមអនឡាញផងដែរនោះ ធុរជន នៅតែបន្តស្នើសុំការចុះបញ្ជីពីផ្ទះបានស្របពេលដែលយន្តការគាំទ្រ និងត្រួតពិនិត្យសំណើដោយមន្ត្រី រដ្ឋាភិបាលក៏នៅតែបន្តបានដូចប្រក្រតី។ ការណ៍នេះគួសរំលេចបន្ថែមនូវសារៈសំខាន់ និងភាពចាំបាច់ នៃការប្រើប្រាស់ប្រព័ន្ធឌីជីថល សម្រាប់គាំទ្រដល់ការផ្តល់សេវាសាធារណៈ ជាពិសេសក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩។ ក្នុងរយៈពេលជាង១ ឆ្នាំកន្លងមក ប្រព័ន្ធចុះបញ្ជីអាជីវកម្មបានដំណើរការឥតដាច់ និងបានអនុញ្ញាតឱ្យធុរជន អាចធ្វើការស្នើសុំការចុះបញ្ជីអាជីវកម្មបានគ្រប់ ពេលវេលា និងទីកន្លែង ហើយគិតត្រឹមថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ក្រុមហ៊ុនដែលបានចុះបញ្ជី អាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ មានចំនួនសរុបដល់ទៅ **៧ ៧១៥** និង មានដើមទុនសរុបស្មើជិត **៣ ពាន់លានដុល្លារអាមេរិក**។ វិស័យ ៥ ដែលមានទំហំដើមទុនធំជាងគេរួមមាន (១)- សំណង់មានចំនួន 25.32%, (២)-អាហារ៍ណ នីហរ៍ណ ទិញលក់ ជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទមានចំនួន 16.44%, (៣)- សកម្មភាពអចលនវត្ថុមានចំនួន 15.53%,(៤)-កម្មន្តសាល មានចំនួន 14.3% និង (៥)-សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង មានចំនួន 8.22%។

បន្ថែមលើរបាយការណ៍របស់ ឯកឧត្តម **ផាន់ ផល្លា** និង បទបង្ហាញរបស់ឯកឧត្តម **គង់ ម៉ារី**, ខ្ញុំសូមរំលឹកឡើងវិញផងដែរថា ដំណាក់កាលទី១ បានផ្តោតជាសំខាន់លើនីតិវិធីចាំបាច់ ជាមូលដ្ឋាន ដែលគ្រប់ក្រុមហ៊ុន សហគ្រាស ត្រូវបំពេញ ដើម្បីធ្វើការចុះបញ្ជីអាជីវកម្មរបស់ខ្លួនជាផ្លូវការ និងស្របច្បាប់ដែលមានជាអាទិ៍÷ ការចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម, ការចុះបញ្ជីពន្ធដារជាមួយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការផ្តល់សេចក្តីប្រកាស ជូនដំណឹងបើកសហគ្រាសទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាមួយនឹងភាពជោគជ័យនៃដំណាក់កាលទី១, រាជរដ្ឋាភិ-

បាលបានពង្រីកវិសាលភាពទៅដំណាក់កាលទី២ ថែមទៀតដើម្បីបន្ធូរសម្រួលដល់ធុរជនតាមរយៈការរៀបចំថ្នាលបច្ចេកវិទ្យាព័ត៌មានឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមលំអានការងារ និងគោលការណ៍ដែលយើងបានអនុវត្តក្នុងដំណាក់កាលទី១។

យ៉ាងណាមិញ, ដំណាក់កាលទី២ នេះ ផ្ដោតសំខាន់លើការស្នើសុំអាជ្ញាបណ្ណ និងលិខិត អនុញ្ញាតផ្សេងៗ ទៅតាមប្រភេទនៃសកម្មភាពអាជីវកម្ម ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន ចំនួន៤ រួមមាន÷ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួង ទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតផ្សេងៗ នៅគ្របដណ្ដប់ច្រើនក្រសួង-ស្ថាប័នផ្សេងទៀត ប៉ុន្តែការជ្រើសរើសយកក្រសួង-ស្ថាប័នចំនួន៤ ខាងលើចូលក្នុងដំណាក់កាលទី២ នេះគឺឈរលើតម្រូវការក្នុងវិស័យដែលមានការស្នើសុំថ្មី ឬស្នើសុំបន្តសុពលភាពនៃសកម្មភាពធុរកិច្ចកន្លងមកក្នុងចំនួនច្រើន។ ដំណាក់កាលទី២ នេះនឹងអនុញ្ញាតឱ្យធុរជនអាចចាប់ផ្ដើមអាជីវកម្មរបស់ខ្លួនបានពេញលេញស្របតាមបទប្បញ្ញត្តិ ដែលមានជាធរមាន តាមរយៈការដាក់ស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតផ្សេងទៀត, បង់ថ្លៃសេវាតាមរយៈប្រព័ន្ធទូទាត់បង់ប្រាក់ឌីជីថល និងទាញយកវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតជាទម្រង់ ឌីជីថលពីទីណាក៏បាន នៅពេលណាក៏បាន ដោយមិនចាំបាច់ធ្វើដំណើរ ឬមកជួបផ្ទាល់ជាមួយមន្ត្រី។ បន្ថែមលើនេះ ការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតផ្សេងៗ នៅក្នុងដំណាក់កាលទី២ នេះ ក៏មានលក្ខណៈងាយស្រួលជាងមុនច្រើនដោយមានការកាត់បន្ថយថ្លៃចំណាយ, នីតិវិធី និងពេលវេលា **ដែលពីមុនត្រូវការចន្លោះពី ១៥ ទៅ ៣០ថ្ងៃ មកត្រឹមតែ ៣ ទៅ ៧ថ្ងៃនៃថ្ងៃធ្វើការប៉ុណ្ណោះ ប្រសិនបើសំណើបំពេញលក្ខខណ្ឌគ្រប់គ្រាន់។**

សេវាចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានទាំងដំណាក់កាលទី១ និងទី២ នេះ ត្រូវបានដាក់ឱ្យអនុវត្តលើថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (Cambodia Data Exchange-CamDX) ដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល អាចផ្លាស់ប្ដូរគ្នាបាននូវទិន្នន័យស្ដីពី ក្រុមហ៊ុនសហគ្រាស និងទិន្នន័យពាក់ព័ន្ធដោយរលូន និងសង្គតិភាព ដោយមិនតម្រូវឱ្យធុរជន ឬប្រជាពលរដ្ឋត្រូវបំពេញ ឬផ្ដល់ទិន្នន័យដដែលៗ ពីស្ថាប័នមួយ ទៅស្ថាប័នមួយទៀត។ ជាមួយនឹងសមិទ្ធផលថ្មីមួយទៀតតាមរយៈការដាក់ចេញនូវ **"អនុក្រឹត្យស្ដីពីការផ្លាស់ប្ដូរទិន្នន័យ តាមរយៈ ថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា"** ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ កន្លងទៅថ្មីៗនេះ យើងរំពឹងថាសេវាសាធារណៈថ្មីៗជាច្រើនមុខ នឹងត្រូវបានពង្រីក និងដាក់ឱ្យប្រើប្រាស់តាមប្រព័ន្ធអនឡាញ ជាបន្តបន្ទាប់ សំដៅលើកកម្ពស់ប្រសិទ្ធភាព នៃការផ្ដល់សេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរដ្ឋ មួយកម្រិតថែមទៀត។ អនុក្រឹត្យនេះក៏នឹងក្លាយជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តិដ៏សំខាន់មួយ ដែលអនុញ្ញាត និងបើកផ្លូវឱ្យវិស័យឯកជនមានលទ្ធភាពចូលរួមផ្លាស់ប្ដូរទិន្នន័យជាមួយរាជរដ្ឋាភិបាល ជំរុញឱ្យមានសហថាមពល (Synergy) និងសហបង្កើតថ្មី (Co-creation) ក្នុងវិស័យធុរកិច្ច សេដ្ឋកិច្ច និងសង្គម។

ទោះបីជារាជរដ្ឋាភិបាលបាននិងកំពុងខិតខំធ្វើបរិវត្តកម្មឌីជីថល, ប៉ុន្តែការងារកសាង អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលនឹងមិនអាចសម្រេចឡើយ បើតួអង្គពាក់ព័ន្ធនៃប្រព័ន្ធអេកូឡូស៊ីមិនដើរស្របគ្នា និងមិន




ចាប់ផ្ដើមចាប់យកបច្ចេកវិទ្យាឌីជីថលនេះមកប្រើប្រាស់។ វិស័យឯកជន ដើរតួនាទីជាតួអង្គដ៏សំខាន់មួយ ដែលត្រូវចាប់ផ្ដើមធ្វើបរិវត្តកម្មឌីជីថលក្នុងអាជីវកម្ម របស់ខ្លួនផងដែរ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការអាជីវកម្ម និងសម្រាប់ ជាមធ្យោបាយដើម្បីពង្រីកទីផ្សាររបស់ខ្លួន ដូចជាការលក់ដូរអនឡាញ និងពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិកជាដើម។ ក្នុងន័យនេះ ខ្ញុំសូមផ្ដល់អនុសាសន៍មួយចំនួនផងដែរ ដល់វិស័យឯកជន ក្នុងការចាប់ផ្ដើមគិតគូរធ្វើបរិវត្តកម្មឌីជីថលរួមមាន÷ (១)- គួរផ្លាស់ប្ដូរផ្នត់គំនិត និងរបៀបរបបធ្វើការតាមយុគបច្ចេកវិទ្យាឌីជីថល ព្រោះការធ្វើបរិវត្តកម្មឌីជីថលមិនមែនជាដំណើរការដែលធ្វើតែមួយលើក ឬមួយពេលនោះទេ ពោលគឺជាដំណើរការដែលត្រូវធ្វើជាប្រចាំ ដូច្នេះយើងត្រូវពង្រឹងសមត្ថភាពសម្របខ្លួន (Adaptability) ព្រមទាំងសមត្ថភាពផ្លាស់ប្ដូររហ័ស (Agility) ដើម្បីរកដំណោះស្រាយថ្មីៗធ្វើឱ្យបរិវត្តកម្មឌីជីថលកាន់តែមានប្រសិទ្ធភាព និងសម្ទុះលឿន, (២)- កំណត់ចក្ខុវិស័យរបស់ខ្លួន ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង ធ្វើការ




វាយតម្លៃឡើងវិញនូវសមត្ថភាព និងធនធានរបស់ខ្លួន, (៣)-កំណត់អាទិភាពនៃការធ្វើឌីជីថលូនីយកម្ម ទាំងលើផ្នែកប្រតិបត្តិការ និងផ្នែកទីផ្សារ និង(៤)- ពង្រឹងកិច្ចសហប្រតិបត្តិការ និងសហបង្កើតថ្មី (Co-creation) រវាងរដ្ឋ និងឯកជន ឬ ឯកជន និងឯកជនព្រមទាំងពិនិត្យ និងស្វែងរកកម្មវិធីគាំទ្រផ្សេងៗរបស់រាជរដ្ឋាភិបាលដែលកំពុងតែត្រូវបានដាក់ចេញ។ ក្នុងឱកាសនេះ ខ្ញុំសូម ប្រកាសផងដែរថា រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ពាក់ព័ន្ធ នឹងដាក់ឱ្យមានកម្មវិធីគាំទ្រថ្នាក់ជាតិដល់រាល់សហគ្រាសធនតូច និងមធ្យមក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល ដែលកម្មវិធីនេះ មានការគិតគូរជាកញ្ចប់ និងគ្រប់ជ្រុងជ្រោយ ទាំងទិដ្ឋភាពហិរញ្ញវត្ថុ បច្ចេកទេស និងជំនាញ។

*-ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី!*

ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារអន្តរក្រសួង រៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានរៀបចំ និង បន្តអនុវត្តដំណាក់កាលទី១ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ខ្ញុំក៏ សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារអន្តរក្រសួងក្នុងដំណាក់កាលទី២ នេះដែលក្នុងនោះរួមមាន÷ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ”, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ព្រមទាំងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងក្រសួង-ស្ថាប័នពាក់ព័ន្ធដែលបានខិតខំប្រឹងប្រែងឥតរាថយ តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធ រហូតសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ មុននឹងបញ្ចប់ ខ្ញុំសូមស្នើឱ្យក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន បន្តខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ ចិត្ត ប្រកបដោយស្មារតីបុរេសកម្ម និង ស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការផ្តល់ការគាំទ្រជាប្រចាំ ដោះស្រាយនូវបញ្ហាប្រឈមទាំងផ្នែកបច្ចេកទេស ឬបញ្ហាប្រឈមផ្សេងទៀត ដែលនឹងអាចកើតមានក្រោយការដាក់ឱ្យដំណើរការនៃប្រព័ន្ធនេះ ដើម្បីកែលម្អប្រព័ន្ធ ឱ្យកាន់តែមានភាពរលូនឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់។ ជាការពិត ដំណាក់កាលទី២ គ្រាន់តែជាការចាប់ផ្តើមនៃដំណើរនៃការផ្តល់សេវាប្រភេទនេះតាម ប្រព័ន្ធអនឡាញតែប៉ុណ្ណោះ។ ក្នុងន័យនេះ, ខ្ញុំសូមស្នើក្រុមការងារខិតខំពង្រីកវិសាលភាព នៃប្រព័ន្ធផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត និងបន្តគ្របដណ្តប់ដល់វិស័យផ្សេងៗទៀត ព្រមទាំងបន្តបញ្ចូលនូវសេវាសំខាន់ៗ និងចាំបាច់នានា សម្រាប់ផ្តល់នូវការសម្រួលបន្ថែមដល់ការធ្វើធុរកិច្ចនៅកម្ពុជា។ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់តួអង្គពាក់ព័ន្ធ ចូលរួមផ្សព្វ-

*សេវាចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័តមានទាំងដំណាក់កាលទី១ និងទី២ នេះ ត្រូវបានដាក់ឱ្យអនុវត្តលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange-CamDX) ដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល អាចផ្លាស់ប្តូរគ្នាបាននូវទិន្នន័យស្តីពីក្រុមហ៊ុនសហគ្រាស និងទិន្នន័យពាក់ព័ន្ធដោយរលូន និងសង្គតិភាព ដោយមិនតម្រូវឱ្យធុរជនឬប្រជាពលរដ្ឋត្រូវបំពេញ ឬផ្តល់ទិន្នន័យដដែលៗពីស្ថាប័នមួយ ទៅស្ថាប័នមួយទៀត។*

ផ្សាយឱ្យបានទូលំទូលាយនូវ ថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ។ ទន្ទឹមនឹងនេះ ខ្ញុំក៏លើកទឹកចិត្តផងដែរ ឱ្យធុរជន និងវិនិយោគិនទាញយកប្រយោជន៍ ឱ្យអស់លទ្ធភាពពីថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ និងផ្តល់នូវមតិកសាងល្អៗដល់ក្រុមការងារ និងសូមស្នើឱ្យបន្តគាំទ្ររាជរដ្ឋាភិបាល និងបន្តនៅជាមួយកម្ពុជា, រួមគ្នា ពុះពារជម្នះនូវរាល់បញ្ហាប្រឈមក្នុងគ្រាដ៏លំបាកនេះ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឱ្យឯកឧត្តម លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក លោកស្រី, សមាជិកសមាជិកាទាំងអស់នៃអង្គពិធីទាំងមូល មានសុខភាពល្អ និងជៀសផុតពីជំងឺ កូវីដ-១៩ និងទទួលបានជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន ព្រមជាមួយនឹងសេចក្តីចំរើនគ្រប់ប្រការ។ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ខ្ញុំសូមប្រកាសដាក់ដំណើរការជាផ្លូវការនូវ **«ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន-ដំណាក់កាលទី២»** ចាប់ពីពេលនេះតទៅ៕■

***សូមអរគុណ!***

# សុន្ទរកថាគន្លឹះ របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *ថ្លែងតាមប្រព័ន្ធវីដេអូក្នុងសិក្ខាសាលាស្ដីពីការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១*

*សូមគោរព*

*-លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២ រដ្ឋសភា*

*-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា*

*-ឯកឧត្តម លោកជំទាវ ប្រធាន អនុប្រធាន គណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភា សមាជិក-សមាជិកានៃរដ្ឋសភា និងព្រឹទ្ធ-សភា*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!*




តាងនាមរាជរដ្ឋាភិបាល រូបខ្ញុំ និងសហការី មកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយស និងក្ដីសោមនស្សជាអនេក ដោយបានទទួលការអញ្ជើញចូលរួមជាថ្មីម្ដងទៀតក្នុង“ **សិក្ខាសាលាស្ដីពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២**” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២ នៃរដ្ឋសភាជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា។

បើទោះបីជាការបន្តឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ មិនអនុញ្ញាតឱ្យយើងទាំងអស់គ្នា អាចជួបជុំផ្ទាល់មុខគ្នាដូចសព្វដង ក៏ជំងឺដ៏កាចសាហាវនេះមិនអាចបន្ទច់បង្អាក់ដល់ចង្វាក់ការងាររបស់យើងឡើយ។ ជាក់ស្ដែង សិក្ខាសាលាតាមប្រព័ន្ធវីដេអូនាពេលនេះ បាននិងកំពុងដំណើរការយ៉ាងរលូន ហើយនឹងចូលរួមចំណែកបន្តរក្សាវប្បធម៌ចែករំលែកនូវព័ត៌មាន ជូនដល់ស្ថាប័ននីតិប្បញ្ញត្តិ អំពីការរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលជាមូលដ្ឋាន នៃការរៀបចំថវិកាជាតិសម្រាប់ឆ្នាំ២០២២ ជាមួយនឹងការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ សមាជិក-សមាជិកានៃរដ្ឋសភា ព្រឹទ្ធ-សភា និងអស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ដូចបណ្ដាឆ្នាំមុនៗ នៅពេលដែលមិនទាន់មានវត្តមាននៃជំងឺកូវីដ-១៩។

ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងខិតខំប្រឹងប្រែងឥតឈប់ឈរក្នុង ស្មារតីបុរេសកម្ម និងម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ សិក្ខាសាលានេះ គឺជាវេទិកាមួយដ៏មានសារៈសំខាន់ក្នុងការបន្ថែមចំណែកលើកកម្ពស់តម្លាភាពថវិកា និងកិច្ចសន្ទនារវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិសម្រាប់ការឈ្វេងយល់កាន់តែលម្អិត និងទូលំទូលាយ អំពីការគិតគូរ និងការរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោ-បាយហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ របស់រាជរដ្ឋាភិបាល។ ដោយហេតុថា តាមការគ្រោងទុក សហការីរបស់ខ្ញុំនឹងជម្រាបជូនអង្គសិក្ខាសាលាលម្អិត អំពីបរិការណ៍ និងគោលការណ៍ចម្បងៗក្នុងការកសាងថវិកាជាតិ ខ្ញុំសូមធ្វើការគូសរំលេចដោយសង្ខេប

ជូនអង្គសិក្ខាសាលា នូវចំណុចសំខាន់ៗចំនួន៣ ដែលជាមូលដ្ឋាននៃការរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ឆ្នាំ២០២២ ក្នុងនោះរួមមាន ÷ (១). ស្ថានភាព និងការគ្រប់គ្រងវិបត្តិជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា (២). បរិការណ៍រួមនៃការរៀបចំក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាធារណៈ និង (៣). ទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងផែនការស្តារសេដ្ឋកិច្ចឡើងវិញ។ ខ្ញុំសូមឆ្លងចូលទៅធ្វើការអធិប្បាយអំពីចំណុចនីមួយៗ ដូចតទៅ÷

## ១.អំពីស្ថានភាព និងការគ្រប់គ្រងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា

ក្នុងឆ្នាំ២០២១ នេះ ជំងឺកូវីដ-១៩បានបន្តឆ្លងរាលដាលដល់គ្រប់ប្រទេស និងដែនដី ទាំងអស់នៅលើសកលលោក ជាមួយនឹងភាពមិនប្រាកដប្រជាកាន់តែខ្ពស់ តាមរយៈការបំប្លែងខ្លួនជាប្រភេទវីរុសកូវីដ-១៩ ថ្មីជាច្រើន ជាពិសេសមេរោគបំប្លែងថ្មីដែលតា (Delta) ដែលមានលទ្ធភាពចម្លងកាន់តែខ្ពស់ និងអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជនកាន់តែខ្លាំងក្លាជាងមុន។ នៅក្នុងក្របខណ្ឌតំបន់
មេរោគបំប្លែងថ្មីនេះ
បាននិងកំពុងធ្វើឱ្យប្រទេស មួយចំនួនដែលធ្លាប់គ្រប់គ្រងករណីឆ្លងបានល្អ ក្លាយជាតំបន់ក្តៅគគុកនៃការរីករាលដាលនៃកូវីដ-១៩ ក្នុងកម្រិតធ្ងន់ធ្ងរ ដែលករណីឆ្លង និងការបាត់បង់ជីវិត មានសម្ទុះកើនឡើងខ្លាំង ស្របពេលដែលអត្រានៃការចាក់វ៉ាក់សាំងសម្រាប់ប្រជាជនជារួម នៅមានកម្រិតទាបនៅឡើយ។

សម្រាប់កម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបាន និងកំពុងខិតខំយ៉ាងសស្រាក់សស្រាំ ប្រកបដោយស្មារតីបុរេសកម្មក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ដែលកើតចេញពី«**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**» តាមរយៈការដាក់ចេញទាំងវិធានការរដ្ឋបាល និងវិធានសុខាភិបាលជាច្រើន ដែលមានភាពទន់ភ្លន់ ប៉ុន្តែម៉ឹងម៉ាត់ និងបត់បែនទៅតាមសភាពការណ៍ និងទីតាំងភូមិសាស្ត្រ ជាក់ស្តែង ដើម្បីទប់ស្កាត់ កាត់ផ្តាច់នូវខ្សែច្រវាក់ចម្លង និងកាត់បន្ថយការឆ្លងបានទាន់ពេល សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន ពិសេស គឺ**យុទ្ធសាស្ត្រ ៦ចំណុច** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលក្រសោបបញ្ចូលនូវវិធានការលម្អិតជាក់ស្តែងចំនួន២៦ ចំណុច។ ជាមួយនឹងវិធានការទាំងនេះ រាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំង ជាវិធានការយុទ្ធសាស្ត្រគន្លឹះ ដើម្បីកាត់បន្ថយការឈឺឆ្លង និងឈឺធ្ងន់ និង ពិសេសសំដៅឈានទៅសម្រេចបាននូវ ភាពស៊ាំសហគមន៍ (Herd Immunity) ដែលជាកត្តាជំរុញក្នុងការធានាបាននូវការវិលត្រឡប់ឱ្យបានឆាប់រហ័សទៅរក«**ប្រក្រតីភាពថ្មី**» នៃជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋកម្ពុជាទូទៅ និងកិច្ចដំណើរការនៃសង្គម-សេដ្ឋកិច្ច។

*ជាមួយនឹងការធានានូវការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងប្រកបដោយប្រសិទ្ធភាពនូវធនធានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងរយៈពេលមធ្យម រហូតដល់ឆ្នាំ២០២៣, កម្ពុជាត្រូវបង្កើនការប្តេជ្ញាចិត្ត និងតម្រង់កិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពម៉ឺងម៉ាត់ និងឆន្ទៈនយោបាយខ្ពស់ ដោយតម្កល់ផលប្រយោជន៍ជាតិជាធំក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងពន្លឿនកិច្ចការកែទម្រង់គ្រប់ការដ្ឋាន ពិសេសការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ដែលជា"កត្តាស្លាប់រស់" ដើម្បីធានាឱ្យកម្ពុជាអាចឈានទៅសម្រេចបានចក្ខុវិស័យនៃការអភិវឌ្ឍវែងឆ្ងាយរបស់ខ្លួន។*

ជាលទ្ធផល ផ្អែកលើសមិទ្ធផល ដែលសម្រេចបានមកទល់ពេលនេះ កម្ពុជានឹងបញ្ចប់ការចាក់វ៉ាក់សាំងបង្ការកូវីដ-១៩ ជូនប្រជាជនតាមចំនួនគោលដៅ ១០លាននាក់ ដោយមិនទាន់រាប់បញ្ចូលកុមារ និងយុវវ័យ មុនផែនការកំណត់។ លើមូលដ្ឋាននេះ, បើប្រៀបធៀបនឹងប្រទេសក្នុងតំបន់ដែលមានស្ថានភាពនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ កាន់តែស្រួចស្រាល់, កម្ពុជាស្ថិតក្នុងចំណោមប្រទេស ដែលឈានមុខគេក្នុងដំណើរឆ្ពោះទៅរកការបង្កើតភាពស៊ាំសហគមន៍ក្នុងដំណាច់ឆ្នាំ២០២១ នេះ ជាមួយនឹងលទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងការរីករាលដាល នៃជំងឺកូវីដ-១៩។ ថ្មីៗនេះ, ជាមួយនឹងការជំរុញអនុវត្តយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ខណៈដែលមេរោគបំប្លែងថ្មីប្រភេទ ដែលតា (Delta) បានលេចធ្លាយចូលក្នុងសហគមន៍នៃរាជធានី-ខេត្តមួយចំនួន, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវយុទ្ធនាការចាក់វ៉ាក់សាំងដល់កុមារ និងយុវវ័យអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ និងចាក់វ៉ាក់សាំងដូសទី៣ ឬដូសជំរុញបន្ថែមដល់ក្រុមមន្ត្រីបម្រើសេវាជួរមុខផងដែរ។

## ២.អំពីបរិការណ៍រួមនៃការរៀបចំក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

ដូចបណ្តាប្រទេសនានានៅលើសកលលោក, ២០២០ គឺជាឆ្នាំដ៏លំបាកបំផុតក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា ដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះក្នុងអត្រា -៣,១% ដោយសារការធ្លាក់ចុះនៃតម្រូវការសកល, ការបង្អាក់ដល់ខ្សែច្រវាក់ផលិតកម្មសកល, ការធ្លាក់ចុះនៃវិហ្វូរមនុស្ស និងការបាត់បង់ទំនុកចិត្តវិនិយោគ ដែលត្រូវបានបង្កឡើងដោយការរីករាលដាលឥតស្រាកស្រាន្តនៃជំងឺកូវីដ-១៩។ កត្តានេះបានធ្វើឱ្យវិស័យជំរុញកំណើនសំខាន់ៗរបស់កម្ពុជា រួមមានវិស័យទេសចរណ៍ និងវិស័យគាំទ្រផ្សេងទៀតដូចជា កាត់ដេរ សំណង់ និងអចលនទ្រព្យ ធ្លាក់ចុះយ៉ាងគំហុក។ ត្រង់ចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ផងដែរថាសេដ្ឋកិច្ចកម្ពុជា អាចនឹងមានកំណើនអវិជ្ជមានជ្រៅជាងនេះ ក្នុងករណីពុំមានការដាក់ចេញនូវវិធានការអន្តរាគមន៍ ទាន់ពេល និងប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលនោះទេ។ ជាក់ស្តែង មកទល់ពេលនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍ **ចំនួន៩ជុំ** រួចមកហើយប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការជួយរក្សាលំនឹងធុរកិច្ច និងជីវភាពរស់នៅ របស់ប្រជាជន ជាពិសេសកម្មករ-និយោជិត និងគ្រួសារក្រីក្រ ព្រមទាំងជនងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិ ជំងឺកូវីដ-១៩។ សម្រាប់ឆ្នាំ ២០២១ ផ្អែកតាមការវាយតម្លៃកាលពីដើមឆ្នាំ កំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថាអាចនឹងមានកំណើនក្នុងអត្រា ៤,០% ដែលទ្រទ្រង់ដោយការងើបឡើងវិញ នៃសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ចក្នុងស្រុក និងកំណើនវិជ្ជមាន នៃសេដ្ឋកិច្ចសកល និងការកើនឡើង នូវតម្រូវការខាងក្រៅ ពិសេសការប្រើប្រាស់ និងការវិនិយោគឯកជន ដែលជាលទ្ធផលនៃ (១). ការដាក់ចេញគោលនយោបាយគាំទ្រនៅតាមបណ្តាប្រទេសនានា; (២). ការរំពឹងទុក នៃការងើបឡើងវិញជាបណ្តើរៗ នៃសកម្មភាពសេដ្ឋកិច្ចដែលជំរុញដោយការចែកចាយ និងការចាក់វ៉ាក់សាំងបានកាន់តែទូលំទូលាយ និង (៣). ការសម្របខ្លួនរបស់ប្រជាជន និងអាជីវកម្មទៅនឹងវិបត្តិជំងឺកូវីដ-១៩។ យ៉ាងណាមិញ តាមការវាយតម្លៃពាក់កណ្តាលឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ"** ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាអាចនឹងសម្រេចបានអត្រាកំណើនត្រឹមតែ **២,៤ ភាគរយ** ប៉ុណ្ណោះនៅក្នុងឆ្នាំ២០២១ នេះ ពោលគឺទាបជាងការព្យាករដើមឆ្នាំ ដោយសារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩នៅក្នុងសហគមន៍ បាននិងកំពុងបន្ទច់បង្អាក់យ៉ាងខ្លាំងដល់សកម្មភាពពាណិជ្ជកម្ម ដែលធ្វើឱ្យវិស័យទេសចរណ៍ វិស័យលក់ដុំ លក់រាយ ដែលជាសកម្មភាពប្រើប្រាស់ក្នុងស្រុក វិស័យសំណង់ និងអចលនទ្រព្យ បន្តធ្លាក់ចុះយ៉ាងគំហុក។

ដោយឡែក សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងសម្រេចបានក្នុងអត្រា **៤,៨ ភាគរយ** ដោយសារការសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី (New Normal) ព្រមទាំងភាពធូរស្រាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីការចាក់វ៉ាក់សាំងត្រូវបាន អនុវត្តយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស ដែលនឹងជួយជំរុញការងើបឡើងវិញសន្សឹមៗ នៃវិស័យ និងអនុវិស័យជំរុញកំណើនសំខាន់ៗជាមួយនឹងភាពល្អប្រសើរឡើងនៃកំណើនសេដ្ឋកិច្ចសកល ការផ្លាស់ប្តូរទីតាំងរោងចក្រពីប្រទេសជិតខាងមួយចំនួនមកកាន់កម្ពុជា និងការងើបឡើងវិញសន្សឹមៗ នៃវិហ្វូរមនុស្ស និងវិហ្វូរទុនវិនិយោគស្របពេលដែលការរីករាលដាល នៃជំងឺកូវីដ-១៩ ត្រូវបានរំពឹងថានឹងអាចគ្រប់គ្រងបាន។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជា ក៏បន្តប្រឈមនឹងហានិភ័យពីកត្តាខាងក្រៅ និងក្នុងប្រទេសផងដែរ ដែលទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាបន្តត្រៀមខ្លួនប្រកបដោយស្មារតីប្រុងប្រយ័ត្ន បុរេសកម្ម និងបត់បែនខ្ពស់ក្នុងការរៀបចំ និងដាក់ចេញនូវគោលនយោបាយ និងវិធានការអន្តរាគមន៍ ដើម្បីឆ្លើយតប និងសម្របតាមការវិវត្តនៃវិបត្តិឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ រីឯក្នុងទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈវិញ ការវាយតម្លៃពាក់កណ្តាលឆ្នាំលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលរាជរដ្ឋាភិបាលបានរៀបចំជារបាយការណ៍ គោរពជូនរដ្ឋសភា និងព្រឹទ្ធសភារួចហើយ បានបង្ហាញថាជាមួយនឹងស្ថានភាពមិនប្រាកដប្រជាខ្ពស់នាពេលបច្ចុប្បន្ន កម្ពុជាបាននិងកំពុងទទួលរងសម្ពាធហិរញ្ញវត្ថុសាធារណៈលើសពីការរំពឹងទុក។ ក្នុងនោះ ការប្រមូលចំណូលថវិកាជាតិអាចប្រឈមនឹងការថមថយថែមមួយកម្រិតទៀត ជាពិសេសចំណូលមិនមែនសារពើពន្ធ ស្របទៅតាមកត្តាសត្យានុម័តនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចខណៈតួនាទី និងការរួមចំណែករបស់រាជរដ្ឋាភិបាលក្នុងការទប់ទល់នឹងផលវិបាកនេះនឹងមានវិសាលភាពកាន់តែធំដើម្បីដោះស្រាយបញ្ហានានាចំពោះមុខតាមរយៈការត្រៀមបង្កើនការដាក់ចេញកម្មវិធីចំណាយ ដែលមានភាពបត់បែន និងឆ្លើយតបនឹងតថភាព ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ជាក់ស្តែង, នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ រាជរដ្ឋាភិបាល បានដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ក្នុងទំហំប្រមាណ **៧១៩ លានដុល្លារអាមេរិក** ដើម្បីប្រយុទ្ធការពារអាយុជីវិត រក្សាលំនឹងជីវភាពប្រជាជន និងទ្រទ្រង់សកម្មភាពអាជីវកម្មក្នុងស្រុក។ ទោះបីជា




*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងសិក្ខាសាលាស្តីពីការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១។*

យ៉ាងណា មកទល់ពេលបច្ចុប្បន្នដោយសារ **ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ** គួបផ្សំនឹងសម្ទុះនៃការកើនឡើងនូវចំនួនករណីនាំចូល ជាពិសេសប្រភេទមេរោគបំប្លែងថ្មីដែលតា (Delta) នាពេលថ្មីៗនេះ, ទំហំនៃថវិកាចំណាយអន្តរាគមន៍ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១ អាចនឹងឡើងរហូតដល់ប្រមាណ **១ ៤៥៤ លានដុល្លារអាមេរិក** ដែលក្នុងនោះចំណាយលើកម្មវិធីទប់ស្កាត់ និងព្យាបាលជំងឺកូវីដ-១៩ អាចឡើងដល់ប្រមាណ **៧៤០ លានដុល្លារអាមេរិក** ធៀបនឹងការគ្រោងពីដើមឆ្នាំត្រឹម ៣០ លានដុល្លារអាមេរិក (មិនទាន់គិតការទិញវ៉ាក់សាំង) ដែលពេលនោះកម្ពុជាយើងគ្រប់គ្រងសភាពការណ៍បានល្អ និងបានរំពឹងទុកថា ការចាប់ផ្តើមចាក់វ៉ាក់សាំងនៅដើមខែកុម្ភៈ ឆ្នាំ២០២១ នឹងជួយឱ្យការឆ្លងជំងឺនេះកាន់តែស្រាកស្រាន្ត។ ការកើនឡើងយ៉ាងគំហុកនៃបន្ទុកចំណាយលើផ្នែកសុខាភិបាល និងសង្គម នឹងធ្វើឱ្យឱនភាពថវិកាឆ្នាំ២០២១ រីកធំរហូតដល់ទៅ **១១,០៩% នៃ ផសស** ខ្ពស់ជាងការគ្រោងក្នុងច្បាប់ថវិកាប្រមាណជិត ២ ពិន្ទុភាគរយ។

ទោះជាយ៉ាងនេះក្តី ការរីកធំនៃឱនភាពថវិកានេះមិនទាន់ជាបញ្ហាចោទធំដុំសម្រាប់រាជរដ្ឋាភិបាលនោះទេ ដោយសារតម្រូវការថវិកាបន្ថែមនេះ នឹងត្រូវបំពេញមកវិញតាមរយៈ ការបញ្ចេញបន្ថែមនូវប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ដែលនឹងអនុញ្ញាតឱ្យកម្ពុជា បន្តគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនប្រកបដោយទំនុកចិត្ត ភាពរឹងមាំ និងភាពជាម្ចាស់ខ្ពស់។ ត្រង់ចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ជូនអង្គសិក្ខាសាលាជ្រាបថា ពុំមែនគ្រប់រដ្ឋាភិបាលសុទ្ធតែមានប្រាក់សន្សំរបស់ខ្លួន សម្រាប់បញ្ចេញក្នុងការដោះស្រាយបញ្ហានៅពេលមានគ្រោះអាសន្ននោះឡើយ ហើយអ្វីដែលកម្ពុជាមាន នាពេលនេះ ពុំមែនកើតឡើងដោយចៃដន្យនោះទេ។ ប្រាក់សន្សំទាំងនេះ គឺកើតចេញពីការគិតគូរប្រកបដោយភាពមធ្យ័ត និងចក្ខុវិស័យវែងឆ្ងាយក្នុងការគ្រប់គ្រងធនធានថវិកាជាតិ និងជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងក្នុងកិច្ចការកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក, ដែលនាំឱ្យកម្ពុជារក្សាបាននូវទ្រនាប់ថវិកា (Fiscal Buffer) ក្នុងកម្រិតសមរម្យមួយ ព្រមទាំងបានរួមចំណែក យ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាចំពោះមុខ ដូចដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន។

សម្រាប់ឆ្នាំ២០២២ ការរៀបចំក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានចរិតជាការប្រឹងប្រែងប្តូរផ្តាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដើម្បីការពារអាយុជីវិតរបស់ប្រជាជនផង និងកសាងមូលដ្ឋានដើម្បីសម្រាប់រស់នៅជាមួយជំងឺកូវីដ-១៩ ផង ក្នុងគោលដៅស្តារសេដ្ឋកិច្ច និងស្តារជីវភាពប្រជាជនឡើងវិញ តាមរយៈការបន្តអនុវត្តនូវកញ្ចប់ អន្តរាគមន៍សង្គម-សេដ្ឋកិច្ច សំដៅបន្តគ្រប់គ្រងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ បង្កើត

ការងារជូនប្រជាពលរដ្ឋ, លើកកម្ពស់បរិយាកាសធុរកិច្ច តាមរយៈការផ្ដល់ការលើកទឹកចិត្ត និងបង្កើនទំនុកចិត្តវិនិយោគិន, បន្តអភិវឌ្ឍធនធានមនុស្ស, លើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងបន្តដោះស្រាយរាល់បញ្ហាប្រឈមជារចនាសម្ព័ន្ធនានា ដែលជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលនឹងបន្តធ្វើអាទិភាព-វូបនីយកម្មមុខសញ្ញាចំណាយឱ្យកាន់តែចំគោលដៅ និងពង្រឹងការកៀរគរធនធានដែលនៅមានសក្ដានុពល ទាំងនៅលើផ្នែកចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ព្រមទាំងបន្ថែមការគិតគូរទៅលើយន្តការហិរញ្ញប្បទាននានា ដើម្បីបំពេញឱ្យបាននូវរាល់តម្រូវការចំណាយ ក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាធានាឱ្យបាននូវការស្ដារឡើងវិញ នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបន្តតម្កល់នូវគុណតម្លៃនៃសិទ្ធិរស់រានមានជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូបជាចម្បង ដែលមានន័យថា អាទិភាពខ្ពស់បំផុតនៅតែត្រូវបានផ្ដល់ទៅលើចំណាយចាំបាច់នានា សម្រាប់ការទប់ទល់ទៅនឹងការរាលដាល នៃជំងឺកូវីដ-១៩។ ក្នុងនោះ មានរួមបញ្ចូលនូវការត្រៀមដាក់ចេញកញ្ចប់ថវិកាអន្តរាគមន៍ក្នុងទំហំប្រមាណជិត **១ ០០០ លានដុល្លារអាមេរិក** សំដៅបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជនកម្ពុជា ព្រមទាំងបន្តរក្សាលំនឹង សង្គម-សេដ្ឋកិច្ច ដើម្បីឈានទៅជំរុញឡើងវិញជាបណ្ដើរៗ នូវក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចដែលមានស្រាប់ និងដែលជាសក្ដានុពលថ្មីៗ ស្របទៅតាមបរិបទ «**គន្លងប្រក្រតីភាពថ្មី**»។

ជារួម ក្នុងរយៈពេលជិត ២ឆ្នាំកន្លងមកនេះ គោលនយោបាយថវិកា(Fiscal Policy) បានក្លាយជាឧបករណ៍គោលនយោបាយដ៏សំខាន់របស់រាជរដ្ឋាភិបាលក្នុងការទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ព្រមទាំងការគ្រប់គ្រងសភាពការណ៍នៃវិបត្តិជំងឺកូវីដ-១៩។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានគិតគូរប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ក្នុងការរៀបចំក្របខណ្ឌចំណាយសាធារណៈឆ្នាំ២០២២ ពោលគឺប្រកាន់យកគោលការណ៍ “**ត្រៀមខ្លួនសម្រាប់អ្វីដែលអាក្រក់បំផុត និងសង្ឃឹមសម្រាប់អ្វីដែលល្អបំផុត**” (Prepare for the Worst, Hope for the Best) ក្នុងស្មារតីធានាឱ្យមានថវិកាគ្រប់គ្រាន់សម្រាប់ការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងគាំទ្រដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច- សង្គមក្នុងរយៈពេលមធ្យម។

ក្នុងនាមជាសេនាធិការផ្ទាល់ របស់រាជរដ្ឋាភិបាលនៅក្នុងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងក្រោមការចង្អុលបង្ហាញ ប្រកបដោយភាពប៉ិនប្រសប់ ត្រឹមត្រូវ ច្បាស់លាស់ និងម៉ឺងម៉ាត់របស់**សម្ដេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយភាពហ្មត់ចត់ និងការទទួលខុសត្រូវខ្ពស់ក្នុងការធានាឱ្យបាននូវនិរន្តរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងធានានូវភាពជាម្ចាស់របស់កម្ពុជា លើការគ្រប់គ្រងជោគវាសនារបស់ខ្លួន ដោយមិនអនុញ្ញាតឱ្យប្រទេសជាតិធ្លាក់ចូលក្នុងស្ថានភាពបំណុលវ័ណ្ដកនោះឡើយ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ។

## ៣.អំពីទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល និងផែនការស្ដារសេដ្ឋកិច្ចឡើងវិញ

ស្របពេលដែលសង្គម-សេដ្ឋកិច្ចសកលបន្តស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ដោយសារការអូសបន្លាយនៃជំងឺកូវីដ-១៩, កម្ពុជាក៏អាចនឹងទទួលបាននូវកាលានុវត្តភាពមួយចំនួនវិញដែរ។ ការណ៍នេះអាស្រ័យលើសមត្ថភាព និងលទ្ធភាពរបស់កម្ពុជាក្នុងការចេះបត់បែន និងតាមទាន់សភាពការណ៍ប្រែប្រួលក្នុងតំបន់ និងពិភពលោក ក៏ដូចជាការចេះប្រើប្រាស់លក្ខខណ្ឌអំណោយផលទាំងឡាយ សម្រាប់លើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច និងកែលម្អបរិស្ថានវិនិយោគ ដើម្បីទាក់ទាញបន្ថែមនូវការវិនិយោគ និងធុរកិច្ច ដែលអាចនឹងហូរចេញពីតំបន់មានជម្លោះពាណិជ្ជកម្ម និងមានអស្ថិរភាពនយោបាយ ព្រមទាំងការផ្លាស់ប្ដូរខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ចូលមកកាន់កម្ពុជា។ ក្នុងន័យនេះ ការបោះជំហានលើគន្លងប្រក្រតីភាពថ្មី ផ្សារភ្ជាប់នឹងការផ្លាស់ប្ដូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល ព្រមទាំងការបន្តគ្រប់គ្រងផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ គឺជាទិសដៅគោលនយោបាយចម្បង និងជាយុទ្ធសាស្ត្ររបស់កម្ពុជាក្នុងឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់។

ម្យ៉ាងវិញទៀត ការបង្កើតបាននូវភាពស៊ាំសហគមន៍ ក្នុងរយៈពេលពេលខ្លីខាងមុខនេះ ក៏នឹងផ្ដល់មូលដ្ឋានដ៏សំខាន់សម្រាប់កម្ពុជា ក្នុងការគាំទ្រឱ្យសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជាអាចងើបឡើងវិញ និងជំរុញការឈានទៅដល់ «**ប្រក្រតីភាពថ្មី**» ឱ្យបានកាន់តែរហ័ស ជាពិសេសក្នុងការស្ដារកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកម្ពុជាយើង។ ត្រង់ចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ជូនអង្គសិក្ខាសាលាជ្រាបថាសមិទ្ធផលដែលយើងកំពុងឃើញចំពោះមុខនេះ និងការឈានទៅការបង្កើតបាននូវភាពស៊ាំសហគមន៍ គឺកើតចេញពីឆន្ទៈដ៏ក្លាហានប្រកបដោយស្មារតីបុរេសកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយមេត្តាធម៌ របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ដែលបានស្វែងរកវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់ចាក់ជូនប្រជាជនកម្ពុជាយើង។

ជាការប្រមើលទៅមុខ ជំងឺកូវីដ-១៩ ត្រូវបានរំពឹងថានឹងក្លាយជាផ្នែកមួយ នៃ «**គន្លងប្រក្រតីភាពថ្មី**»។ នៅក្នុងបរិការណ៍នេះ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការនាំកម្ពុជាទៅ ដល់ស្ថានភាពថ្មីនៃ «**ការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី**» នឹងពឹងផ្អែកលើវិធានការគន្លឹះ ៤យ៉ាងគឺ÷ (១). ការបន្តជំរុញចាក់វ៉ាក់សាំងដើម្បីបង្កើតបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចរឹងមាំ, (២). ការបន្តជំរុញប្រើប្រាស់យ៉ាងទូលំទូលាយនូវឧបករណ៍តេស្តរហ័សក្នុងការរុករកអ្នកផ្ទុកមេរោគកូវីដ-១៩ ដើម្បីគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកវីដ-១៩ ប្រកបដោយប្រសិទ្ធភាព និងឱ្យបានទាន់ពេល; (៣). ការពង្រឹងសមត្ថភាពព្យាបាល និងការប្រើប្រាស់ថ្នាំ ព្រមទាំងមធ្យោបាយព្យាបាល ប្រកបដោយស័ក្តិសិទ្ធិភាព និង (៤). ការបន្តជំរុញអនុវត្តដោយម៉ត់ចត់ និងប្រកបដោយប្រសិទ្ធភាព នូវវិធានការចាំបាច់នានា ទាំងផ្នែករដ្ឋបាល ទាំងផ្នែកសុខាភិបាល និងទាំងវិធានការច្បាប់ ក៏ដូចជាវិធានការផ្សព្វផ្សាយ និងអប់រំដើម្បីគ្រប់-គ្រងការឆ្លងរាលដាល និងទាក់ទាញការចូលរួមយ៉ាងទូលំទូលាយ និងយ៉ាងសកម្មពីសំណាក់សាធារណជនគ្រប់មជ្ឈដ្ឋាន និងគ្រប់ៗរូប។

ឈរលើមូលដ្ឋាននេះ បើទោះជាកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយធនធានក៏មានកម្រិត រាជរដ្ឋាភិបាលប្តេជ្ញាប្រែក្លាយវិបត្តិនៃជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការកែទម្រង់កាន់តែស៊ីជម្រៅ សំដៅកសាងប្រព័ន្ធសេដ្ឋកិច្ច និងសង្គមឱ្យកាន់តែរឹងមាំ និង មានភាពធន់ទៅនឹងវិបត្តិនាអនាគត ជាពិសេសឆ្លើយតបឱ្យបានទាន់ពេលទៅនឹងការវិវត្ត នៃព្រឹត្តិការណ៍នានាក្នុងតំបន់ និងសកល។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងរៀបចំ ហើយគ្រោងនឹងដាក់ចេញនូវផែនការស្តារសេដ្ឋកិច្ច**ឡើងវិញពីវិបត្តិកូវីដ-១៩** សម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងគោលបំណង “**អូសទាញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅខិតជិតកំណើនសក្តានុពលប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាពិសេសលើមូលដ្ឋានឧស្សាហកម្មរឹងមាំដែលមានសមត្ថភាពនាំចេញខ្ពស់ និងផ្សារភ្ជាប់កាន់តែខ្លាំងក្លាជាមួយខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងពិភពលោក**”។ ដើម្បីសម្រេចឱ្យបានគោលដៅនេះរាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់អាទិភាពលើ÷

(១). **ការស្តារឡើងវិញ:** ដោយកសាងមូលដ្ឋានរឹងមាំសម្រាប់ស្តារសេដ្ឋកិច្ចឱ្យវិលទៅស្ថិតលើមាគ៌ានៃកំណើនឡើងវិញ ដោយផ្តោតលើការធានាសុវត្ថិភាព ការគ្រប់គ្រងផលប៉ះពាល់ ការរក្សាលំនឹង និងការរស់ឡើងវិញនៃធុរកិច្ច ដែលមានសក្តានុពលជាពិសេស ក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំង និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័ស

(២). **ការកែទម្រង់:** ដោយបន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធដែលរួមមានការធ្វើ ឱ្យប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម ការវិនិយោគ និងធុរកិច្ច ការជំរុញ និងការអភិវឌ្ឍឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋ-កិច្ចទាំងវិស័យសាធារណៈ និងវិស័យឯកជន

(៣). **ការកសាងភាពធន់:** ដោយពង្រឹងការត្រៀមខ្លួន និងការឆ្លើយតបទៅនឹងជំងឺ ឬស្ថានភាពស្រដៀងគ្នាដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្តោតលើការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គមដែលរឹងមាំ មានប្រសិទ្ធភាព និងការធានានូវចីរភាព និងបរិយាបន្នកម្មនៃការស្តារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ក្នុងស្មារតីនេះ ជាមួយនឹងការធានានូវការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងប្រកបដោយ ប្រសិទ្ធភាពនូវធនធានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងរយៈពេលមធ្យម រហូតដល់ឆ្នាំ២០២៣ កម្ពុជាត្រូវបង្កើនការប្តេជ្ញា-ចិត្ត និងតម្រង់កិច្ចខិតខំ ប្រឹងប្រែងប្រកបដោយភាពម៉ឺងម៉ាត់ និងឆន្ទៈនយោបាយខ្ពស់ដោយតម្កល់ផលប្រយោជន៍ជាតិជាធំក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងការពន្លឿនកិច្ចការកែទម្រង់គ្រប់ការដ្ឋានជាពិសេស ការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ដែលជា "**កត្តាស្លាប់រស់**" ដើម្បីធានាឱ្យកម្ពុជាអាចឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការអភិវឌ្ឍវែងឆ្ងាយរបស់ខ្លួន។

ជាថ្មីម្តងទៀត ខ្ញុំសូមគោរពថ្លែងអំណរ-គុណយ៉ាងជ្រាលជ្រៅជូនចំពោះ លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២ រដ្ឋសភា ឯកឧត្តម លោកជំទាវ ប្រធាន និងអនុប្រធាន នៃគណៈកម្មការទាំងអស់ សមាជិក-សមាជិកានៃព្រឹទ្ធសភា និងរដ្ឋសភាដែលបានអញ្ជើញចូលរួមសិក្ខាសាលានាឱកាសនេះ។

ជាចុងក្រោយ, ខ្ញុំសូមជូនពរឱ្យសិក្ខា-សាលាថ្ងៃនេះ ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ និងសូមជូនពរ លោកជំទាវ ឯកឧត្តម លោក លោកស្រីទាំងអស់ ដែលមានវត្តមានក្នុងសិក្ខាសាលានេះ សូមប្រកបដោយពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំ បីឃ្លៀងឃ្លាតឡើយ ជាពិសេស ចៀសឆ្ងាយពីជំងឺកូវីដ-១៩៕■

***សូមអរគុណ!***



# ផ្នែកទី ៤

# ទស្សនៈ និងមតិ



*“ ទស្សនវិជ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា គឺប្រែក្លាយការគំរាមកំហែងពីជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការកែទម្រង់នៅក្នុងប្រទេសនីមួយៗ។ លើមូលដ្ឋាននេះ ខ្ញុំសូមគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាមិនបានបន្ថយល្បឿននៃការងារកែទម្រង់របស់ខ្លួននៅក្នុងគ្រប់វិស័យនោះឡើយ។ ផ្ទុយទៅវិញ គោលដៅរបស់យើង គឺបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា តាមរយៈការបង្កភាពងាយស្រួល និងការបង្កើតបរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច និងការវិនិយោគនៅក្នុងប្រទេស។”*

*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងតាមប្រព័ន្ធវីដេអូ ក្នុងកិច្ចប្រជុំកំពូលឆ្នាំ២០២០ នៃវេទិកាសេដ្ឋកិច្ចពិភពលោក ស្តីពីផលប៉ះពាល់លើការអភិវឌ្ឍប្រកបដោយចីរភាពក្រោមប្រធានបទ÷ « ការកសាងឆ្ពោះទៅមុខប្រកបដោយចីរភាពនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន»*



*“ ពុំមែនគ្រប់រដ្ឋាភិបាលសុទ្ធ តែមានប្រាក់សន្សំរបស់ខ្លួន សម្រាប់បញ្ចេញក្នុងការដោះស្រាយបញ្ហា នៅពេលមានគ្រោះអាសន្ននោះឡើយ ហើយអ្វីដែលកម្ពុជាមាននាពេលនេះពុំមែនកើតឡើងដោយចៃដន្យនោះទេ។ ប្រាក់សន្សំទាំងនេះ គឺកើតចេញពីការគិតគូរប្រកបដោយ ភាពមធ្យ័ត និងចក្ខុវិស័យវែងឆ្ងាយក្នុងការគ្រប់គ្រងធនធានថវិកាជាតិ និងជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែង ក្នុងកិច្ចការកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក, ដែលនាំឱ្យកម្ពុជា រក្សាបាននូវទ្រនាប់ថវិកា (Fiscal Buffer) ក្នុងកម្រិតសមរម្យមួយព្រមទាំងបានរួមចំណែក យ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាចំពោះមុខ ដូចដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន។*

*អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងតាមប្រព័ន្ធវីដេអូក្នុងសិក្ខាសាលាស្តីពីការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២*



*“ បើទោះបី កម្ពុជាបាននិងកំពុងជួបប្រទះបញ្ហាធំៗដូចជា៖ បញ្ហាការរីករាលដាលជំងឺកូវីដ-១៩ ការកាត់ផ្តាច់ផ្នែកខ្លះនៃការអនុគ្រោះពន្ធ EBA បញ្ហាគ្រោះមហន្តរាយធម្មជាតិទឹកជំនន់ក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែអាចឈរក្នុងភាពជាម្ចាស់ការដោយខ្លួនឯងបាន ហើយបានកសាងនូវសមិទ្ធផលជាច្រើនពាសពេញផ្ទៃប្រទេស និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ។ ភាពជោគជ័យ និងសមិទ្ធផលពាសពេញផ្ទៃប្រទេសទាំងអស់នេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ គឺសុទ្ធតែបានកើតឡើងពីការខិតខំប្រឹងប្រែងឥតឈប់ឈរការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញាស្មារតីរបស់ប្រមុខថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងកិច្ចសហការល្អពីគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ក្នុងខណៈដែលកម្ពុជាមានសុខសន្តិភាពពេញលេញ មានស្ថិរភាពនយោបាយ និងស្ថិរភាពសេដ្ឋកិច្ច។”*

*ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងពិធីបើកការដ្ឋានស្ថាបនាហេដ្ឋារចនាសម្ព័ន្ធចំនួន ៣៨ខ្សែ ក្នុងក្រុងសៀមរាប នៅថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។*



*“ បដិវត្តន៍ឧស្សាហកម្មទី៤ គឺជានិន្នាការសកលរយៈពេលយូរមួយ ដែលយើងមិនអាចជៀសបាន ហើយវាផ្តល់ផលប្រយោជន៍ដល់មនុស្សជាតិច្រើនផង ប៉ុន្តែក៏ផ្តល់ផលវិបាកអវិជ្ជមានដល់មនុស្សលោកផងដែរ។ ចំណុចខ្លាំង**ទី១** របស់បដិវត្តន៍ឧស្សាហកម្មទី៤ ជាពិសេស Digitalization នេះគឺ ការបង្កើន Productivity ក្នុងសេដ្ឋកិច្ច ក្នុងផលិតកម្ម និងសេវាកម្ម បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចដែលយើងត្រូវការ បង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច, **ទី២** គឺ បង្កើនទំនាក់ទំនង (connectivity) រវាងមនុស្ស រវាងតួអង្គសំខាន់ៗ នៃសង្គម រវាងអ្នកផលិត និងអ្នកប្រើប្រាស់ដែលធ្វើឱ្យការទាក់ទងកាន់តែងាយស្រួល ហើយបន្ថយតម្លៃ (cost) នៃការទាក់ទងនេះ ធ្វើឱ្យសេដ្ឋកិច្ចកាន់តែមានតម្លៃបន្ថែមកាន់តែខ្ពស់ថែមទៀត, **ទី៣** គឺពិពិធកម្ម វាធ្វើឱ្យបាត់បង់នូវវិស័យខ្លះក្នុងសេដ្ឋកិច្ច ប៉ុន្តែក៏បង្កើតនូវវិស័យខ្លះទៀតផងដែរ។ កន្លែងខ្លះទៀតវាបង្កើននូវប្រសិទ្ធភាពនៃវិស័យមួយឱ្យកើនកាន់តែខ្ពស់ថែមទៀតដោយសារតែបច្ចេកវិទ្យា វាជំរុញពិពិធកម្មក្នុងសេដ្ឋកិច្ច, **ទី៤** ដែលសំខាន់ គឺវិស័យបច្ចេកវិទ្យាឌីជីថលនេះ បង្កើតបានជាជន្ទល់មួយទៀតនៃសេដ្ឋកិច្ចសឹងតែគ្រប់ប្រទេសទាំងអស់ រួមទាំងកម្ពុជាផងដែរ ដែលជាជន្ទល់ដឹកនាំកំណើនសេដ្ឋកិច្ច (កម្លាំងដឹកនាំសេដ្ឋកិច្ច កម្លាំងចលករសេដ្ឋកិច្ច) នៅក្នុងប្រទេសកម្ពុជា។”*

*ឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្លែងបាឋកថាពិសេស តាមប្រព័ន្ធវីដេអូក្នុងឱកាសកម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ២០២១ ស្តីពី “ យុវជន និងសង្គមឌីជីថល”*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ÷

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ អ.គ.ហ. |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង អ.គ.ហ. |
| មាស សុខសេនសាន | អគ្គលេខាធិការរង អ.គ.ហ. |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង អ.គ.ហ. |
| យ៉េត វីណែល | អគ្គលេខាធិការរង អ.គ.ហ. |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង អ.គ.ហ. |
| អ៊ុង លុយណា | អគ្គលេខាធិការរង អ.គ.ហ. |

## រៀបចំអត្ថបទដោយ ÷

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| វុទ្ធី សត្រា | មន្ត្រីជំនាញ |
| ស៊ុន គឹមហេង | មន្ត្រីជំនាញ |

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញជាន់ខ្ពស់ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |
| គុណ មុនីរ័ត្នភ្លង | មន្ត្រីជំនាញ |
| តាន់ វណ្ណលិ | មន្ត្រីជំនាញ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | មន្ត្រីជំនាញ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | មន្ត្រីជំនាញ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ន | មន្ត្រីជំនាញជាន់ខ្ពស់ |
| ផេង សុខម៉ៃ | មន្ត្រីជំនាញ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីជំនាញជាន់ខ្ពស់ថវិកា |
| ឈុន ម៉ារឌី | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ជា សុខផេង | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ឡេង ចាន់ភ្លួង | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ÷

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
ក្រុមការងារកែទម្រង់នៃអគ្គាធិការដ្ឋាន
ក្រុមការងារកែទម្រង់នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## នវានុវត្តន៍ និងកែសម្រួលដោយ ÷

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញជាន់ខ្ពស់ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |
| គុណ មុនីរ័ត្នភ្លង | មន្ត្រីជំនាញ |
| តាន់ វណ្ណលិ | មន្ត្រីជំនាញ |

អាសយដ្ឋានទំនាក់ទំនង៖
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm